# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ស្ថានភាពនៃអតិផរណានៅប្រទេសកម្ពុជា និង ថៃ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


| | |
|---|---|
| រៀបរៀង និងចងក្រងដោយ | ណែនាំដោយ |
| និស្សិតឈ្មោះ: **ស្រស់ ឡាឌី** | សាស្ត្រាចារ្យ **ជុន ចាន់ណែត** |
| **លឹម ប៊ុនឆៃ** | |
| ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច | ឆ្នាំចូលសិក្សា ២០១៨ |
| ជំនាញ ធនាគារ និង ហិរញ្ញវត្ថុ ជំនាន់ទី១៥ | ឆ្នាំសរសេរសារណា ២០២២ |

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ស្រស់ ឡាឌី** និង **លឹម ម៉ិនឆៃ** ជានិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំទី ៤ ជំនាន់ទី១៥ ជំនាញ ធនាគារ និងហិរញ្ញវត្ថុ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងខ្ពង់ខ្ពស់ចំពោះ**

- **លោកអ្នកមានគុណទាំងពីរ** របស់យើងខ្ញុំ ដែលលោកបានផ្តល់កំណើត និងបានចិញ្ចឹមបីបាច់ថែរក្សាយើងខ្ញុំយ៉ាងយកចិត្តទុកដាក់ជាទីបំផុត ព្រមទាំងខិតខំទូន្មានប្រៀនប្រដៅ ថែមទាំងផ្តល់ឱកាសឲ្យយើងខ្ញុំទាំងពីរនាក់បានសិក្សារៀនសូត្រតាំងពីនៅកុមារភាពរហូតមកដល់មានចំណេះដឹង។ អ្វីដែលលើសពីនេះ លោកទាំងពីរតែងផ្តល់កម្លាំងចិត្ត ក្តីស្រលាញ់ និងការផ្គត់ផ្គង់រាល់តម្រូវការនានាដែលយើងខ្ញុំទាំងពីរត្រូវការជាចាំបាច់សម្រាប់ការសិក្សា ផ្នែកហិរញ្ញវត្ថុ ផ្នែកកម្លាំងចិត្ត។
- **លោកគ្រូ អ្នកគ្រូ គ្រប់កម្រិត** ដែលបានយកចិត្តទុកដាក់អប់រំ ផ្តល់ដំបូន្មាន ប្រៀនប្រដៅ ក៏ដូចជាផ្តល់នូវបទពិសោធន៍ រួមទាំងចំណេះដឹងល្អៗយ៉ាងច្រើនក្រៃលែងតាំងពីកម្រិតបឋមសិក្សារហូតមកដល់កម្រិតសាកលវិទ្យាល័យ។
- **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធាន និងអនុប្រធានការិយាល័យសិក្សា និងស្រាវជ្រាវ ព្រមទាំងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ** គ្រប់មុខវិជ្ជា នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំដឹកនាំ បង្ហាត់បង្ហាញ បង្រៀន ក៏ដូចជាប្រឹងប្រែងក្នុងការផ្ទេរនូវចំណេះដឹងមកដល់យើងខ្ញុំឲ្យទទួលបាននូវជោគជ័យក្នុងការសិក្សារៀនសូត្រ រួមទាំងចែករំលែកនូវបទពិសោធន៍ជីវិតល្អមកដល់យើងខ្ញុំ។
- លោកសាស្ត្រាចារ្យ **ជុន ចាន់ណែត** ដែលជាសាស្ត្រាចារ្យណែនាំដល់ក្រុមយើងខ្ញុំដោយ លោកបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោកក្នុងការចង្អុលបង្ហាញពីរបៀបនៃការសិក្សាស្រាវជ្រាវឲ្យទទួលបានប្រសិទ្ធភាពល្អ ក៏ដូចជាវិធីសាស្ត្រក្នុងការស្វែងរកប្រភពទិន្នន័យ ឬឯកសារយោងដែលមានប្រភពច្បាស់លាស់ដើម្បីយកមកចងក្រងជាសារណា។ ពិសេសជាងនេះទៅទៀត លោកបានផ្តល់នូវអនុសាសន៍ ព្រមទាំងជួយកែលម្អនូវចំណុចខ្វះចន្លោះ កំហុសឆ្គងទាំងឡាយណាដែលយើងខ្ញុំមានឲ្យមានភាពល្អប្រសើរឡើងវិញ។
- មិត្តភក្តិទាំងឡាយដែលតែងតែរងចាំជួយផ្តល់កម្លាំងចិត្ត ព្រមទាំងគំនិតយោបល់ផ្សេងៗ។

ជាចុងក្រោយ យើងខ្ញុំ សូមជូនពរឲ្យលោកមានគុណទាំងពីរ ឯកឧត្តម លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យគ្រប់កម្រិតទាំងអស់ និងមិត្តរួមថ្នាក់ ព្រមទាំងមិត្តនិស្សិតទាំងអស់ ឲ្យទទួលបាននូវសុភមង្គល និងសុខភាពល្អ។

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលបានធ្វើសមាហរណកម្មចូលជាសមាជិកអាស៊ាននៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩។ យើងធ្វើការសង្កេតមើលពីអតីតកាលរបស់កម្ពុជាមកឃើញថាជាប្រទេសមួយដែលធ្លាប់បានឆ្លងកាត់នូវក្នុងយុគសម័យកាលលំបាកជាច្រើន មិនថាតែសង្គ្រាម ឬក៏វិបត្តិសេដ្ឋកិច្ចនយោបាយនោះទេ ដែលរាល់វិបត្តិទាំងអស់នោះហើយបានបង្កទៅជាការខូចខាតយ៉ាងធ្ងន់ធ្ងរដល់ប្រទេសជាតិ។ ពិសេសជាងនេះទៅទៀតនោះ គឺវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៨ ដែលវិបត្តិនេះហើយបានបន្ថយល្បឿនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិកម្ពុជា ហើយទន្ទឹមនឹងនោះវាក៏បានធ្វើឲ្យកើតមានឡើងនូវកម្រិតអតិផរណាយ៉ាងខ្ពស់មិនធ្លាប់មានផងដែរ គឺស្ថិតក្នុងអត្រា ២៥.៧%។

ក្នុងទ្រឹស្តីរបស់សេដ្ឋកិច្ចបានបង្ហាញថា វាមានកត្តាជាច្រើនដែលមានឥទ្ធិពលលើអតិផរណា ប៉ុន្តែភាពជាក់ស្តែង វាមានភាពស្មុគស្មាញក្នុងការស្វែងរកពីមូលហេតុដែលនាំឲ្យកើតមានឡើងនូវអតិផរណា។ បើយើងសាកសង្កេតមើលពីស្ថានភាពអតិផរណានៅកម្ពុជា គឺយើងទទួលរងនូវសម្ពាធពីប្រទេសដែលជាដៃគូពាណិជ្ជកម្មសំខាន់មួយចំនួនដូចជាប្រទេសថៃ វៀតណាម ចិនជាដើម ព្រោះថាយើងជាប្រទេសដែលនាំចូលទំនិញពីបណ្តាប្រទេសទាំងនោះ។ ដូចនេះ នៅពេលដែលអតិផរណានៅប្រទេសទាំងនោះមានការប្រែប្រួល អតិផរណាកម្ពុជាក៏មានការប្រែប្រួលផងដែរ។

ដោយការមើលឃើញពីសារៈសំខាន់ ក៏ដូចជាផលប៉ះពាល់របស់អតិផរណាមកលើសេដ្ឋកិច្ចនេះហើយ ទើបក្រុមយើងខ្ញុំបានសម្រេចចិត្តកំណត់ជ្រើសយកប្រធានបទមួយ មកធ្វើការស្រាវជ្រាវដែលមានចំណងជើងថា "ស្ថានភាពអតិផរណានៃប្រទេសកម្ពុជា និងថៃ"។ ដោយលើកយកនូវប្រទេសថៃ ដែលជាប្រទេសក្បែរខាង និងជាប្រទេសដែលមានខឿនសេដ្ឋកិច្ចរឹងមាំយកមកធ្វើការសិក្សា និងប្រៀបធៀបជាមួយនឹងប្រទេសកម្ពុជាជាគោលដោយសិក្សាទៅកត្តាទូទៅដូចជា ការប្រៀបធៀបការប្រែប្រួលនៃអត្រាអតិផរណារបស់ប្រទេសទាំងពីរ។

ជាចុងក្រោយ ទោះបីជាក្រុមយើងខ្ញុំ បានខិតខំធ្វើការសិក្សាស្រាវជ្រាវពាក់ព័ន្ធទៅនឹងប្រធានខាងលើយ៉ាងណាក្តី ក៏របាយការណ៍នេះ នៅតែមានចំណុចខ្វះខាត កំហុសឆ្គង ទាំងការប្រើប្រាស់ពាក្យពេចន៍ក្នុងឃ្លាប្រយោគ ទំហំនៃការសិក្សា ក៏ដូចជាការការរៀបចំនៃរបាយការណ៍សារណា។ ទោះជាយ៉ាងណាក្តី ក៏ក្រុមយើងខ្ញុំសង្ឃឹមថារបាយការណ៍សារណានៃប្រធានបទខាងលើនេះ នឹងបានចូលរួមក្នុងការរក្សាទុកជាឯកសារសម្រាប់សិស្ស និស្សិត និងមិត្តអ្នកអានទាំងឡាយ ដែលចង់សិក្សាស្វែងយល់ពាក់ព័ន្ធនឹងប្រធានបទដែលក្រុមយើងខ្ញុំបានបកស្រាយនេះ និងសូមជូនពរឲ្យ សិស្ស និស្សិតទាំងអស់ទទួលបាននូវជោគជ័យក្នុងការសិក្សា។

# មាតិកា

ទំព័រ

អក្សរកាត់ ............ v

បញ្ជីតារាង ............ vi

បញ្ជីក្រាហ្វិក ............ vii

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ............ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ............ ២

៣. គោលបំណងនៃការស្រាវជ្រាវ ............ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ............ ៣

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ............ ៣

៦. សារៈសំខាន់នៃការស្រាវជ្រាវ ............ ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ ៥

## ជំពូកទី ១
## រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងអតិផរណា

១.១ និយមន័យនៃអតិផរណា ............ ៧

១.២ ប្រភេទនៃអតិផរណា ............ ៧

១.៣ មូលហេតុនៃអតិផរណា ............ ៨

១.៤ ឥទ្ធិពលនៃអតិផរណាមកលើសេដ្ឋកិច្ច ............ ៩

១.៤.១ ផលវិជ្ជមាន ............ ៩

១.៤.២ ផលអវិជ្ជមាន ............ ១១

១.៥ ការគណនាអត្រាអតិផរណា ............ ១៣

១.៥.១ ការគណនាសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ និង អត្រាអតិផរណា ............ ១៣

១.៥.១.១ ការកំណត់តន្ត្រកនៃសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ ............ ១៤

១.៥.១.២ ស្វែងរកតម្លៃ ............ ១៤

១.៥.១.៣ គណនាថ្លៃកន្ត្រកទំនិញ ............ ១៤

១.៥.១.៤ ជ្រើសរើសឆ្នាំគោល និងគណនាសន្ទស្សន៍ថ្លៃ ........ ១៥
១.៥.១.៥ គណនាអត្រាអតិផរណា ........ ១៦

# ជំពូកទី ២

# ស្ថានភាពអតិផរណានៃប្រទេសកម្ពុជា

២.១ ស្ថានភាពទូទៅនៃប្រទេសកម្ពុជា ........ ១៨
២.២ អត្រាអតិផរណាប្រចាំឆ្នាំជាភាគរយឆ្នាំលើឆ្នាំ ........ ១៩
២.៣ ស្ថានភាពអតិផរណាប្រចាំឆ្នាំនីមួយៗ ........ ២០
២.៣.១ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៥ ........ ២០
២.៣.២ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៦ ........ ២២
២.៣.៣ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៧ ........ ២៣
២.៣.៤ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៨ ........ ២៤
២.៣.៥ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៩ ........ ២៥
២.៣.៦ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០២០ ........ ២៧
២.៣.៧ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០២១ ........ ២៨
២.៤ មូលហេតុនៃបម្រែបម្រួលអតិផរណាកម្ពុជា ........ ២៨
២.៤.១ កត្តាខាងក្រៅ ........ ២៨
២.៤.២ កត្តាក្នុងស្រុក (កត្តាតម្រូវការ និងរូបិយវត្ថុ) ........ ៣០
២.៥ ផលប៉ះពាល់នៃអតិផរណា ........ ៣១
២.៥.១ ប៉ះពាល់ដល់បុគ្គលិកដែលទទួលបានចំណូលទាប ........ ៣១
២.៥.២ ប៉ះពាល់ដល់ប្រជាពលរដ្ឋទូទៅ ........ ៣១
២.៥.៣ ប៉ះពាល់ដល់មន្ត្រីរាជការដែលចូលនិវត្តន៍ ........ ៣២
២.៦ ដំណោះស្រាយ ........ ៣២
២.៦.១ ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ........ ៣២
២.៦.២ គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ ........ ៣៣
២.៦.៣ ការអនុវត្តគោលនយោបាយដំឡើងប្រាក់បៀវត្ស ........ ៣៤

## ជំពូកទី ៣

## ស្ថានភាពអតិផរណានៃប្រទេសថៃ

៣.១ ស្ថានភាពទូទៅនៃប្រទេសថៃ....................................................................................................៣៥
៣.២ អត្រាអតិផរណាប្រចាំឆ្នាំជាភាគរយ.......................................................................................៣៦
៣.៣ ស្ថានភាពអតិផរណាប្រចាំឆ្នាំនីមួយៗ.....................................................................................៣៨
៣.៣.១ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៥ ......................................................................................៣៨
៣.៣.២ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៦ ......................................................................................៣៩
៣.៣.៣ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៧.......................................................................................៤០
៣.៣.៤ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៨ ......................................................................................៤១
៣.៣.៥ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៩ ......................................................................................៤១
៣.៣.៦ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០២០ ......................................................................................៤២
៣.៣.៧ ស្ថានភាពអតិផរណាប្រចាំឆ្នាំ ២០២១.....................................................................................៤៣
៣.៤ មូលហេតុដែលនាំឲ្យមានអតិផរណាកើតមានឡើង .....................................................................៤៤
៣.៤.១ កត្តាតម្លៃថាមពល ..............................................................................................................៤៥
៣.៤.២ កត្តារូបិយវត្ថុ......................................................................................................................៤៥
៣.៥ ផលប៉ះពាល់.........................................................................................................................៤៦
៣.៦ យុទ្ធសាស្ត្រ និងដោះស្រាយរបស់រដ្ឋាភិបាលថៃលើបញ្ហាអតិផរណា.........................................៤៦

## ជំពូកទី ៤

## ការពិភាក្សា វិភាគ ប្រៀបធៀបទៅលើការវិវត្តនៃ

## អត្រាអតិផរណារបស់ប្រទេសកម្ពុជា និងថៃ

៤.១ ការប្រៀបធៀបអត្រាអតិផរណារវាងប្រទេសកម្ពុជា និងថៃ .........................................................៤៨
៤.២ ប្រៀបធៀបមូលហេតុដែលនាំឲ្យមានអតិផរណារវាងប្រទេសកម្ពុជា និងប្រទេសថៃ ......................៥១
៤.៣ បញ្ហាប្រឈមនៃការប្រែប្រួលអត្រាអតិផរណានៃប្រទេសកម្ពុជា និងប្រទេសថៃ...........................៥២
៤.៤ ដំណោះស្រាយរបស់រាជរដ្ឋាភិបាលនៃប្រទេសទាំងពីរទៅលើអតិផរណា.....................................៥២

## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

១. សេចក្ដីសន្និដ្ឋាន ........................................ ៥៤
២. ការផ្ដល់អនុសាសន៍ ........................................ ៥៥

## ឯកសារយោង

## បញ្ជីឧបសម្ព័ន្ធ

# អក្សរកាត់

| | | |
|---|---|---|
| ASEAN | : Association of Southeast Asian Nations | សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CPI | : Consumer Price Index | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ |
| M2 | : M2 | រូបិយវត្ថុទូទៅ |
| OPEC | : Organization of the Petroleum Exporting Countries | បណ្តាប្រទេសសមាជិកអង្គការនៃប្រទេសនាំចេញប្រេង |
| GDP | : Gross Domestic Product | ផលិតផលក្នុងស្រុកសរុប |
| THB | : Thai Baht | ប្រាក់បាតថៃ |

# បញ្ជីតារាង

តារាង : ១.១ ..................................................................................................១៥
តារាង : ១.២.................................................................................................. ១៧
តារាង : ២.១..................................................................................................១៩
តារាង : ៣.១.................................................................................................. ៣៦
តារាង : ៤.១ ..................................................................................................៤៩

# បញ្ជីក្រាហ្វិក


ក្រាហ្វិក ២.១ : បម្រែបម្រួលអត្រាអតិផរណាជាភាគរយ ឆ្នាំលើឆ្នាំ.................................................. ២០

ក្រាហ្វិក ២.២ : អតិផរណា........................................................................................................ ២១

ក្រាហ្វិក ២.៣ : អតិផរណា........................................................................................................ ២២

ក្រាហ្វិក ២.៤ : អតិផរណា........................................................................................................ ២៣

ក្រាហ្វិប ២.៥ : អតិផរណារួម និងការរួមចំណែកក្នុងអតិផរណារួម.................................................. ២៤

ក្រាហ្វិក ២.៦ : អតិផរណាតាមក្រុម........................................................................................... ២៥

ក្រាហ្វិក ២.៧ : អតិផរណារួម និងការរួមចំណែកក្នុងអតិផរណា..................................................... ២៦

ក្រាហ្វិក ២.៨ : អតិផរណាតាមក្រុមសំខាន់ៗទាំងបី...................................................................... ២៦

ក្រាហ្វិក ២.៩ : អតិផរណារួម និងការរួមចំណែកក្នុងអតិផរណារួម.................................................. ២៧

ក្រាហ្វិក ២.១០ : អតិផរណានៃក្រុមទាំងបី................................................................................. ២៧

ក្រាហ្វិក ២.១១ : អតិផរណារួម និងការរួមចំណែកក្នុងអតិផរណារួម................................................ ២៨

ក្រាហ្វិក ២.១២ : អតិផរណារួម និងអតិផរណាក្រុមទាំងបី............................................................ ២៨

ក្រាហ្វិក ៣.១ : បម្រែបម្រួលអត្រាអតិផរណាជាភាគរយ ឆ្នាំលើឆ្នាំ.................................................. ៣៧

ក្រាហ្វិក ៣.២ : អតិផរណា........................................................................................................ ៣៨

ក្រាហ្វិក ៣.៣ : អតិផរណា........................................................................................................ ៣៩

ក្រាហ្វិក ៣.៤ : អតិផរណា........................................................................................................ ៤០

ក្រាហ្វិក ៣.៥ : អតិផរណា........................................................................................................ ៤១

ក្រាហ្វិក ៣.៦ : អតិផរណា........................................................................................................ ៤២

ក្រាហ្វិក ៣.៧ : អតិផរណា........................................................................................................ ៤៣

ក្រាហ្វិក ៣.៨ : អតិផរណា........................................................................................................ ៤៤

ក្រាហ្វិក ៤.១ : ការវិវត្តនៃអត្រាអតិផរណាប្រចាំឆ្នាំ......................................................................... ៤៨

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលស្ថិតនៅក្នុងចំណោមប្រទេសទាំង ១០ នៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលត្រូវបានហៅកាត់ថា អាស៊ាន (ASEAN) ដែលបានចូលជាសមាជិកនៃសមាគមន៍នេះជាផ្លូវការនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩។ កម្ពុជាពីអតីតកាល ជាប្រទេសដែលធ្លាប់ឆ្លងកាត់នូវក្នុងរបបដ៏ខ្មៅងងឹត គឺរបបប្រល័យពូជសាសន៍ ដែលរបបនេះហើយបានបំផ្លិចបំផ្លាញរចនាសម្ព័ន្ធដឹកនាំរបស់ប្រទេសសឹងតែលើគ្រប់វិស័យ ដោយក្នុងនោះរួមមានដូចជា ប្រព័ន្ធអប់រំ ប្រព័ន្ធសុខាភិបាល កសិកម្ម ពាណិជ្ជកម្ម វិស័យសេដ្ឋកិច្ច ក៏ដូចជាវិស័យផ្សេងៗទៀតផងដែរ។ មិនតែប៉ុណ្ណោះសង្គ្រាមនៅក្នុងប្រទេសកម្ពុជាត្រូវបានអូសបន្លាយជាច្រើនឆ្នាំ ដោយត្រូវបានបញ្ចប់នូវមុនពេលដែលកម្ពុជាធ្វើសមាហរណកម្មចូលជាសមាជិកអាស៊ាន។ ចាប់តាំងពីពេលនោះមក ទើបកម្ពុជាមានឱកាសក្នុងការរៀបចំស្តារប្រទេសជាតិឡើងវិញ ដោយក្នុងនោះមានការរៀបចំប្រព័ន្ធអប់រំ ប្រព័ន្ធសុខាភិបាល ការកែលំអហេដ្ឋារចនាសម្ព័ន្ធ។ បន្ថែមលើសពីនោះទៅទៀត រដ្ឋាភិបាលកម្ពុជា ក៏បានសម្រេចកំណត់យករបបសេដ្ឋកិច្ចទីផ្សារសេរី ដែលជាគោលនយោបាយបើកចំហរជើងមេឃ ដែលក្នុងគោលបំណងផ្តល់ឱកាស និងសិទ្ធិដល់ក្រុមហ៊ុនឯកជននានាចូលមកវិនិយោគរួមគ្នាជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើយ៉ាងណាឲ្យមាននូវការអភិវឌ្ឍន៍នៅក្នុងប្រទេស។

ទន្ទឹមនឹងការចាប់ផ្តើមកសាងប្រទេសឡើងវិញនេះ កម្ពុជាក៏បានជួបប្រទះនូវព្យុះភ្លៀង និងវិបត្តិសេដ្ឋកិច្ចជាច្រើនផងដែរ ដូចជា ការរីករាលដាលនៃជំងឺឆ្លងជាសកល កូវីត ១៩ ដែលវិបត្តិមួយនេះបានធ្វើឲ្យប្រទេសជាច្រើនលើសកលលោកបានបិទខ្ទប់ប្រទេស ហើយវាជាការបង្កជាប៉ះពាល់ដល់វិស័យសេដ្ឋកិច្ចយ៉ាងខ្លាំង ដោយក្នុងនោះ ប្រទេសកម្ពុជាក៏ជាជនរងគ្រោះនៃវិបត្តិនេះផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ កំឡុងពេលមានវិបត្តិហិរញ្ញវត្ថុសកលនៅក្នុងឆ្នាំ២០០៨ វិបត្តិនេះបានបង្កជាប៉ះពាល់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា ដោយវាបានធ្វើឲ្យកើតមានឡើងនូវអត្រាអតិផរណាយ៉ាងខ្ពស់មិនធ្លាប់មាន ដោយស្ថិតក្នុងអត្រា ២៥.៧%។

យោងតាមការសិក្សានៅក្នុងមុខវិជ្ជាម៉ាក្រូសេដ្ឋកិច្ច អតិផរណា គឺជាកត្តាប្រឈមមួយដ៏សំខាន់មួយក្នុងចំណោមកត្តាផ្សេងៗជាច្រើនទៀត ដែលអាចធ្វើឲ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ អន្តរជាតិ និងអាចឈានទៅដល់ការកើតមានឡើងនូវវិបត្តិយ៉ាងធ្ងន់ធ្ងរបានផងដែរ ដូចជាការធ្វើឲ្យទំនិញ ឬសេវាកម្មដែលចរាចរនៅក្នុងប្រទេសឡើងថ្លៃហួសកម្រិត ដែលនឹងបង្កជាផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសនោះប៉ះពាល់យ៉ាងខ្លាំងទៅដល់បុគ្គលដែលមានប្រាក់ចំណូលទាប។ អាស្រ័យហេតុនេះហើយ ទើបបានជាតម្រូវឲ្យរាជរដ្ឋាភិបាលនៃប្រទេសនីមួយៗប្រញាប់គិតគូរស្វែងរកដំណោះស្រាយ ឬវិធីសាស្ត្រក្នុងការទប់ស្កាត់កុំឲ្យអត្រានៃអតិផរណាកើនឡើងក្នុងកម្រិតមួយខ្ពស់រហូតមិនអាចគ្រប់គ្រងបាន។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដូចដែលបានលើកឡើងខាងលើ អតិផរណាជាបញ្ហាដ៏សំខាន់មួយដែលចាំបាច់ត្រូវតែរកដំណោះស្រាយ និងមានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលនៃប្រទេសក្នុងការរកវិធីសាស្ត្រទប់ស្កាត់ ព្រោះវាអាចជាកត្តាបង្កដែលជះឥទ្ធិពលអាក្រក់ដល់សេដ្ឋកិច្ចទាំងមូល និងជាកត្តារាំងស្ទះដល់ការអភិវឌ្ឍសេដ្ឋកិច្ចបាន។

ដោយសារតែ មើលឃើញពីការជះឥទ្ធិពលដ៏អាក្រក់របស់អតិផរណាមកលើសេដ្ឋកិច្ចជាតិទាំងមូលបែបនេះហើយ ទើបធ្វើឲ្យក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទ **ស្ថានភាពនៃអតិផរណានៅប្រទេសកម្ពុជា និងថៃ** ដោយក្រុមយើងខ្ញុំនឹងធ្វើការសិក្សាស្រាវជ្រាវឲ្យកាន់តែច្បាស់ និងលម្អិតអំពីអតិផរណា ដោយមានចំណោទបញ្ហារបស់ប្រធានដូចខាងក្រោម៖

- តើកត្តាអ្វីខ្លះដែលនាំឲ្យកើតមានអតិផរណានៅក្នុងប្រទេសកម្ពុជា និងប្រទេសថៃ?
- តើសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងថៃទទួលរងឥទ្ធិពលអាក្រក់អ្វីខ្លះពីអតិផរណា?
- តើរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា និងប្រទេសថៃធ្លាប់អនុវត្តន៍យុទ្ធសាស្ត្រ ក៏ដូចជាវិធីសាស្ត្រអ្វីខ្លះក្នុងការដោះស្រាយវិបត្តិអតិផរណា?
- តើការវិវត្តនៃអត្រាអតិផរណារបស់ប្រទេសកម្ពុជា និងថៃ មានការប្រែប្រួលយ៉ាងណាខ្លះ នាពេលប៉ុន្មានឆ្នាំចុងក្រោយនេះ?
- តើគម្លាតរវាងអត្រាអតិផរណារបស់ប្រទេសកម្ពុជា និងថៃ មានភាពខុសគ្នាខ្លាំងដែរឬទេ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងដ៏ធំនៃការស្រាវជ្រាវលើប្រធានបទនេះ គឺដោយសារតែការមើលឃើញថា ការស្រាវជ្រាវមុនៗពុំទាន់បានធ្វើបច្ចុប្បន្នភាពឲ្យទាន់សម័យកាលទៅលើទិន្នន័យនៃអតិផរណា រួមទាំងការបកស្រាយនូវត្រង់ចំណុចខ្លះពុំបានក្បោះក្បាយ។ ហើយក៏ដោយសារតែអតិផរណា ជាកត្តាដ៏សំខាន់មួយសម្រាប់សេដ្ឋកិច្ចជាតិ ព្រោះវាអាចជះឥទ្ធិពលដល់សេដ្ឋកិច្ចជាតិយ៉ាងអាក្រក់ ប្រសិនបើរាជរដ្ឋាភិបាលនៃប្រទេសមិនប្រញ៉ាប់ប្រញ៉ាលគិតគូរកដំណោះស្រាយ។ ដូចនេះហើយ ទើបក្រុមយើងខ្ញុំសម្រេចជ្រើសរើសយកប្រធានបទនេះមកសិក្សា ដើម្បីស្វែងរកពីសារៈសំខាន់បន្ថែមលើប្រធានបទនេះ សម្រាប់ចងក្រងរក្សាទុកជាឯកសារដល់សិស្សនិស្សិតក្នុងការសិក្សាស្រាវជ្រាវ ក៏ដូចជាសម្រាប់ប្រជាពលរដ្ឋ រួមទាំងសម្រាប់រាជរដ្ឋាភិបាលរបស់យើងផងដែរ។

ដូច្នេះ កម្មវត្ថុសំខាន់ដែលនឹងត្រូវសិក្សាស្រាវជ្រាវនៃប្រធានបទខាងលើនេះ គឺចង់ផ្តោតសំខាន់ទៅលើចំណុចមួយចំនួនដូចបានរៀបរាប់នៅខាងក្រោម៖

- សិក្សាអំពីកត្តាដែលពាក់ព័ន្ធទៅនឹងមូលហេតុដែលបណ្តាលឲ្យមានអតិផរណា និងផលប៉ះពាល់របស់វាទៅលើសេដ្ឋកិច្ចសង្គម

- វិធីសាស្ត្រក្នុងការគណនា អត្រាអតិផរណា
- សិក្សាទៅលើឥទ្ធិពលនៃអតិផរណាដែលមានក្នុងសេដ្ឋកិច្ចជាតិ
- សិក្សាស្វែងយល់ពីបទពិសោធន៍ផ្សេងៗ ដែលប្រទេសថៃបានអនុវត្តន៍ក្នុងការគ្រប់គ្រងអតិផរណា ក៏ដូចជាវិធានការ និងយុទ្ធសាស្ត្រមួយចំនួនរបស់រដ្ឋាភិបាលរបស់ថៃ
- សិក្សាប្រៀបធៀបពីស្ថានភាពនៃអតិផរណានៃប្រទេសកម្ពុជា និងថៃ ដើម្បីដឹងតើអត្រាអតិផរណានៃប្រទេសមួយណា មានការប្រែប្រួលខ្លាំងជាង។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺជាប់ពាក់ព័ន្ធទៅនឹងស្ថានភាពនៃអតិផរណារបស់ប្រទេសកម្ពុជាទាំងមូល ដោយក្រុមយើងខ្ញុំនឹងធ្វើការសិក្សាស្រាវជ្រាវលម្អិតអំពីដើមហេតុ ក៏ដូចជាផលប៉ះពាល់របស់អតិផរណាមកលើសេដ្ឋកិច្ចកម្ពុជា។ ដោយក្នុងនោះ យើងក៏បានលើកយកស្ថានភាពនៃអតិផរណានៅក្នុងប្រទេសថៃមកសិក្សាផងដែរ ដើម្បីធ្វើការសិក្សាប្រៀបធៀបរវាងស្ថានភាពអតិផរណានៃប្រទេសទាំងពីរ រួមទាំងយុទ្ធសាស្ត្រ ឬវិធីសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយរាល់បញ្ហានៃអតិផរណាដែលកើតមានឡើង។

ដោយវិសាលភាពក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ក្រុមយើងខ្ញុំសូមលើកយកតែចំណុចដែលពាក់ព័ន្ធនឹងប្រធានបទមកសិក្សាតែប៉ុណ្ណោះរួមមាន៖

- ការសិក្សាអំពីរបាយការណ៍នៃអតិផរណារបស់ប្រទេសកម្ពុជាចាប់ពីឆ្នាំ២០១៥ រហូតដល់២០២១
- ការសិក្សាអំពីរបាយការណ៍នៃអតិផរណារបស់ប្រទេសកម្ពុជា
- ប្រៀបធៀបស្ថានភាពនៃអតិផរណានៃប្រទេសថៃ ទៅនឹងស្ថានភាពនៃអតិផរណានៃប្រទេសកម្ពុជា
- ដើមហេតុនៃអតិផរណា ព្រមទាំងដំណោះស្រាយរបស់រាជរដ្ឋាភិបាល

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដោយការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺក្រុមយើងខ្ញុំផ្តោតសំខាន់ទៅលើទ្រឹស្តី និងបទពិសោធន៍ជាក់ស្តែងក្នុងការដោះស្រាយស្រាយវិបត្តិអតិផរណា ការគ្រប់គ្រងអតិផរណាទាំងស្ថិតនៅក្នុងប្រទេសកម្ពុជា និងប្រទេសថៃ។

ដូចនេះ រាល់កាប្រមូលទិន្នន័យសម្រាប់ការស្រាវជ្រាវនេះ គឺផ្អែកទៅលើទិន្នន័យបន្ទាប់បន្សំ ដែលក្រុមយើងខ្ញុំប្រមូលបានពីប្រភពឯកសារជាច្រើនដែលពាក់ព័ន្ធនឹងប្រធានបទ ព្រមទាំងរបាយការណ៍នានាដូចខាងក្រោម៖

- របាយការណ៍ពីគេហទំព័រផ្លូវរបស់ធនាគារជាតិនៃប្រទេសកម្ពុជា និងធនាគារជាតិនៃប្រទេសថៃ

- សៀវភៅម៉ាក្រូសេដ្ឋកិច្ច ដែលស្តីអំពីអតិផរណា
- ឯកសារដែលមានស្រាប់ ដូចជាសៀវភៅរបាយការណ៍សេដ្ឋកិច្ចប្រចាំឆ្នាំរបស់កម្ពុជា របាយការណ៍ពី World Bank Group និងកម្រងឯកសារដែលពាក់ព័ន្ធនានាជាច្រើនទៀត។
- ប្រព័ន្ធសង្គមផ្សព្វផ្សាយផ្សេងៗ ដូចជា ប្រព័ន្ធអ៊ីនធើណេត វេបសាយ ទស្សនាវដ្តីផ្សេងៗ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវ និងកិច្ចការសារណាមួយនេះ ក្រុមយើងខ្ញុំជឿជាក់យ៉ាងមុតមាំថា ប្រាកដជាមានប្រយោជន៍ និងរួមចំណែកយ៉ាងខ្លាំងដល់ សិស្សានុសិស្ស និស្សិត ក៏ដូចជាអ្នកសិក្សាដទៃទៀតដូចខាងក្រោម៖

- **ចំពោះក្រុម**
    - ធ្វើឲ្យយល់ដឹងបន្ថែមទាក់ទងនឹងវិធីសាស្ត្រក្នុងការស្រាវជ្រាវ ចងក្រង រៀបចំ និងដកស្រង់នូវឯកសារផ្សេងៗឡើង ដើម្បីសរសេរជាសៀវភៅ
    - ធ្វើឲ្យទទួលចំណេះដឹងបន្ថែមទាក់ទងនឹងប្រធានបទដែលក្រុមរបស់យើងបានធ្វើការស្រាវជ្រាវ
    - ជួយពង្រឹងសមត្ថភាពរបស់ក្រុមយើងខ្ញុំឲ្យប្រសើរឡើងមួយកម្រិតទៀត
    - ធ្វើឲ្យយើងបានដឹងអំពីស្ថានភាពអតិផរណានៅក្នុងប្រទេស និងប្រទេសថៃ រួមទាំងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនៃប្រទេសទាំងពីរក្នុងការដោះស្រាយពេលមានវិបត្តិអតិផរណាកើតមានឡើងម្តងៗ។
- **ចំពោះសិស្សនិស្សិត**
    - កិច្ចសារស្រាវជ្រាវសារណាមួយនេះ នឹងជួយជាចំណែកដល់សិស្សានុសិស្សក្នុងការសិក្សាស្រាវជ្រាវបន្ថែម ដែលពាក់ព័ន្ធនឹងស្ថានភាពអតិផរណា
    - កិច្ចសារស្រាវជ្រាវសារណាមួយនេះ នឹងក្លាយជាគំរូមួយដល់សិស្សនិស្សិតក្រោយឲ្យបន្តយកចិត្តទុកដាក់ និងខិតខំលើការស្រាវជ្រាវឲ្យបានច្រើន
    - កិច្ចការស្រាវជ្រាវមួយនេះ នឹងជួយលើកទឹកចិត្តដល់សិស្សនិស្សិតយកចិត្តទុកដាក់តាមដានអំពីស្ថានភាពសេដ្ឋកិច្ចរបស់ជាតិ រួមទាំងបញ្ហាដែលកើតមានឡើងផងដែរ ក្នុងនោះដូចជាបញ្ហាអតិផរណាជាដើម។ មិនដែលប៉ុណ្ណោះ តាមដានអំពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសជិតខាង ព្រោះថា ប្រទេសកម្ពុជាយើង ជាប្រទេសដែលនាំចូលទំនិញពីប្រទេសជិតខាងច្រើនជាងនាំចេញ។

- **ចំពោះសង្គម**
    - កិច្ចការស្រាវជ្រាវមួយនេះ នឹងបានចូលរួមជាចំណែកក្នុងការលើកកម្ពស់ពីការតាមដានអំពីស្ថានភាពសេដ្ឋកិច្ចរបស់ជាតិ
    - ជាពិសេសនោះ គឺក្នុងកិច្ចការស្រាវជ្រាវនេះ នឹងលើកយកនូវដំណោះស្រាយរបស់រដ្ឋាភិបាល ក៏ដូចជាយុទ្ធសាស្ត្រដែលធ្លាប់បានអនុវត្តន៍ពេលមានវិបត្តិអតិផរណាកើតមានឡើង
    - កិច្ចការស្រាវជ្រាវមួយនេះ នឹងជួយឲ្យពលរដ្ឋដែលរស់នៅក្នុងសង្គម យកចិត្តទុកដាក់តាមដានពីបញ្ហាដែលកើតមានឡើងក្នុងសង្គម ដូចជាបញ្ហាអតិផរណាជាដើម ព្រោះវាអាចងាយនឹងជះឥទ្ធិពលដល់អ្នកដែលមានចំណូលមធ្យម ឬចំណូលទាប។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

## សេចក្តីផ្តើម

នៅក្នុងសេចក្តីនេះក្រុមយើងខ្ញុំនឹងបង្ហាញអំពី: ១.លំនាំបញ្ហានៃការស្រាវជ្រាវ, ២.ចំណោទបញ្ហានៃការស្រាវជ្រាវ ៣. គោលបំណងនៃការស្រាវជ្រាវ ៤. វិធីសាស្ត្រនៃការស្រាវជ្រាវ, ៥. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ, ៦. សារៈសំខាន់នៃការស្រាវជ្រាវ, ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

## ជំពូកទី ១ រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងអតិផរណា

នៅក្នុងជំពូកទី ១ នេះ យើងនឹងធ្វើការបកស្រាយ រំពឹកអំពីទ្រឹស្តីទូទៅដែលពាក់ព័ន្ធនឹងអតិផរណាដូចជានិយមន័យរបស់អតិផរណា, ប្រភេទរបស់អតិផរណា, មូលហេតុនៃអតិផរណា, ឥទ្ធពិលនៃអតិផរណាមកលើសេដ្ឋកិច្ច, និងការគណនារកអត្រានៃអតិផរណា។

## ជំពូកទី ២ ស្ថានភាពអតិផរណានៃប្រទេសកម្ពុជា

នៅក្នុងជំពូកទី ២ នេះ គឺក្រុមយើងខ្ញុំនឹងធ្វើការបកស្រាយអំពីការប្រែប្រួលនៃអត្រាអតិផរណារបស់ប្រទេសកម្ពុជា ដោយគិតចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២១ ដោយក្នុងនោះ ក៏បានរួមបញ្ចូលទាំង ស្ថានភាពនៃអតិផរណាតាមឆ្នាំនីមួយៗដោយបង្ហាញជាតារាង កត្តាជះឥទ្ធិពលរបស់វាមកលើសេដ្ឋកិច្ច និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ដែលធ្លាប់បានអនុវត្តន៍ក្នុងការដោះស្រាយនៅពេលដែលមានអតិផរណាកើតឡើង។

## ជំពូកទី ៣ ស្ថានភាពអតិផរណានៃប្រទេសថៃ

នៅក្នុងជំពូកទី ៣ នេះ យើងធ្វើបកស្រាយអំពីស្ថានភាពនៃអត្រាអតិផរណានៅក្នុងប្រទេសថៃ ដោយដែនកំណត់របស់វា គឺចាប់ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០២១។ ដោយក្នុងនោះ យើងក៏លើកយកនូវមូលហេតុដែលនាំឲ្យកើតមានឡើងនូវអតិផរណាក្នុងប្រទេសថៃ រួមទាំងយុទ្ធសាស្ត្រ ក៏ដូចជាវិធីសាស្ត្រដែលរដ្ឋាភិបាលថៃធ្លាប់បានអនុវត្តន៍ក្នុងការដោះស្រាយបញ្ហាអតិផរណានេះ។

## ជំពូកទី ៤ ការពិភាក្សា វិភាគ ប្រៀបធៀបទៅលើការវិវត្តនៃអត្រាអតិផរណារបស់ប្រទេសកម្ពុជា និងថៃ

ក្នុងជំពូកទី ៤ នេះ ក្រុមយើងខ្ញុំនឹងធ្វើការពិភាក្សា វិភាគទៅការវិវត្តនៃអត្រាអតិផរណានៃប្រទេសទាំងពីរតាមចន្លោះឆ្នាំនីមួយៗ។ បន្ថែមលើសពីនេះទៀត យើងក៏ធ្វើការប្រៀបធៀបទៅលើការវិវត្តនៃអត្រាអតិផរណារនៃប្រទេសកម្ពុជា និងថៃផងដែរ។

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ឯកសារយោង

## បញ្ជីឧបសម្ព័ន្ធ

# ជំពូកទី ១

# រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងអតិផរណា

# ជំពូកទី ១
# រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងអតិផរណា

នៅក្នុងជំពូកទី ១ នេះ គឺយើងនឹងធ្វើការបកស្រាយពីទ្រឹស្តីទូទៅដែលពាក់ព័ន្ធនឹងអតិផរណា ដោយក្នុងនោះរួមមានដូចជា ការកំណត់និយមន័យនៃអតិផរណា, ប្រភេទនៃអតិផរណា, មូលហេតុនៃអតិផរណា, ឥទ្ធិពលនៃអតិផរណាមកលើសេដ្ឋកិច្ច, និងការគណនារកអត្រាអតិផរណា។

## ១.១ និយមន័យនៃអតិផរណា

- អតិផរណា គឺជាការកើនឡើងកម្រិតថ្លៃជាទូទៅនៃទំនិញនិងសេវាក្នុងសេដ្ឋកិច្ច ។ អតិផរណាត្រូវបានគណនាជាភាគរយ និង វាស់វែងកំណើនជា ខែ ត្រីមាស និង ឆ្នាំ[1]។
- អតិផរណា គឺសំដៅដល់ការកើនឡើងនៃថ្លៃទំនិញជារួមនៅក្នុងសេដ្ឋកិច្ចនៅក្នុងរយៈពេលជាក់លាក់មួយ ឬសំដៅដល់ការបាត់បង់អំណាចទិញរបស់រូបិយវត្ថុរបស់ប្រទេសមួយនៅក្នុងពេលណាមួយ។ វាអាចកើតឡើង ដោយសារតែកត្តាជាច្រើន ដូចជា ថ្លៃដើមកើនឡើង តម្រូវការកើនឡើងខ្លាំង ការរំពឹងទុករបស់អ្នកប្រើប្រាស់ជាដើម[2]។
- អតិផរណា ត្រូវបានកំណត់និយ័មថា ជាការកើនឡើងនៃតម្លៃរស់នៅ (Cost of living) ដោយសារតែតម្លៃទំនិញ និងសេវាកម្មប្រើប្រាស់ប្រចាំថ្ងៃទូទៅមួយចំនួន ដូចជា អាហារ ការដឹកជញ្ជូន សម្លៀកបំពាក់ សម្ភារៈប្រើប្រាស់ជាដើមមានការកើនឡើង។ ការកើនឡើងនៃកម្រិតតម្លៃទូទៅនៅក្នុងសេដ្ឋកិច្ចមួយបណ្ដាលឲ្យមានការថយចុះនៃអំណាចទិញរបស់រូបិយវត្ថុទៅតាមពេលវេលា[3]។

## ១.២ ប្រភេទនៃអតិផរណា

ប្រភេទនៃអតិផរណា ត្រូវបានបែងចែកចេញជា ៤ ប្រភេទ[4] ដូចខាងក្រោមនេះ៖

- **Creeping Inflation:** ជាប្រភេទអតិផរណាមួយ ដែលកើនឡើងយឺតៗទៅតាមពេលវេលា។ ជាទូទៅ វាកើនឡើងប្រមាណ ៣% ឬតិចជាងនេះ ក្នុងមួយឆ្នាំ។ Creeping Inflation ជាទូទៅមិនត្រូវបានគេចាប់អារម្មណ៍ ឬសម្គាល់ឃើញភ្លាមៗនោះទេ ដោយសារវាត្រូវបានគេចាត់ទុកថាពុំសូវមានហានិភ័យ ឬគ្រោះថ្នាក់ ប៉ុន្តែប្រសិនបើវាកើនឡើងជាបន្តបន្ទាប់ នោះវាអាចនឹងមានបញ្ហាកើតឡើងចំពោះសេដ្ឋកិច្ច។

[1] ដកស្រង់ចេញពីវាក្យស័ព្ទធនាគាររបស់ធនាគារជាតិនៃកម្ពុជា តាមរយៈគេហទំព័រដូចខាងក្រោម (https://www.nbc.org.kh/about_the_bank/banking_terms.php)

[2] គេហទំព័រ https://www.facebook.com/CambonomicTimes/posts/414904180170401/

[3] https://moneyclubber.com/blog/inflation/

[4] https://www.thebalance.com/types-of-inflation-4-different-types-plus-more-3306109

- **Moderate Inflation:** ជាអតិផរណាដែលអត្រារបស់វាស្ថិតនៅចន្លោះពី ៣% ទៅ ១០% ក្នុងមួយឆ្នាំ។ ប៉ុន្តែអតិផរណាប្រភេទនេះ គឺវាបង្កជាផលអាក្រក់ដល់សេដ្ឋកិច្ចយ៉ាងខ្លាំង ព្រោះវាអាចធ្វើឲ្យសេដ្ឋកិច្ចឡើងកម្តៅកាន់តែខ្លាំង។ ឧទាហរណ៍៖ មនុស្សចាប់ផ្តើមនាំគ្នាទៅទិញទំនិញស្តុកទុកកាន់តែច្រើន ដើម្បីចៀសវាងការឡើងថ្លៃទំនិញនាពេលខាងមុខដ៏ខ្លី ដែលព្រឹត្តិការណ៍នេះហើយ អាចបង្កជាផលលំបាកដល់អ្នកផ្គត់ផ្គង់។
- **Galloping Inflation:** សំដៅលើប្រភេទអតិផរណាដែលអត្រារបស់វាកើនចន្លោះពី ១០% ឬក៏ច្រើនជាងនេះ។ អត្រាកំណើនដ៏លឿន និងខ្ពស់បែបនេះហើយ ដែលវាបង្កឲ្យមានបញ្ហាដល់សេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ និងប៉ះពាល់ដោយផ្ទាល់ដល់អ្នកប្រើប្រាស់។
- **Hyperinflation:** ជាប្រភេទអតិផរណា ដែលកើតឡើងនៅពេលដែលថ្លៃទំនិញកើនឡើងខ្ពស់ ច្រើនជាង ៥០% ក្នុងមួយខែ។ ជាឧទាហរណ៍ជាក់ស្តែងលើអតិផរណាប្រភេទនេះ គឺកើតមានឡើងនៅក្នុងពេលដែលរដ្ឋាភិបាលនៃប្រទេសមួយបោះពុម្ពលុយដើម្បីចំណាយសម្រាប់ធ្វើសង្គ្រាម ឬសងបំណុលនៅពេលចាញ់សង្គ្រាម ដូចជា ប្រទេសអាល្លឺម៉ង់ នៅក្នុងឆ្នាំ១៩២០, ហ្ស៊ីមបាវេ នៅក្នុងឆ្នាំ២០០០ និង ប្រទេសវេណេស៊ុយអេឡា នៅក្នុងឆ្នាំ២០១០ ដោយប្រទេសទាំងនេះ សុទ្ធតែធ្លាប់ឆ្លងកាត់អតិផរណាប្រភេទនេះ។

## ១.៣ មូលហេតុនៃអតិផរណា

អតិផរណាបានត្រូវបានចែកចេញជា ៣ ប្រភេទធំៗ គឺ៖ អតិផរណាដែលបណ្តាលមកពីកំណើននៃតម្រូវការ អតិផរណាដែលបណ្តាលមកពីការកើនឡើងនៃថ្លៃដើម និង អតិផរណាវដ្តសង្សារ ដែលបណ្តាលមកពីអន្តរប្រតិសកម្មរវាងថ្លៃដើម និងការឡើងថ្លៃទំនិញជារួម[5]។

- **អតិផរណាដែលបណ្តាលមកពីកំណើននៃតម្រូវការ៖** ជាអតិផរណាដែលបណ្តាលមកពីការកើនឡើងនៃតម្រូវការសរុប ដោយសារការផ្គត់ផ្គង់រូបិយវត្ថុកើនឡើង ហើយផ្នែកឯកជន និងរដ្ឋបង្កើនចំណាយរបស់ខ្លួន។ ការកើនឡើងនៃតម្រូវការទំនិញ និងសេវាកម្មទាំងអស់ (ឬហៅថាតម្រូវការសរុប) គឺជាកត្តាដែល «ទាញ» តម្លៃទំនិញ និងសេវាកម្មសព្វសារពើឲ្យឡើងថ្លៃ ជាពិសេសនៅពេលដែលចំនួនផ្គត់ផ្គង់សរុបមិនអាចកើនឡើងបានដោយសារសមត្ថភាពផ្គត់ផ្គង់នៅមានកម្រិត។ នៅក្នុងចំណុចសំខាន់នៃទ្រឹស្តីអតិផរណាដែលបណ្តាលមកពីកំណើនតម្រូវ គឺផ្តោតទៅលើការផ្គត់ផ្គង់រូបិយវត្ថុ ពោល គឺអតិផរណា

[5] សៀវភៅម៉ាក្រូសេដ្ឋកិច្ចរបស់បណ្ឌិត ហង់ ជួន ណារ៉ុង ឆ្នាំ២០០៩, ទំព័រ ៣៦

ដែលបណ្តាលមកពីចំនួនរូបិយវត្ថុធ្វើចរាចរនៅលើទីផ្សារកើនឡើងធៀបនឹងសមត្ថភាពផ្គត់ផ្គង់សរុបរបស់សេដ្ឋកិច្ច។

- **អតិផរណាបណ្តាលមកពីកំណើនថ្លៃដើម៖** ជាអតិផរណា ដែលបណ្តាលមកពីការធ្លាក់ចុះយ៉ាងខ្លាំងនៃបរិមាណផ្គត់ផ្គង់សរុប ដោយសារតម្លៃធាតុចូលសម្រាប់ផលិតកម្មកើនឡើង។ កត្តាជំរុញថ្លៃដើមមួយចំនួន ដូចជា ប្រេង ស្បៀង ឬ ថ្លៃឈ្នួលអាចបង្កើនកម្រិតតម្លៃទំនិញទូទៅ។ ផលិតករ ដែលត្រូវបង់ថ្លៃដើមនៃធាតុចូលខ្ពស់នឹងបញ្ជូនបន្ទុកនេះបន្តទៅឲ្យអតិថិជន ដោយវិធីបង្កើនតម្លៃធាតុចេញ ឬទំនិញលើទីផ្សារ។
- **វដ្តអតិផរណា៖** គឺបណ្តាលមកពីការរំពឹងគិតទៅពេលអនាគត ដោយផ្អែកលើស្ថានភាពបច្ចុប្បន្ន ដោយភាគច្រើនគឺផ្សារភ្ជាប់ទៅនឹង «វដ្តសង្សារនៃដំណើរប្រតិសកម្មទៅវិញទៅមក រវាងថ្លៃទំនិញ និង ប្រាក់បៀវត្ស»។ ដោយសារអតិផរណាកើនឡើងជាប្រចាំ និយោជិតទាមទារតម្លើងប្រាក់បៀវត្សរបស់ខ្លួន ដើម្បីទប់ទល់នឹងថ្លៃទំនិញ ដែលចេះតែកើនឡើងឥតឈប់ឈរ (ដោយប្រាក់បៀវត្សដុល ត្រូវតែកើនលើសសន្ទស្សន៍ថ្លៃទំនិញ ដើម្បីធ្វើឲ្យប្រាក់បៀវត្សសុទ្ធមានកម្រិតសមស្រប ជាមួយនឹងសន្ទស្សន៍ថ្លៃទំនិញបន្ទាប់ពីដកពន្ធចេញ) ហើយនិយោជកបញ្ចូលថ្លៃទំនិញ ដែលជាផ្នែកមួយនៃវដ្តសង្សារនៃដំណើរការប្រតិសកម្មបន្ថែមគ្នាទៅវិញទៅមករវាងអតិផរណា និងប្រាក់បៀវត្ស។ អតិផរណាវដ្តសង្សារបង្ហាញពីព្រឹត្តិការណ៍ក្នុងអតីតកាល ដូចនេះគេអាចទុកវាជាអតិផរណាដែលវិលចុះវិលឡើង។

## ១.៤ ឥទ្ធិពលនៃអតិផរណាមកលើសេដ្ឋកិច្ច

### ១.៤.១ ផលវិជ្ជមាន

ខាងក្រោមនេះ ជាផលវិជ្ជមាននៃអតិផរណាមកលើសេដ្ឋកិច្ច[6]៖

- **ជួយដល់កូនបំណុល៖** អតិផរណា ផ្តល់ផលប៉ះពាល់ដល់ម្ចាស់បំណុល ប៉ុន្តែវាបានផ្តល់ផលវិជ្ជមានដល់កូនបំណុល ដោយសារតែមានការប្រែប្រួលលើអត្រាការប្រាក់ពិត (Real Interest Rate)។ ឧទាហរណ៍ កិច្ចព្រមព្រៀងមួយលើកិច្ចសន្យាខ្ចីប្រាក់ពីធនាគារ ភាគីទាំងសងខាងបានព្រមព្រៀងគ្នាថាអត្រាការប្រាក់ក្នុងមួយឆ្នាំ គឺ ៣% ដោយក្នុងនោះ ម្ចាស់បំណុលសង្ឃឹមថានឹងទទួលបានអត្រា ៣% នៅឆ្នាំបន្ទាប់។ នៅក្នុងឆ្នាំបន្ទាប់ កូនបំណុលបានបង់ប្រាក់ដើម និងអត្រាការប្រាក់ទៅឲ្យម្ចាស់បំណុល ក្នុងអត្រា ៣% ដែលស្ថិតក្នុងអតិផរណាប្រចាំឆ្នាំ ២% ទៅឲ្យម្ចាស់បំណុល។

[6] ដកស្រង់ចេញពីគេហទំព័រ (psndaily.wixsite.com)

$$\text{Real interest rate} = \text{Nominal interest rate} - \text{Inflation rate}$$

ដូចនេះ មានន័យថា ម្ចាស់បំណុលទទួលបានអត្រាការប្រាក់ពិតត្រឹមតែ ១% តែប៉ុណ្ណោះ ដោយអ្នកដែលទទួលផលចំណេញ គឺកូនបំណុល។

- **ជួយបង្កើនតម្រូវការក្នុងរយៈពេលខ្លី៖** នៅពេលដែលអតិផរណាមានកំណើន អ្នកប្រើប្រាស់រំពឹងថាថ្លៃទំនិញនឹងមានការប្រែប្រួលនៅថ្ងៃអនាគត។ ដូចនេះ អ្នកប្រើប្រាស់នឹងទិញទំនិញច្រើនជាងការចំណាយប្រចាំថ្ងៃរបស់ពួកគេ។ ជាលទ្ធផល ម្ចាស់សហគ្រាសដែលជាអ្នកផ្គត់ផ្គង់មានលទ្ធភាពផលិតទំនិញរបស់ខ្លួន ដើម្បីផ្គត់ផ្គង់លើទីផ្សារឲ្យកាន់បានតែច្រើនក្នុងគោលបំណងបំពេញទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់។
- **ជួយជំរុញសេដ្ឋកិច្ចឲ្យរីកចម្រើន៖** មូលហេតុមួយរបស់អតិផរណា គឺនៅពេលដែលបរិមាណតម្រូវការរបស់អ្នកប្រើប្រាស់ច្រើនជាងបរិមាណផ្គត់ផ្គង់នៅលើទីផ្សារ ដែលនាំឲ្យតម្លៃរបស់ទំនិញ ឬសេវាកម្មមានការប្រែប្រួលខ្លាំង។ នៅក្នុងពេលនោះហើយដែលម្ចាស់សហគ្រាសជាអ្នកផ្គត់ផ្គង់ខិតខំបង្កើនការផលិតទំនិញរបស់ខ្លួន ដើម្បីបំពេញទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់នៅលើទីផ្សារ។ ដំណើរការផលិតកាន់តែច្រើនរបស់សហគ្រាស នឹងធ្វើឲ្យការលក់ទំនិញនៅលើទីផ្សារកើនឡើងបានកាន់តែច្រើនស្រប ទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់។ នេះជាកត្តាដែលធ្វើឲ្យអ្នកវិនិយោគទទួលបានផលចំណេញច្រើន និងបន្តផលិតទំនិញកាន់តែច្រើនទៀតនៅលើទីផ្សារ ហើយរដ្ឋក៏មានលទ្ធភាពប្រមូលពន្ធបានច្រើនផងដែរ ដោយផ្អែកលើកំណើនផលិតរបស់សហគ្រាស។
- **បង្កើនការវិនិយោគ៖** វាជាឱកាសរបស់អ្នកវិនិយោគក្នុងការបណ្តាក់ទុនបន្ថែមលើការផលិតទំនិញ នៅពេលដែលបរិមាណតម្រូវការកើនឡើងខ្ពស់លើទីផ្សារ ព្រោះនៅពេលដែលអត្រាអតិផរណាកើនឡើង នោះថ្លៃទំនិញ ឬសេវាកម្មដែលគេផ្គត់ផ្គង់នៅលើទីផ្សារ គឺមានតម្លៃខ្ពស់ជាងធម្មតា។ តម្លៃទំនិញខ្ពស់ជាងធម្មតានេះហើយ ដែលជាឱកាសសម្រាប់អ្នកវិនិយោគក្នុងការទទួលបានផលចំណេញខ្ពស់ ហើយក៏ជាមូលហេតុដែលនាំឲ្យវិនិយោគិនបន្តដាក់ទុនកាន់តែច្រើន រួមទាំងអាចទាក់ទាញវិនិយោគិនថ្មីៗ។
- **ឱកាសការងារដល់ប្រជាជន៖** នៅពេលដែលប្រទេសមួយ មានការវិនិយោគកើនឡើង នោះវាក៏បានរួមចំណែកក្នុងការផ្តល់ឱកាសការងារដល់ប្រជាជននៅក្នុងប្រទេសនោះផងដែរ។ ឧទាហរណ៍ជាក់ស្តែង ពេលដែលសហគ្រាសមួយបង្កើនការផលិតទំនិញ ឬសេវាកម្ម សហគ្រាសត្រូវតែមានកម្លាំងពលកម្មច្រើនជាងមុន ដើម្បីបន្លឿនដំណើរការផលិតរបស់ខ្លួន ដើម្បីផ្គត់ផ្គង់ទំនិញ ឬសេវាកម្មនៅលើទីផ្សារ។

ដូចនេះ សហគ្រាសនឹងបង្កើនចំនួនអ្នកធ្វើការបន្ថែម ដែលនេះជាកត្តាជួយឲ្យប្រជាជនមានការងារធ្វើច្រើន និងជួយឲ្យប្រជាជនបង្កើនប្រាក់ចំណូល។ ហើយនៅពេលដែលប្រជាជនមានប្រាក់ចំណូលកើនឡើង តម្រូវការក្នុងការប្រើប្រាស់ទំនិញ និងសេវាកម្មរបស់ពួកគេក៏កើនឡើងដូចគ្នា ដែលទាមទារឲ្យសហគ្រាសមានការផលិត ឬការផ្គត់ផ្គង់កាន់តែកើនឡើងស្របតាមតម្រូវការ។

### ១.៤.២ ផលអវិជ្ជមាន

ចំពោះ ផ្ទុយទៅវិញ ចេះ: ថ្វីត្បិតតែអតិផរណា បានផ្ដល់ផលវិជ្ជមានមួយចំនួនដល់សេដ្ឋកិច្ចក៏ដោយ ក៏យើងមើលឃើញពីការជះឥទ្ធិពលអវិជ្ជមានរបស់អតិផរណាមកលើសេដ្ឋកិច្ចទាំងមូលដូចគ្នា ដោយក្នុងនោះរួមមាន ការឡើងថ្លៃទៅលើម្ហូបអាហារ ថ្លៃដឹកជញ្ជូន ប្រេងសាំង និង ថ្លៃទំនិញ និងសេវាកម្មដទៃទៀតផងដែរ។ នេះបង្ហាញពីការប៉ះពាល់យ៉ាងខ្លាំងដល់អំណាចទិញរបស់អ្នកប្រើប្រាស់ ហើយវាក៏ជះឥទ្ធិពលគ្រប់ជ្រុងនៃការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនទូទៅ ដូចជាការសន្សំរយៈពេលទៅថ្ងៃអនាគតផងដែរ។

ខាងក្រោមនេះ ជាផលអវិជ្ជមាននៃអតិផរណា៖

- **ប៉ះពាល់ដល់អ្នកសន្សំ៖** អតិផរណា ធ្វើឲ្យថ្លៃទំនិញមានការកើនឡើង និងតម្លៃនៃរូបិយវត្ថុធ្លាក់ចុះទៅតាមពេលវេលា។ ហេតុនេះហើយ ទើបការកើតមានឡើងនៃអតិផរណា មានផលប៉ះពាល់ខ្លាំងដល់អ្នកសន្សំគ្រប់គ្នា មិនថាការសន្សំនោះស្ថិតក្នុងរូបភាពណានោះទេ។ ឧទាហរណ៍ថា នៅក្នុងឆ្នាំ១៩៩០ តម្លៃលុយ ១ ដោន អាចទិញបាននំប៉័ងចំនួនពីរដើម ប៉ុន្តែនៅក្នុងឆ្នាំ២០២០ តម្លៃលុយ ១ ដោន ដដែល អាចទិញបាននំប៉័ងតែមួយដើមនោះទេ[7]។ ឧទាហរណ៍ក្នុងករណីមួយទៀត យើងយកលុយទៅសន្សំនឹងធនាគារដោយទទួលបានអត្រាការប្រាក់ ១% ក្នុងមួយឆ្នាំ ដោយឆ្នាំក្រោយលុយរបស់យើងនឹងកើនឡើង ១% បន្ថែម។ ប៉ុន្តែ ប្រសិនបើអត្រាអតិផរណាកើនឡើងខ្ពស់ជាង ១% ក្នុងឆ្នាំដែលយើងសន្សំ ទោះបីជាលុយរបស់យើងកើនឡើងបន្ថែម ១% ក៏ដោយ តែអត្រាអតិផរណានឹងធ្វើឲ្យលុយរបស់យើងធ្លាក់ថ្លៃ[8]។
- **ប៉ះពាល់ដល់បុគ្គលិក និងកម្មករ៖** បុគ្គលិក និងកម្មករ ជាក្រុមមនុស្សដែលទទួលបានប្រាក់ចំណូលថេរ (ប្រាក់ខែ) ដូចនេះហើយ ពួកគេងាយទទួលរងឥទ្ធិពលពីអតិផរណា ព្រោះថាអតិផរណាធ្វើឲ្យតម្លៃទំនិញ និងសេវាកម្មមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ។ ការប្រែប្រួលនៃតម្លៃទំនិញ និងសេវាកម្មនេះហើយ ដែលធ្វើឲ្យអំណាចទិញរបស់ក្រុមមនុស្សទទួលបានប្រាក់ចំណូលថេរមានការធ្លាក់ចុះ។

[7] https://www.moneyhelper.org.uk/en/savings/how-to-save/inflation-what-the-saver-needs-to-know

[8] https://www.moneyhelper.org.uk/en/savings/how-to-save/inflation-what-the-saver-needs-to-know

- **ប៉ះពាល់ដល់ម្ចាស់បំណុល៖** យើងបានដឹងរួចមកហើយថា អតិផរណាបានផ្តល់ផលចំណេញដល់កូនបំណុល ព្រោះវាបានធ្វើឲ្យតម្លៃលុយពិតធ្លាក់ចុះ ដែលជាមូលហេតុធ្វើឲ្យមានការខាត់បង់ដល់ម្ចាស់បំណុល។ ឧបមាថាម្ចាស់បំណុលបានផ្តល់លុយឲ្យកូនបំណុលខ្ចីចំនួន ១០,០០០ ដុល្លារ ក្នុងរយៈពេលមួយឆ្នាំទៀតត្រូវសងត្រឡប់មកវិញ។ បើសិនជាថ្លៃកើនឡើងរហូតដល់ទៅ ១០% ក្នុងចន្លោះពេលនោះ នាំឲ្យលុយរបស់ម្ចាស់បំណុលដែលទទួលបានត្រឡប់មកវិញមានតម្លៃតិចជាងមុន។
- **ប៉ះពាល់ជីវភាពរស់នៅរបស់ប្រជាជន៖** អតិផរណា គឺមានន័យថាថ្លៃទំនិញ ឬសេវាកម្មមានការកើនឡើងជាងមុន នេះបញ្ជាក់ពីការធ្លាក់ចុះនៃអំណាចទិញរបស់អ្នកប្រើប្រាស់ ព្រោះថាចំនួនលុយដដែល ប៉ុន្តែទិញបានបរិមាណទំនិញ ឬសេវាកម្មតិចជាងមុន។ ត្រង់កន្លែងនេះ យើងមើលឃើញថា អ្នកដែលទទួលរងឥទ្ធិពលខ្លាំងនៅពេលដែលមានអតិផរណា គឺអ្នកដែលទទួលបានចំណូលថេរ ឬក្រុមមនុស្សដែលចូលនិវត្តន៍។ នៅពេលដែលចំណូលរបស់ក្រុមមនុស្សប្រភេទនេះថេរ ហើយថ្លៃទំនិញ ឬសេវាកម្មចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ នោះជីវភាពរស់នៅប្រចាំថ្ងៃនឹងមានផលលំបាក។
- **ប៉ះពាល់ដល់សេដ្ឋកិច្ចរយៈពេលវែង៖** ក្នុងករណីដែលអតិផរណាបន្តអូសបន្លាយក្នុងរយៈពេលវែង នោះវានឹងបង្កឲ្យមានបញ្ហាដល់សេដ្ឋកិច្ចក្នុងរយៈពេលវែងដូចគ្នា។ ក្នុងន័យនេះ គឺអាចមានរឿងពីរកើតឡើង ដោយទីមួយ អ្នកប្រើប្រាស់នឹងបន្ថយការចំណាយរបស់ខ្លួន ក្នុងហេតុផលអំណាចទិញរបស់ពួកគេថយចុះ ឬទិញបានទំនិញបានតិចជាងមុន ហើយទីពីរ ការផ្គត់ផ្គង់ទំនិញនៅលើទីផ្សារមានការធ្លាក់ចុះ ក្នុងហេតុផលតម្រូវបានការធ្លាក់ចុះ។ កត្តាទាំងនេះហើយ ដែលធ្វើឲ្យសហគ្រិនខាតបង់ចំណូល ហើយតម្រូវឲ្យមានការកាត់បន្ថយបុគ្គលិក ក្នុងហេតុផលទំហំផលិតកម្មរបស់ខ្លួនមានការធ្លាក់ចុះ។ ដូចនេះកម្រិតវិនិយោគមានការធ្លាក់ចុះ រីឯមនុស្សមួយចំនួនក៏បាត់បង់ការងារធ្វើ។
- **ធ្លាក់ចុះភាពប្រកួតប្រជែងនៃទំនិញលើទីផ្សារ៖** សព្វថ្ងៃ រាល់បណ្តាប្រទេសជាច្រើនខិតខំប្រឹងប្រែងនាំចេញផលិតផលរបស់ខ្លួនចូលទៅកាន់ទីផ្សាររបស់ប្រទេសដទៃទៀត ដើម្បីដណ្តើមយកចំណែកទីផ្សារប្រកួតប្រជែងជាមួយនឹងផលិតផលរបស់ប្រទេសដទៃផ្សេងទៀត។ ប្រសិនបើសេដ្ឋកិច្ចនៃប្រទេសមួយមានអតិផរណា នោះថ្លៃទំនិញរបស់ប្រទេសនោះនឹងមានការកើនឡើងខ្ពស់ជាងធម្មតា ដែលជាហេតុនាំឲ្យពួកគេពិបាកក្នុងការនាំយកនូវផលិតផលរបស់ខ្លួនយកទៅប្រកួតប្រជែងនឹងផលិតផលរបស់ប្រទេសដទៃ ដែលដាក់លក់ក្នុងតម្លៃទាបជាង។ កត្តានេះហើយ ដែលធ្វើឲ្យសេដ្ឋកិច្ចនៃប្រទេសដែលកើតមានអតិផរណាមានការធ្លាក់ចុះ។

- **ប៉ះពាល់ដល់ការគ្រប់គ្រងអាជីវកម្ម៖** អតិផរណា គឺធ្វើឲ្យថ្លៃទំនិញ ឬសេវាកម្មមានការប្រែប្រួល ហើយប្រសិនបើអត្រាអតិផរណាមានការប្រែប្រួលខ្លាំងក្នុងរយៈពេលខ្លី នោះតម្រូវឲ្យម្ចាស់អាជីវកម្មមានការយកចិត្តទុកដាក់ និងតាមដានខ្ពស់ ដើម្បីឲ្យអាជីវកម្មរបស់ពួកគេនូវបន្តដំណើរការរលូន និងមិនមានការខាតបង់។ ជាក់ស្តែងក្នុងរយៈពេលប៉ុន្មានចុងក្រោយនេះ យើងឃើញថាការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈនៅក្នុងទីផ្សារនៃប្រទេសកម្ពុជាមានការប្រែប្រួលខ្លាំង ដោយសារតែបម្រែបម្រួលនៃតម្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ។ ដោយតម្លៃនៃប្រេងឥន្ធនៈបានប្រែប្រួលក្នុងរយៈពេលដ៏ខ្លី គឺ តម្លៃនៅចន្លោះថ្ងៃទី១១ ដល់ ២០ ខែមេសា គឺ ៥០៥០ រៀល ក្នុងមួយលីត ហើយ ចន្លោះថ្ងៃទី២១ ដល់ ៣០ ខែមេសា គឺ ៥១៥០ រៀល ក្នុងមួយលីត[9]។

## ១.៥ ការគណនាអត្រាអតិផរណា

អត្រាអតិផរណា កើតឡើងគ្រប់ប្រទេសទាំងអស់នៅលើសកលលោក ដោយគ្រាន់តែវាស្ថិតនៅក្នុងកម្រិតអត្រាផ្សេងៗគ្នា ហើយខ្ពស់ ឬទាបតែប៉ុណ្ណោះទៅតាមការខិតខំប្រឹងប្រែងរកវិធីសាស្ត្រក្នុងការគ្រប់គ្រងឲ្យបានល្អរបស់រដ្ឋាភិបាលនៃប្រទេសទាំងនោះ។ អតិផរណាក៏ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្ពស់ពីរាជរដ្ឋាភិបាលនៃប្រទេសនីមួយៗផងដែរ ព្រោះថាវាអាចបង្កជាហេតុអាក្រក់ដល់សេដ្ឋកិច្ចជាតិទាំងមូលបាន។ ហេតុដូចនេះហើយ ទើបបានជាអតិផរណាត្រូវបានគេធ្វើការវាស់វែង តាមដាន និងគ្រប់គ្រងវាយ៉ាងជាប់លាប់ ដែលក្នុងនោះគឺគេធ្វើការវាស់វែងវាដោយគណនាទៅជាភាគរយ តាមរយៈសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់។ ក្រៅពីប្រើប្រាស់សន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ យើងក៏អាចធ្វើការគណនារកអត្រាអតិផរណាតាមរយៈការប្រើប្រាស់រូបមន្ត GDP Deflator បានដូចគ្នា ដោយយើងនឹងនិយាយពីការគណនានេះនៅក្នុងចំណុចទី ១.៥.១.៥ (ផ្នែក ក និង ខ)។ ដោយការគណនាអត្រាអតិផរណា គឺជាភាគរយនៃការផ្លាស់ប្តូរនៅក្នុងកម្រិតថ្លៃនារយៈពេលមួយឆ្នាំ។

### ១.៥.១ ការគណនាសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ និង អត្រាអតិផរណា

ដើម្បីធ្វើការគណនារកអត្រាអតិផរណាបាន គឺយើងត្រូវស្គាល់ពីសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ និងយល់ដឹងពីវិធីសាស្ត្រក្នុងការគណនារកសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់។ សន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ (Consumer Price Index)[10] ជារង្វាស់នៃថ្លៃទំនិញ និងសេវាកម្មទូទៅ ដែលត្រូវបានទិញដោយអ្នកប្រើប្រាស់។

[9] https://www.phnompenhpost.com/business/regular-petrol-diesel-rates-set-5150-and-5500-riel

[10] Principles of Economics, Eighth Edition N. GREGORY MANKIW, Chapter 24 Measuring the cost of living, page 496, print year: 2016

**១.៥.១.១ ការកំណត់កន្ត្រកនៃសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់**

ត្រូវកំណត់ថា ប្រភេទទំនិញណាខ្លះ ដែលត្រូវបានដាក់បញ្ចូលទៅក្នុងកន្ត្រកនៃសន្ទស្សន៍ថ្លៃទំនិញ។ នៅក្នុងប្រទេសកម្ពុជា មានការបែងចែកប្រភេទទំនិញចំនួន ១២ ក្រុមក្នុងកន្ត្រកនៃសន្ទស្សន៍ថ្លៃទំនិញដូចខាងក្រោម[11]៖

១. អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង

២. ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់

៣. សម្លៀកបំពាក់ និងស្បែកជើង

៤. ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត

៥. គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់គ្រួសារ និងការថែទាំផ្ទះជាប្រចាំ

៦. សុខាភិបាល

៧. ការដឹកជញ្ជូន

៨. គមនាគមន៍

៩. ការកម្សាន្ត និងវប្បធម៌

១០. ការសិក្សា

១១. ភោជនីយដ្ឋាន

១២. ទំនិញ និងសេវាកម្មផ្សេងៗ

**១.៥.១.២ ស្វែងរកតម្លៃ**

ធ្វើការកំណត់ពីថ្លៃនៃទំនិញ និងសេវាកម្មណាមួយនៅក្នុងកន្ត្រកសម្រាប់ចំណុចនីមួយៗក្នុងពេលវេលាជាក់លាក់ណាមួយ។ នៅក្នុងប្រទេសកម្ពុជា គឺគេប្រមូលទិន្នន័យថ្លៃទំនិញ និងសេវាកម្មទាំង ១២ ក្រុមជាប្រចាំខែ ហើយគណនារកសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ប្រចាំខែដូចគ្នា។

**១.៥.១.៣ គណនាថ្លៃកន្ត្រកទំនិញ**

គេត្រូវប្រើប្រាស់ទិន្នន័យរបស់ថ្លៃទំនិញ ក្នុងការគណនាថ្លៃកន្ត្រកទំនិញ និងសេវាកម្មនៅត្រង់ពេលវេលាផ្សេងៗគ្នា ដោយដើម្បីធ្វើការគណនាថ្លៃកន្ត្រកទំនិញទៅបាន គឺតម្រូវឲ្យស្គាល់ពីថ្លៃទំនិញ ចំនួនបរិមាណទំនិញទៅតាមប្រភេទទំនិញនីមួយៗ និងធ្វើការបូកសរុបថ្លៃទំនិញ។

ឧទាហរណ៍៖ ខាងក្រោមនេះ គឺជាការគណនាស្វែងរកថ្លៃកន្ត្រកទំនិញនៅតាមឆ្នាំនីមួយៗដូចដែលបានបង្ហាញនៅក្នុង (តារាង ១.១) ដោយយោងទៅតាមទិន្នន័យជាក់ស្តែងដែលដកស្រង់ចេញពីតារាងតម្លៃ និងសេវា

[11] ដកស្រង់ចេញពីគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ (http://nis.gov.kh/index.php/km/20-cpi/31-cpi-tables)

ប្រចាំខែសម្រាប់ខែឧសភា ក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១, របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយដ្ឋានគោលនយោបាយ។

**(ក) តម្លៃគោលនៃកន្ត្រកថ្លៃទំនិញ ក្នុងខែឧសភា ឆ្នាំ២០២១**[12]

| ថ្លៃកន្ត្រកទំនិញ | | | តម្លៃសរុបនៃកន្ត្រកថ្លៃទំនិញ |
|---|---|---|---|
| **មុខទំនិញ** | **បរិមាណ** | **ថ្លៃក្នុងមួយឯកតា** | |
| អង្ករផ្កាខ្ញី បាត់ដំបង់ | ១ គីឡូ | ២៨៨០ ៛ | ២៨៨០ ៛ |
| អង្ករនាងមិញ បាត់ដំបង | ១ គីឡូ | ២៥០០ ៛ | ២៥០០ ៛ |
| អង្ករផ្កាម្លិះ | ១ គីឡូ | ៣៨០០ ៛ | ៣៨០០ ៛ |
| អង្ករផ្ការំដួល | ១ គីឡូ | ៤០៥០ ៛ | ៤០៥០ ៛ |
| តម្លៃគោលនៃកន្ត្រកថ្លៃទំនិញ | | | ១៣,២៣០ ៛ |

**(ខ) តម្លៃគោលនៃកន្ត្រកថ្លៃទំនិញ ក្នុងខែឧសភា ឆ្នាំ២០២០**[13]

| ថ្លៃកន្ត្រកទំនិញ | | | តម្លៃសរុបនៃកន្ត្រកថ្លៃទំនិញ |
|---|---|---|---|
| **មុខទំនិញ** | **បរិមាណ** | **ថ្លៃក្នុងមួយឯកតា** | |
| អង្ករផ្កាខ្ញី បាត់ដំបង់ | ១ គីឡូ | ៣០០០ ៛ | ៣០០០ ៛ |
| អង្ករនាងមិញ បាត់ដំបង | ១ គីឡូ | ៣៥០០ ៛ | ៣៥០០ ៛ |
| អង្ករផ្កាម្លិះ | ១ គីឡូ | ៣០០០ ៛ | ៣០០០ ៛ |
| អង្ករផ្ការំដួល | ១ គីឡូ | ៣៤០០ ៛ | ៣៤០០ ៛ |
| តម្លៃគោលនៃកន្ត្រកថ្លៃទំនិញ | | | ១២,៩០០ ៛ |

**១.៥.១.៤ ជ្រើសរើសឆ្នាំគោល និងគណនាសន្ទស្សន៍ថ្លៃ**

ដើម្បីធ្វើការគណនារកសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ គឺគេត្រូវស្គាល់នូវថ្លៃកន្ត្រកទំនិញក្នុងឆ្នាំគោល (Price of basket in base year) និងថ្លៃកន្ត្រកទំនិញក្នុងពេលបច្ចុប្បន្ន (Price of basket of goods and services in current year) ។

ដូច្នេះហើយ គេត្រូវធ្វើការកំណត់យកឆ្នាំណាមួយជាឆ្នាំគោល ដែលពោល គឺជាគោលទល់នឹងឆ្នាំផ្សេងទៀតដែលនឹងត្រូវយកមកប្រៀបធៀប។ (ដោយការជ្រើសរើសឆ្នាំគោល គឺយើងអាចរើសទៅតាមការចង់បាន

[12] តារាងតម្លៃ និងសេវាប្រចាំខែសម្រាប់ខែឧសភា ឆ្នាំ២០២១, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយដ្ឋានគោលនយោបាយ

[13] តារាងតម្លៃ និងសេវាប្រចាំខែសម្រាប់ខែឧសភា ឆ្នាំ២០២០, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយដ្ឋានគោលនយោបាយ

របស់យើង ដោយសារតែសន្ទស្សន៍នេះ ត្រូវបានគេប្រើប្រាស់ដើម្បីវាស់វែងអំពីការប្រែប្រួលជាភាគរយក្នុងថ្លៃទ្រទ្រង់នៃការរស់នៅ)។ ហើយនៅពេលដែលឆ្នាំគោលត្រូវបានជ្រើសរើសរួច សន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់នឹងត្រូវបានគណនាតាមរូបមន្ត[14]ដូចខាងក្រោម៖

$$\text{Consumer Price Index (CPI)} = \frac{\text{Price of basket of goods and services in current year}}{\text{Price of basket in base year}} \times 100$$

ថ្លៃនៃកន្ត្រកទំនិញ និងសេវាកម្មក្នុងឆ្នាំនីមួយៗត្រូវចែកជាមួយនឹងថ្លៃនៃកន្ត្រកទំនិញនៅក្នុងឆ្នាំគោល រួចហើយត្រូវគុណនឹង ១០០ ដោយលទ្ធផលដែលទទួលបាន គឺជាសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់។

ដោយយោងទៅតាមឧទាហរណ៍ (តារាង ១.១) ថ្លៃកន្ត្រកទំនិញក្នុងឆ្នាំ២០២០ គឺមានតម្លៃស្មើរ ១២,៩០០៛ នៃថ្លៃកន្ត្រកទំនិញ ហើយក្នុងឆ្នាំ២០២១ មានតម្លៃស្មើរ ១០,៩៨០៛។

ដោយយើងអាចធ្វើការគណនារក CPI ក្នុងឆ្នាំនីមួយៗបាន ដោយប្រើប្រាស់តម្លៃនៃកន្ត្រកទំនិញក្នុងឆ្នាំទាំងពីរខាងលើដែលយើងរកឃើញ៖

- CPI សន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ក្នុងខែឧសភា ឆ្នាំ២០២០

  $\text{CPI ក្នុងឆ្នាំ២០២០} = \frac{១២,៩០០}{១២,៩០០} \times ១០០ = ១០០$

- CPI សន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ក្នុងខែឧសភា ឆ្នាំ២០២០

  $\text{CPI ក្នុងឆ្នាំ២០២១} = \frac{១៣,២៣០}{១២,៩០០} \times ១០០ = ១០២.៥៦$

### ១.៥.១.៥ គណនាអត្រាអតិផរណា

#### ក. ការគណនាអត្រាអតិផរណាដោយប្រើសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់

ដើម្បីគណនារកអត្រាអតិផរណាបាន យើងត្រូវប្រើប្រាស់សន្ទស្សថ្លៃទំនិញអ្នកប្រើប្រាស់ ដែលជាបម្រែបម្រួលជាភាគរយនៅក្នុងសន្ទស្សន៍ថ្លៃ ចេញពីរយៈពេលមួយទៅរយៈពេលមួយទៀត។ គេត្រូវប្រើប្រាស់រូបមន្ត[15] ដូចខាងក្រោមនេះ ដើម្បីធ្វើការគណនារកអត្រាអតិផរណា៖

$$\text{Inflation Rate in year 2} = \frac{(\text{CPI in year 2} - \text{CPI in year 1})}{\text{CPI in year 1}} \times 100$$

[14] Principles of Economics Eighth Edition N. GREGORY MANKIW, Chapter 24 Measuring the cost of living, page 497, print year: 2016

[15] Principles of Economics Eighth Edition N. GREGORY MANKIW, Chapter 24 Measuring the cost of living, page 498, print year: 2016

ឧទាហរណ៍៖ ចូរធ្វើការគណនារកអត្រាអតិផរណានៅក្នុងឆ្នាំ២០២១ ដោយដឹងពី តម្លៃសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ក្នុងឆ្នាំ២០២០ មានតម្លៃស្មើ ១០០ និង សន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ក្នុងឆ្នាំ២០២១ មានតម្លៃស្មើ ១០២.៥៦។

ដំណោះស្រាយ

ដោយយើងស្គាល់៖ សន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ក្នុងឆ្នាំ២០២១ = ១០០

សន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ក្នុងឆ្នាំ២០២១ = ១០២.៥៦

$$\text{Inflation Rate in year 2021} = \frac{102.56 - 100}{100} \times 100 = 2.56\%$$

ដូចនេះ អត្រាអតិផរណានៅក្នុងឆ្នាំ២០២១ គឺ ២.៥៦%

**ខ. ការគណនាអត្រាអតិផរណាដោយប្រើ** GDP Deflator

ក្រៅពីគណនារកអត្រាអតិផរណាតាម សន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ (CPI) យើងក៏គណនារកអត្រាអតិផរណាដោយប្រើ GDP Deflator បានដូចគ្នា។

$$\text{GDP Deflator} = \frac{\text{Nominal GDP}}{\text{Real GDP}} \times 100$$

$$\text{Inflation Rate in year 2} = \frac{(\text{GDP Deflator in year 2} - \text{GDP Deflator in year 1})}{\text{GDP Deflator in year 1}} \times 100$$

ឧទាហរណ៍៖ តារាង ១.២

| ឆ្នាំ | Nominal GDP | Real GDP | GDP Deflator |
|---|---|---|---|
| ២០១៧ | $ 22,158,209,503 | $ 18,201,700,723 | 121.74 |
| ២០១៦ | $ 20,016,747,754 | $ 16,995,073,301 | 117.78 |

$$\text{Inflation Rate in year 2017} = \frac{(121.74 - 117.78)}{117.78} \times 100 = 3.3\%$$

ដូចនេះ អត្រាអតិផរណានៅឆ្នាំ ២០១៧ គឺ ៣.៣%

# ជំពូកទី ២

# ស្ថានភាពអតិផរណានៃប្រទេសកម្ពុជា

# ជំពូកទី ២

# ស្ថានភាពអតិផរណានៃប្រទេសកម្ពុជា

នៅក្នុងជំពូកទី ២ នេះផងដែរ គឺយើងនឹងធ្វើការសិក្សាស៊ីជម្រៅអំពីស្ថានភាពអតិផរណានៅក្នុងប្រទេសកម្ពុជា ដោយចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២១ ដោយក្នុងនោះ យើងនឹងធ្វើការបកស្រាយលម្អិតអំពីស្ថានភាពអតិផរណាតាមឆ្នាំនីមួយៗ, មូលហេតុនៃបម្រែបម្រួលអតិផរណានៅកម្ពុជា, ផលប៉ះពាល់ រួមទាំងយុទ្ធសាស្ត្រ និងដោះស្រាយរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ទៅលើបញ្ហាអតិផរណាផងដែរ។

## ២.១ ស្ថានភាពទូទៅនៃប្រទេសកម្ពុជា

អស់រយៈពេលជាងពីរទសវត្សមកហើយ ដែលប្រទេសកម្ពុជាមានការផ្លាស់ប្តូរមុខមាត់ប្រទេស ដោយធ្វើឲ្យប្រទេសមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ដែលក្នុងនោះបានសម្រេចជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥ ហើយប្រាថ្នាថានឹងសម្រេចឲ្យបានជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ ២០៣០។ ដោយក្នុងនោះ មានវិស័យនាំមុខដូចជា ការនាំចេញសម្លៀកបំពាក់ និងវិស័យទេសចរណ៍នេះហើយ ដែលជំរុញឲ្យសេដ្ឋកិច្ចរបស់កម្ពុជារក្សាបាននូវកំណើនជាមធ្យមចំនួន ៧.៧ ភាគរយក្នុងមួយឆ្នាំ ដោយនៅចន្លោះឆ្នាំ១៩៩៨ និងឆ្នាំ២០១៩ ដែលធ្វើឲ្យប្រទេសកម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសដែលសេដ្ឋកិច្ចមានកំណើនលឿនជាងគេនៅលើពិភពលោក[16]។

ជាអកុសល នៅក្នុងឆ្នាំ២០២០ ជាឆ្នាំដែលប្រទេសទូទាំងពិភពលោកបានជួបប្រទះនឹងវិបត្តិដែលបង្កដោយជំងឺឆ្លងកូវីដ ១៩ ហើយវិបត្តិនេះបានបង្កជាគ្រោះមហន្តរាយដល់សេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរដល់បណ្តាប្រទេសទាំងអស់ ក្នុងនោះប្រទេសកម្ពុជា ក៏ជាប្រទេសមួយដែលបានទទួលរងនូវឥទ្ធិពលយ៉ាងអាក្រក់ពីវិបត្តិជំងឺកូវីដ ១៩ នេះផងដែរ ដោយប៉ះពាល់ទៅដល់ផ្នែកធំៗទាំងបីនៃសេដ្ឋកិច្ចរបស់កម្ពុជា គឺវិស័យទេសចរណ៍ ការនាំចេញនៃកម្មន្តកម្ម និង វិស័យសំណង់។ វិស័យទាំងបីនេះហើយ ដែលបានរួមចំណែកជាង ៧០% នៃកំណើនសេដ្ឋកិច្ចរបស់ប្រទេស និងបានផ្តល់ការងារចំនួន ៣៩% នៃការងារមានប្រាក់ឈ្នួលទាំងអស់ក្នុងប្រទេស នៅក្នុងឆ្នាំ ២០១៩។ នៅក្នុងឆ្នាំ២០២០ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា មានកំណើនអវិជ្ជមានជាប្រវត្តិសាស្ត្រ ដោយស្ថិតក្នុងអត្រា - ៣.១% ដែលជាកំណត់ត្រាដ៏អាក្រក់បំផុតតាំងពីឆ្នាំ១៩៩៤ មក។

ក្នុងឆ្នាំ២០២១ សេដ្ឋកិច្ចកម្ពុជា ក៏បន្តទទួលរងផលប៉ះពាល់ពីជំងឺកូវីដ ១៩ ជាពិសេសដោយសារការអូសបន្លាយនៃការឆ្លងក្នុងសហគមរណ៍ ២០ កុម្ភៈ។ ប៉ុន្តែបើធៀបនឹងឆ្នាំ២០២០ កន្លងទៅ សកម្មភាពសេដ្ឋកិច្ចមានភាពល្អប្រសើរជាង ជាពិសេស ចាប់ពីឆមាសទី២ ឆ្នាំ២០២១ នេះមក។ ដោយសារការងើបមកវិញនៃ

[16] ដកស្រង់ចេញពីគេហទំព័រ www.worldbank.org/km/country/cambodia/overview#1

កំណើនសេដ្ឋកិច្ចពិភពលោក ជាពិសេសប្រទេសអភិវឌ្ឍន៍ដែលជាដៃគូពាណិជ្ជកម្មសំខាន់របស់កម្ពុជា ការសម្របខ្លួនទៅនឹងប្រក្រតីភាពថ្មី និងជោគជ័យនៃការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋរបស់រាជរដ្ឋាភិបាល បានធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាអាចសម្រេចបានកំណើនវិជ្ជមានវិញក្នុងអត្រា ៣% ក្នុងឆ្នាំ២០២១ បន្ទាប់ពីធ្លាក់ចុះ - ៣.១% កាលពីឆ្នាំកន្លងទៅ។ ក្នុងនោះ ផលិតផលកម្មន្តសាលសម្រាប់ឧស្សាហកម្មនាំចេញបានកើនឡើង ១២.៣% វិស័យសំណង់កើនឡើងបន្តិចក្នុងអត្រា ១.៤% ទន្ទឹមនឹងការងើបឡើងវិញនៃលំហូរទុនវិនិយោគបរទេស និងតម្រូវការក្នុងស្រុក វិស័យកសិកម្មបន្តមានវឌ្ឍនភាពល្អក្នុងអត្រាកំណើន ១.៤% ដោយសារវិធានការគាំទ្រផលិតកម្ម និងអំណោយផលពីអាកាសធាតុ។ មានតែវិស័យទេសចរណ៍ទេដែលនូវតែបន្តទទួលរងផលប៉ះពាល់ជាមួយការធ្លាក់ចុះភ្ញៀវទេសចរអន្តរជាតិ -៨៥% ស្របពេលដែលភ្ញៀវទេសចរក្នុងស្រុកបានធ្លាក់ចុះ -៣៥%។

## ២.២ អត្រាអតិផរណាប្រចាំឆ្នាំជាភាគរយឆ្នាំលើឆ្នាំ

តារាង ២.១៖ តារាងបម្រែបម្រួលអត្រាអតិផរណាប្រចាំឆ្នាំជាភាគរយឆ្នាំលើឆ្នាំ

| **បម្រែបម្រួលអត្រាអតិផរណាឆ្នាំលើឆ្នាំ** | | | | | | | |
|---|---|---|---|---|---|---|---|
| **គិតជាភាគរយ** | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| មករា | ០.៤ | ៣ | ៤.៤ | ២ | ១.៥ | ៣.៦ | ២.៦ |
| កុម្ភៈ | ១.៦ | ២.៣ | ៤ | ២.៣ | ២ | ២.៦ | ១.៧ |
| មីនា | ១.១ | ២ | ៤.៣ | ២.៣ | ២.២ | ២.៨ | ២.១ |
| មេសា | ១.៣ | ២.៨ | ៣.២ | ២.៤ | ២.១ | ១.៩ | ២.៧ |
| ឧសភា | ១ | ៣.២ | ២.៥ | ២.៩ | ២ | ២.៣ | ៣ |
| មិថុនា | ០.៧ | ៣.៣ | ២.៣ | ២.៩ | ១.៤ | ២.៤ | ២.៧ |
| កក្កដា | ០.៨ | ៣ | ២.៣ | ២.៣ | ២.២ | ៣.១ | ៣.៣ |
| សីហា | ០.៨ | ២.៩ | ២.៦ | ២.៦ | ២.៤ | ២.៤ | ៣.៤ |
| កញ្ញា | ០.៩ | ៣ | ២.៧ | ២.៦ | ១.៧ | ២.៩ | ៣ |
| តុលា | ១.៣ | ៣.៤ | ២.១ | ៣.១ | ១.៣ | ៣.៧ | ២.៩ |
| វិច្ឆិកា | ១.៩ | ៣.៦ | ២.៣ | ២.៥ | ១.៨ | ៣.៦ | ៣.៨ |
| ធ្នូ | ២.៨ | ៣.៩ | ២.២ | ១.៦ | ៣.១ | ៣.១ | ៣.៧ |
| **ជាមធ្យមភាគ** | ១.២ | ៣.០ | ២.៩ | ២.៥ | ១.៩ | ២.៩ | ២.៩ |

ប្រភព៖ របាយការណ៍ស្តីពីអតិផរណាប្រចាំខែរបស់ធនាគារជាតិនៃកម្ពុជា




ប្រភព៖ ពីគេហទំព័រ https://data.worldbank.org/indicator/FP.CPI.TOTL.ZG?locations=KH

តាមរយៈក្រាហ្វិក ២.១ ខាងលើ យើងសង្កេតឃើញថា អត្រាអតិផរណាឆ្នាំលើឆ្នាំជាមធ្យមប្រចាំឆ្នាំនីមួយៗ គិតចាប់តាំងពីឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០២១ គឺមានការប្រែប្រួលគួរឲ្យកត់សម្គាល់។ ដោយពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៦ អត្រាអតិផរណាមានការប្រែប្រួលខ្លាំង ពី ១.២% ទៅ ៣.0% ហើយការកើនឡើងក្នុងអត្រាអតិផរណាដ៏ខ្ពស់ក្នុងឆ្នាំ២០១៦ នេះ គឺមានកត្តាចម្បងបណ្តាលមកពីកំណើនថ្លៃម្ហូបអាហារ ក្រុមសម្លៀកបំពាក់ និងក្រុមភោជនីយដ្ឋាន។ ប៉ុន្តែអត្រាអតិផរណាក្នុងឆ្នាំបន្ទាប់ៗ គឺមានការថមថយយ៉ាងខ្លាំង ដោយនៅក្នុងឆ្នាំ ២០១៧ ក្នុងអត្រា ២.៩% ក្នុងឆ្នាំ២០១៨ ក្នុងអត្រា ២.៥% និងក្នុងឆ្នាំ២០១៩ ក្នុងអត្រា ១.៩%។

ប៉ុន្តែជាអកុសល ចាប់តាំងពីមានការរីករាលដាលនៃជំងឺឆ្លងកូវីដ ១៩ នៅទូទាំងសកលលោកមក យើងសង្កេតឃើញថា អត្រាអតិផរណានៅក្នុងប្រទេសមានកម្រិតខ្ពស់ជាងឆ្នាំ២០១៩ បន្តិច គឺស្ថិតក្នុងអត្រា ២.៩% ហើយអត្រាអតិផរណានៅក្នុងឆ្នាំ២០២១ ក៏បន្តមានកម្រិតប្រហាក់ប្រហែលនឹងឆ្នាំ២០២០ ដែរ ដោយស្ថិតក្នុងអត្រាជាមធ្យម ២.៩%។

## ២.៣ ស្ថានភាពអតិផរណាប្រចាំឆ្នាំនីមួយៗ

### ២.៣.១ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៥

ស្ថានភាពអតិផរណាក្នុងឆ្នាំ២០១៥ មានភាពល្អប្រសើរធៀបនឹងឆ្នាំ២០១៤ ដោយសារការធ្លាក់ចុះនៃថ្លៃប្រេង, អត្រាអតិផរណាទាបនៅក្នុងប្រទេសនាំទំនិញចូលមកកម្ពុជា និងការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុប្រកបដោយប្រសិទ្ធភាព។ នៅក្នុងឆ្នាំ២០១៥ នេះអតិផរណារួមគិតជាមធ្យមមានកម្រិតទាបត្រឹម ១.២% ប៉ុណ្ណោះធៀបនឹងឆ្នាំ២០១៤ (៣.៩%) និងទាបជាងរំពឹងទុករបស់រាជរដ្ឋាភិបាល (៣%)។

**ក្រាហ្វិក ២.២ : អតិផរណា**




ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ២០១៥ និងទិសដៅការងារឆ្នាំ២០១៦ (ធនាគារជាតិនៃកម្ពុជា)

បើពិនិត្យមើលការប្រែប្រួលក្នុងឆ្នាំ ២០១៥ នេះ អត្រាអតិផរណារួមឆ្នាំលើឆ្នាំ បានប្រែប្រួលក្នុងកម្រិតទាបទៅតាមកត្តារដូវកាល។ នៅខែមករា អតិផរណារួមបានថយចុះដល់ 0.៤% ប៉ុន្តែនៅក្នុងខែកុម្ភៈ បានកើនឡើងបន្តិចមកវិញដល់ ១.៦% ដោយសារការកើនឡើងនៃតម្រូវការប្រើប្រាស់ក្នុងស្រុក ជាពិសេសក្រុមម្ហូបអាហារនៅក្នុងពិធីចូលឆ្នាំប្រពៃណីផ្សេងៗ ខណៈដែលក្រុមដឹកជញ្ជូនបានចូលរួមបន្ទាបអត្រាអតិផរណា។ ចាប់ពីខែមីនា ដល់ខែកញ្ញា អត្រាអតិផរណាមានស្ថិរភាពជាមធ្យមប្រមាណ ១% ប៉ុណ្ណោះ។ ដោយឡែក នៅក្នុងត្រីមាសទី៤ អតិផរណារួមបានកើនពី ១.៣% នៅខែតុលា ដល់ ២.៦% នៅខែធ្នូ (តាមការប៉ាន់ស្មាន) ដែលបណ្តាលមកពីកំណើនតម្រូវការក្នុងរដូវកាលបុណ្យប្រពៃណីជាតិធំៗ និងបុណ្យចូលឆ្នាំសកល។

ការថយចុះនៃថ្លៃប្រេងកម្ពុជាបណ្តាលមកពីការធ្លាក់ថ្លៃប្រេងពិភពលោក ដោយសារតែកម្ពុជាជាប្រទេសនាំចូលប្រេងសុទ្ធ។ នៅឆមាសទី១ តម្លៃប្រេងធម្មតាជាមធ្យមមានតម្លៃ ៤,១០៨ រៀលក្នុងមួយលីត្រ (ប្រមាណ ១ ដុល្លារអាមេរិក) បន្ទាប់មកនៅឆមាសទី២ ថ្លៃប្រេងសាំងបានថយចុះមក ៣,៧៣៣ រៀលក្នុងមួយលីត្រ (ប្រមាណ 0.៩ ដុល្លារអាមេរិក)។ ជាមធ្យម តម្លៃប្រេងនៅកម្ពុជាបានធ្លាក់ចុះ ២៣% (ឆ្នាំលើឆ្នាំ)។ ម្យ៉ាងវិញទៀត អតិផរណាទាបនៅក្នុងបណ្តាប្រទេសនាំចូលមកកម្ពុជាបានរួមចំណែកបន្ទាបអតិផរណាកម្ពុជា។

ជាក់ស្តែង អតិផរណាកែតម្រូវដែលបង្ហាញពីឥទ្ធិពលនាំចូលមកកម្ពុជាមានកម្រិតជាមធ្យមត្រឹម-0.២% ប៉ុណ្ណោះ ដោយសារប្រាក់រៀលបានឡើងថ្លៃធៀបនឹងប្រាក់ដុងវៀតណាម បាតថៃ និងដុល្លារតៃវ៉ាន់ គួបផ្សំទៅនឹងអត្រាអតិផរណាទាបរបស់ប្រទេសថៃ និងតៃវ៉ាន់ ដែលបានថយចុះដល់កម្រិត -0.៩% និង -0.៣% រៀងគ្នា។ មូលហេតុចម្បងនៃការថយចុះនៃអត្រាអតិផរណារបស់ប្រទេសទាំងនោះ គឺបណ្តាលមកពីការថយចុះនៃថ្លៃម្ហូបអាហារ និងជាពិសេសថ្លៃថាមពល។

ជារួម អត្រាអតិផរណាស្ថិតក្នុងកម្រិតទាប ដោយសារការថយចុះនៃថ្លៃប្រេង សម្ពាធទាបនៃអតិផរណានាំចូល និងជាពិសេសប្រសិទ្ធភាពនៃការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុដោយធនាគារជាតិនៃកម្ពុជា ទោះបីជា

សន្ទុះកំណើនសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកបានបន្តជំរុញតម្រូវការឲ្យកើនឡើង ហើយបានបង្កើតជាសម្ពាធអតិផរណាក្នុងឆ្នាំ២០១៥ នេះក្តី។

### ២.៣.២ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៦

នៅក្នុងឆ្នាំ២០១៦ កម្រិតអត្រាអតិផរណាឆ្នាំលើឆ្នាំបានកើនឡើងវិញបន្តិច ដោយមានកម្រិតជាមធ្យមប្រមាណ ២.៩% ធៀបនឹងឆ្នាំ២០១៥ (១.២%) ប៉ុន្តែទាបជាងឆ្នាំ ២០១៤ (៣.៩%) ក្នុងនោះ នៅឆមាសទី១ ឆ្នាំ ២០១៦ អតិផរណាមានកម្រិតមធ្យម ២.៨% ខ្ពស់ជាងគ្រាដូចគ្នា ឆ្នាំ២០១៥ (១%) បន្ទាប់មកនៅក្នុងឆមាសទី ២ មានអត្រា ២.៩% ខ្ពស់ជាងគ្រាដូចគ្នា ឆ្នាំ២០១៥ (១.៤%)។ ការកើនឡើងនៃអត្រាអតិផរណានៅក្នុងឆ្នាំ ២០១៦ ជាចម្បងបណ្តាលមកពីកត្តាកំណើនថ្លៃម្ហូបអាហារ (៥%) ក្រុមសម្លៀកបំពាក់ (៤.២%) និងក្រុមភោជនីយដ្ឋាន (៣.៦%)[17]។

អតិផរណាក្នុងក្រុមទាំងនេះ បានឆ្លុះបញ្ចាំងពីកំណើនតម្រូវការរបស់អ្នកប្រើប្រាស់ខណៈពេលដែលអត្រាអតិផរណារបស់ប្រទេសជាដៃគូផ្គត់ផ្គង់ទំនិញនាំចូលសំខាន់ៗរបស់កម្ពុជា មានកម្រិតទាប។ ទោះបីជាយ៉ាងណាក៏ដោយ ថ្លៃក្រុមដឹកជញ្ជូន និងការប្រើប្រាស់ក្នុងក្រុមផ្ទះសម្បែង មានកំណើនមធ្យមទាប ដោយសារការថមថយនៃថ្លៃប្រេងសាំង និងថាមពលនៅកម្ពុជា ហើយក្រុមទាំងពីរនេះ ក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយអតិផរណារួមឲ្យស្ថិតក្នុងកម្រិតទាបផងដែរ។




**ក្រាហ្វិក ២.៣ : អតិផរណា (ឆ្នាំលើឆ្នាំ)**
ខែមករា ឆ្នាំ២០១៥- ខែធ្នូ ឆ្នាំ២០១៦

ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧ (ធនាគារជាតិនៃកម្ពុជា)

អតិផរណាស្នូល គឺជាបម្រែបម្រួលនៃថ្លៃដើមទំនិញ និងសេវាកម្ម ដែលមិនរួមបញ្ចូលថ្លៃម្ហូបអាហារ និងទំនិញពាក់ព័ន្ធនឹងប្រេងឥន្ធនៈឡើយ នេះក៏ដោយសារតែកត្តាថ្លៃម្ហូបអាហារ និងទំនិញពាក់ព័ន្ធនឹងប្រេងឥន្ធនៈ

[17] របាយការណ៍ប្រចាំឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧

មានកម្រិតប្រែប្រួលខ្លាំងលើតម្លៃរបស់វា និងបង្កជាសម្ពាធដល់កម្រិតអតិផរណាផងដែរ។ ក្នុងឆ្នាំ២០១៦ អត្រាអតិផរណាស្នូល មានកម្រិត ២.៦% ទាបជាងឆ្នាំ២០១៥ (៣.១%)។ គួរសម្គាល់ថា អតិផរណាស្នូលមានកម្រិតប្រហាក់ប្រហែលនឹងអតិផរណារួម (២.៩%) ដែលបង្ហាញជាថ្មីម្តងទៀតថា អតិផរណាគឺបណ្តាលមកពីកំណើននៃតម្រូវការ ស្របតាមកំណើនសេដ្ឋកិច្ច និងការកើនឡើងនៃចំណូលរបស់ប្រជាជន។

ជារួម អតិផរណានៅក្នុងឆ្នាំ២០១៦ បន្តមានកម្រិតទាប សមស្របទៅតាមការប៉ាន់ស្មានក្នុងក្របខណ្ឌគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល និងបានអំណោយផលដល់ការលើកស្ទួយសកម្មភាពផលិតកម្ម និងពាណិជ្ជកម្មក្នុងស្រុក ព្រមទាំងបានរួមចំណែកដ៏សំខាន់ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

### ២.៣.៣ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៧

អត្រាអតិផរណានៅក្នុងឆ្នាំ២០១៧ បន្តស្ថិតក្នុងកម្រិតទាបអាចគ្រប់គ្រងបាន ប្រមាណ ២.៩% ប្រហាក់ប្រហែលនឹងឆ្នាំ២០១៦ (៣%) និងអត្រាមធ្យមក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ (២.៨%)។ មូលហេតុចម្បងដែលជំរុញឲ្យមានអតិផរណាក្នុងកម្រិតនេះរួមមាន ការឡើងថ្លៃម្ហូបអាហារក្នុងល្បឿនទាបជាងមុននិងការកើនឡើងថ្លៃប្រេងឥន្ធនៈដែលរួមចំណែកបន្ថែមសម្ពាធបន្តិចដល់អតិផរណា។

អត្រាអតិផរណាចាប់ពីខែមករា ដល់ ខែមីនា ក្នុងឆ្នាំ២០១៧ មានកម្រិតខ្ពស់បន្តិចប្រមាណ ៤.២% បណ្តាលមកពីការឡើងថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ ក្នុងនោះថ្លៃម្ហូបអាហារបានកើនឡើងស្របតាមកំណើនតម្រូវការ ហើយថ្លៃប្រេងឥន្ធនៈកើនឡើងដោយសារការកាត់បន្ថយផលិតកម្មប្រេងនៅបណ្តាប្រទេសសមាជិកអង្គការនៃប្រទេសនាំចេញប្រេង (OPEC) ដែលបានធ្វើឲ្យប្រេងឆៅពិភពលោកងើបឡើងវិញ។ ប៉ុន្តែ អត្រាអតិផរណាបានចាប់ផ្តើមថមថយមកវិញចាប់តាំងពីខែមេសា ជាចម្បងដោយសារការថយល្បឿននៃការឡើងថ្លៃម្ហូបអាហារ និងថ្លៃប្រេងឆៅពិភពលោក នៅពេលសហរដ្ឋអាមេរិកបានបង្កើនផលិតកម្មប្រេងដើម្បីផ្គត់ផ្គង់នៅលើទីផ្សារ។

**ក្រាហ្វិក ២.៤ : អតិផរណា**

(គិតជាភាគរយ, អត្រាមធ្យម, ឆ្នាំ ២០១៣-២០១៧ ប៉ាន់ស្មាន)




ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ (ធនាគារជាតិនៃកម្ពុជា)

### ២.៣.៤ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៨

អតិផរណាជាមធ្យម មានអត្រា ២.៥% ក្នុងឆ្នាំ២០១៨ ដែលជាកម្រិតមួយទាបជាងការព្យាករណ៍កាលពីដើមឆ្នាំ (៣%) និងអតិផរណាឆ្នាំ២០១៧ (២.៨%)[18]។ អត្រាទាបនេះ បណ្តាលមកពីការថយល្បឿននៃកំណើនថ្លៃម្ហូបអាហារ ខណៈដែលអតិផរណាក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ទនៈមានកម្រិតខ្ពស់ជាងឆ្នាំមុន ហើយអតិផរណាស្នូលបន្តមានស្ថិរភាពក្នុងកម្រិតទាប ដែលឆ្លុះបញ្ចាំងពីស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្រោមបរិការណ៍ស្ថិរភាពនយោបាយ និងការអនុវត្តនយោបាយសារពើពន្ធ និងរូបិយវត្ថុសមស្រប និងមានសង្គតិភាព។

**ក្រាហ្វិក ២.៥ : អតិផរណារួម និងការរួមចំណែកក្នុងអតិផរណារួម**

(ឆ្នាំលើឆ្នាំ, ឆ្នាំ ២០១៦-២០១៨)




ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ២០១៨ និងទិសដៅការងារឆ្នាំ២០១៩ (ធនាគារជាតិនៃកម្ពុជា)

**អតិផរណាក្រុមម្ហូបអាហារ៖** កំណើនថ្លៃក្រុមម្ហូបអាហារជាមធ្យមមានអត្រា ២.៥% ទាបជាងឆ្នាំមុន (៣.៤%)។ កំណើនក្រុមទំនិញសំខាន់ៗដូចជា សាច់ ត្រីស្រស់ និងបន្លែ សុទ្ធតែមានកំណើនថ្លៃទាបជាងមុន ខណៈថ្លៃផ្លែឈើមានកំណើនខ្ពស់ជាងឆ្នាំមុនបន្តិច ហើយថ្លៃអង្ករមានកំណើនប្រហាក់ប្រហែលនឹងឆ្នាំមុន។ គួរកត់សម្គាល់ផងដែរថា នៅក្នុងត្រីមាសទី ៣ អតិផរណាក្រុមម្ហូបអាហារបានថមថយទៅតាមនិន្នាការថ្លៃម្ហូបអាហាររបស់ពិភពលោក។

**អតិផរណាក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ទនៈ** ៖ ក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ទនៈមានកំណើន ៣.៧% ខ្ពស់ជាងឆ្នាំមុន (២.១%)។ ថ្លៃក្រុមទំនិញ និងសេវាទាំងនេះ មាននិន្នាការកើនឡើងតាំងពីដើមឆ្នាំ ដោយសារការបន្តកិច្ចព្រមព្រៀងកាត់បន្ថយការផ្គត់ផ្គង់របស់ប្រទេសនាំចេញប្រេង (OPEC) ការធ្លាក់ចុះការផ្គត់ផ្គង់ប្រេងពីប្រទេសរុស្ស៊ី និងវ៉េណេស៊ុយអេឡា គួបផ្សំនឹងការព្រួយបារម្ភពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ចពី

[18] របាយការណ៍ប្រចាំឆ្នាំ២០១៨ និងទិសដៅការងារឆ្នាំ២០១៩ (ធនាគារជាតិនៃកម្ពុជា)

សហរដ្ឋអាមេរិកមកលើអ៊ីរ៉ង់ ដែលអាចរាំងស្ទះការនាំចេញប្រេងរបស់ប្រទេសនេះ។ ប៉ុន្តែកំណើននេះ ត្រូវបានថមថយមកវិញ ដោយសាររាជរដ្ឋាភិបាលកម្ពុជាបានធ្វើអន្តរាគមន៍បញ្ចុះថ្លៃប្រេង ១៨០ រៀលក្នុងមួយលីត្រកាលពីខែកក្កដា គួបផ្សំនឹងការថមថយនៃថ្លៃប្រេងនៅអន្តរជាតិនៅខែវិច្ឆិកា និងខែធ្នូ ដោយសារកំណើនការផ្គត់ផ្គង់ពីសហរដ្ឋអាមេរិក ប្រទេសរុស្ស៊ី អារ៉ាប៊ីសាអូឌីត និងអេមីរ៉ាតអារ៉ាប់រួម។

**អតិផរណាស្នូល** ៖ អតិផរណាស្នូលបន្តមានស្ថិរភាពក្នុងកម្រិតទាបប្រមាណ ២.១% ប្រហាក់ប្រហែលនឹងកម្រិតមធ្យមបីឆ្នាំចុងក្រោយ (២.៣%) ដែលឆ្លុះបញ្ចាំងពីស្ថានភាពល្អនៃសេដ្ឋកិច្ច និងការផ្គត់ផ្គង់រូបិយវត្ថុសមស្រប ហើយស្ថិរភាពតម្លៃប្រាក់រៀលក៏បានរួមចំណែករក្សាស្ថិរភាពថ្លៃនេះផងដែរ។ អតិផរណាស្នូល បានរួមចំណែកប្រមាណ ០.៧% ក្នុងអតិផរណារួម ដែលក្នុងនោះថ្លៃក្រុមភោជនីយដ្ឋានបានកើនឡើងជាមធ្យមប្រមាណ ៦% ដោយសារការកើនឡើងតម្រូវការពីអង្គភាពគ្រួសារ និងការបន្តរីកចម្រើននៃវិស័យទេសចរណ៍។

**ក្រាហ្វិក ២.៦ : អតិផរណាតាមក្រុម**

(ឆ្នាំលើឆ្នាំ, ឆ្នាំ ២០១៦-២០១៨)




ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០ (ធនាគារជាតិនៃកម្ពុជា)

## ២.៣.៥ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៩

អតិផរណាមានកម្រិតត្រឹម ១.៩% ទាបជាងឆ្នាំមុន (២.៥%) និងឆ្នាំ២០១៧ (២.៩%)។ ការថយចុះនេះគឺដោយសារកាបន្តថមថយកំណើនថ្លៃក្រុមម្ហូបអាហារ ដែលមានសមាមាត្រធំជាងគេក្នុងកន្ត្រកទំនិញអ្នកប្រើប្រាស់ ស្របពេលដែលមានការធ្លាក់ថ្លៃនៃក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ បើទោះជាអតិផរណាស្នូលបានកើនឡើងបន្តិចក៏ដោយ។

ថ្លៃក្រុមម្ហូបអាហារបានបន្តថមថយល្បឿនកំណើន ១.៩% ទាបជាងឆ្នាំមុន (២.៥%) និងឆ្នាំ២០១៧ (៣.៥%) ដែលរួមចំណែកដោយសារការឡើងថ្លៃបន្តិចនៃប្រាក់រៀលធៀបនឹងរូបិយប័ណ្ណរបស់ប្រទេសសំខាន់ៗ ដែលកម្ពុជានាំទំនិញចូល ស្របពេលអត្រាអតិផរណាថៃ និងវៀតណាមបានថយចុះពី ១.១% មក ០.៧% និង ៣.៥% មក ២.៥% រៀងគ្នា ធៀបនឹងឆ្នាំមុន ទោះវិស័យកសិកម្មក្នុងស្រុកបន្តមានកំណើនយឺតជាងឆ្នាំមុនបន្តិច។

ថ្លៃក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ទនៈបានថយចុះ ១.២% បន្ទាប់ពីបានឡើងថ្លៃនៅឆ្នាំ ២០១៧-២០១៨ ដោយសារកាធ្លាក់ថ្លៃប្រេងឆៅពិភពលោកដែលបណ្ដាលមកពី៖

- កំណើននៃការផ្គត់ផ្គង់ពីសហរដ្ឋអាមេរិក ប្រេស៊ីល អ៊ីរ៉ាក់ និងអារ៉ាប់រួម ទោះបីជាក្រុមប្រទេសនាំចេញប្រេង (OPEC) បានបន្តកិច្ចព្រមព្រៀងកាត់បន្ថយការផ្គត់ផ្គង់ដ៏ដោយ
- ភាពទន់ខ្សោយនៃតម្រូវការ ដោយសារការថមថយនៃកំណើនសេដ្ឋកិច្ចពិភពលោក
- វិធានការកាត់បន្ថយពន្ធនាំចូលប្រេងឥន្ទនៈ និងអន្តរាគមន៍ផ្សេងៗរបស់រាជរដ្ឋាភិបាលកម្ពុជា[19]។

អតិផរណាស្នូលកើនឡើងក្នុងកម្រិតទាប ២.៦% ធៀបនឹងឆ្នាំមុន (២.១%)។ ការកើនឡើងនេះ ជាចម្បងជំរុញដោយកំណើនថ្លៃក្រុមភោជនីយដ្ឋាន និងក្រុមភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ (បន្ទាប់ពីការដំឡើងពន្ធនាំចូល) គួបផ្សំនឹងការកើនឡើងបន្តិចនៃអតិផរណាក្រុមកម្សាន្ត និងវប្បធម៌ ក្រុមផ្ទះសម្បែង និងក្រុមគ្រឿងសង្ហារឹម ឬសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ និងការថែទាំផ្ទះជាប្រចាំ។

**ក្រាហ្វិក ២.៧: អតិផរណារួម និងការរួមចំណែកក្នុងអតិផរណា**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ ខែមករា ឆ្នាំ២០១៧-ខែធ្នូ ឆ្នាំ២០១៩)




**ក្រាហ្វិក ២.៨ : អតិផរណាតាមក្រុមសំខាន់ៗទាំងបី**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ ខែមករា ឆ្នាំ២០១៧-ខែធ្នូ ឆ្នាំ២០១៩)




ប្រភព៖ របាយការប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០ (ធនាគារជាតិនៃកម្ពុជា)

[19] ថ្លៃប្រេងឆៅពិភពលោកបានថយចុះ ១៣.១% ធៀបនឹងតម្លៃជាមធ្យម ៦៤.៩ ដុល្លារអាមេរិកកាលពីឆ្នាំ២០១៨ ចំណែកនៅកម្ពុជាប្រេងសាំងមានតម្លៃជាមធ្យម ៣,៦២០ រៀលក្នុងមួយលីត្រ ដោយសារបានថយចុះប្រមាណ ៩% ធៀបនឹងឆ្នាំមុន។

### ២.៣.៦ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០២០

អតិផរណាបន្តមានកម្រិតទាបក្នុងអត្រា ២.៩% ប៉ុន្តែខ្ពស់ជាងឆ្នាំមុនបន្តិច (១.៩%) ជាមធ្យម ដោយសារកំណើនថ្លៃក្រុមម្ហូបអាហារ បើទោះក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបានធ្លាក់ថ្លៃ ហើយកំណើនថ្លៃក្រុមទំនិញស្នូលបានថមថយក៏ដោយ។

ថ្លៃក្រុមម្ហូបអាហារបានកើនឡើង ៤.៦% ដោយនៅក្នុងឆ្នាំ២០១៩ ស្ថិតក្នុងអត្រាត្រឹមតែ ២.១%។ ការកើនឡើងនេះ ជាចម្បងដោយសារឥទ្ធិពលនៃការរីករាលដាលនៃជំងឺកូវីដ ១៩ ដែលបានធ្វើឲ្យមានកំណើនតម្រូវការ និងការរអាក់រអួលក្នុងការដឹកជញ្ជូនទំនិញនាំចូល ស្របពេលដែលថ្លៃម្ហូបអាហារនៅប្រទេសសំខាន់ៗដែលកម្ពុជានាំចូលក៏បានកើនឡើងផងដែរ ដូចជាប្រទេសវៀតណាម ថៃ និងចិន ក្នុងហេតុផលដូចគ្នា។ ផ្ទុយទៅវិញ ថ្លៃក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈមានបរិត្តផរណា -៣.៣% (-១.១% នៅឆ្នាំមុន) ដោយសារការធ្លាក់ថ្លៃប្រេងឆៅពិភពលោក ដែលបណ្តាលមកពីការថយចុះតម្រូវ ស្របពេលដែលបរិមាណនៃការផ្គត់ផ្គង់ត្រូវបានកាត់បន្ថយតិចតួច និងកង្វះទីតាំងស្តុកប្រេង។

អតិផរណាស្នូលបានថមថយមកត្រឹម ២.១% (ដោយនៅក្នុងឆ្នាំ២០១៩ ស្ថិតក្នុងអត្រា ២.៧%) ជាចម្បងដោយសារការថយល្បឿនកំណើនថ្លៃក្រុមភោជនីយដ្ឋាននៅពេលតម្រូវការបានធ្លាក់ចុះគួរកត់សម្គាល់ និងក្រុមភេសជ្ជៈមានជាតិស្រវឹង និងថ្នាក់ជក់ គួបផ្សំនឹងការថមថយកំណើនថ្លៃក្រុមសុខាភិបាល និងក្រុមគ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារ និងការថែទាំផ្ទះជាប្រចាំ។

**ក្រាហ្វិក ២.៩ : អតិផរណារួម និងការរួមចំណែកក្នុងអតិផរណារួម**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០១៨-ខែធ្នូ ឆ្នាំ២០២០ ប៉ាន់ស្មាន)




**ក្រាហ្វិក ២.១០ : អតិផរណានៃក្រុមទាំងបី**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០១៨-ខែធ្នូ ឆ្នាំ២០២០ ប៉ាន់ស្មាន)




ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១ (ធនាគារជាតិនៃកម្ពុជា)

### ២.៣.៧ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០២១

អតិផរណារួមបន្តមានស្ថិរភាព ក្នុងកម្រិតជាមធ្យម ២.៩% ប្រហាក់ប្រហែលនឹងឆ្នាំ២០២០ (២.៩%) ជាចម្បងដោយសារការថយល្បឿននៃកំណើនថ្លៃក្រុមម្ហូបអាហារ ខណៈដែលថ្លៃក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបានងើបឡើងវិញ (ដោយប្តូរពីបរិត្តផរណាទៅអតិផរណា)។ អតិផរណាក្រុមម្ហូបអាហារបានថមថយល្បឿនមក ២.៧% (៤.៦% នៅក្នុងឆ្នាំ២០២០) ដែលរួមចំណែកជាចម្បងដោយការបន្តថយចុះនៃតម្រូវការដោយសារការផ្អាកកម្មវិធីជួបជុំនានាក្នុងរយៈពេល ១០ខែ ដើមឆ្នាំ២០២១ ហើយកំណើនថ្លៃម្ហូបអាហារនៅប្រទេសដៃគូនាំចូលមានកម្រិតទាប។

អតិផរណាស្នូល បានថយល្បឿនបន្តិចមក ១.៦% (២.១% នៅឆ្នាំ២០២០) ជាចម្បងដោយសារតម្រូវការនៅបន្តមានភាពទន់ខ្សោយ។ អតិផរណាក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបានកើនឡើងដល់ ៨.៦% (-៣.២% ឆ្នាំមុន) ស្របតាមនិន្នាការនៃការងើបឡើងវិញនៃថ្លៃប្រេងឆៅពិភពលោក នៅពេលតម្រូវការប្រេងឆៅនៅលើពិភពលោកមានការកើនឡើង។

**ក្រាហ្វិក ២.១១ : អតិផរណារួម និងការរួមចំណែកក្នុងអតិផរណារួម**
(ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០១៩-ខែធ្នូ ឆ្នាំ២០២១)




**ក្រាហ្វិក ២.១២ : អតិផរណារួម និងអតិផរណាក្រុមធាតុចំបង**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០១៩-ខែធ្នូ ឆ្នាំ២០២០ ប៉ាន់ស្មាន)




ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ (ធនាគារជាតិនៃកម្ពុជា)

## ២.៤ មូលហេតុនៃបម្រែបម្រួលអតិផរណាកម្ពុជា

### ២.៤.១ កត្តាខាងក្រៅ

#### ក. ថ្លៃប្រេងឆៅពិភពលោក និងថ្លៃប្រេងសាំងនៅកម្ពុជា

ដោយសារតែកម្ពុជាជាប្រទេសនាំចូល ដូចនេះរាល់ការប្រែប្រួលថ្លៃទំនិញនាំចូលមានទំនាក់ទំនងជាមួយអតិផរណាកម្ពុជា ជាពិសេសប្រេងឥន្ធនៈ និងម្ហូបអាហារ គឺជាមុខទំនិញនាំចូលដ៏សំខាន់ ដែលមានឥទ្ធិពលផ្ទាល់លើអតិផរណារួម និងមានឥទ្ធិពលប្រយោលលើតម្លៃទំនិញផ្សេងទៀត។ ដោយក្នុងនោះ ការធ្លាក់ចុះនៃថ្លៃ

ប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ និងអតិផរណាទាបរបស់ប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗដែលនាំចូលមកកម្ពុជា ក៏ជាកត្តាចម្បងធ្វើឲ្យអតិផរណារួមនៅកម្ពុជាមានកម្រិតទាបផងដែរ។

ជាក់ស្តែង ក្នុងឆ្នាំ២០១៦ យើងសង្កេតឃើញថា ប្រេងឆៅសកលបានកើនឡើងបន្តិចពី ០.៣ ដុល្លារក្នុងមួយលីត្រ នៅខែមករា ដល់ ០.៣៧ ដុល្លារក្នុងមួយលីត្រនៅខែមិថុនា។ មូលហេតុចម្បងនៃការកើនឡើងនេះ គឺបណ្តាលមកពីការថយចុះនៃកំណើនផលិតកម្មប្រេងរបស់សហរដ្ឋអាមេរិក រួមនឹងភាពតានតឹងផ្នែកនយោបាយនៅតំបន់មជ្ឈិបូព៌ា និងអាហ្វ្រិកខាងជើងដែលមិនអាចផ្គត់ផ្គង់តាមកំណើនតម្រូវការ។

ប៉ុន្តែ ដោយសារតែមានការអនុវត្តកិច្ចព្រមព្រៀងកាត់បន្ថយផលិតកម្មប្រេងនៅបណ្តាប្រទេសសមាជិក (OPEC) លើកលែងប្រទេសនីហ្សេរីយ៉ា និងលីប៊ី បានធ្វើឲ្យតម្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិមានការកើនឡើងវិញ ដោយតម្លៃប្រេងឆៅពិភពលោកជាមធ្យម បានកើនឡើងពី ១.១២៩ រៀលក្នុងមួយលីត្រ នៅក្នុងឆ្នាំ ២០១៦ ដល់ ១.២៨៥ រៀលក្នុងមួយលីត្រ ពោលគឺមានកំណើន ២១% (ឆ្នាំលើឆ្នាំ)។ ទន្ទឹមនេះ ថ្លៃប្រេងសាំងកម្ពុជាបានកើនពី ៣.៣២៥ រៀលក្នុងមួយលីត្រ ដល់ ៣.៦៧៥ រៀលក្នុងមួយលីត្រ (១០.៥%) ដែលបានបង្កឲ្យមានសម្ពាធដល់អតិផរណាតាមរយៈការឡើងថ្លៃនៃក្រុមដឹកជញ្ជូន។

នៅក្នុងឆ្នាំ២០១៨ ថ្លៃប្រេងឆៅពិភពលោកបានបន្តកើនឡើងក្នុងកំឡុង ១០ ខែដំបូង ដោយសារការបន្តអនុវត្តកិច្ចព្រមព្រៀងកាត់បន្ថយការផ្គត់ផ្គង់ពីបណ្តាប្រទេសនាំចេញប្រេង (OPEC), ស្របពេលដែលមានការធ្លាក់ចុះជាងការរំពឹងទុកនៃការផ្គត់ផ្គង់ប្រេងពីរុស្ស៊ី និងប្រទេសវ៉េណេស៊ុយអេឡា និងការព្រួយបារម្ភពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ចពីសហរដ្ឋអាមេរិកមកលើអ៊ីរ៉ង់ ដែលអាចបង្កភាពរាំងស្ទះដល់ការនាំចេញប្រេងពីប្រទេសនេះ។ ជាលទ្ធផល វាបាននាំឲ្យតម្លៃប្រេងឆៅនៅលើទីផ្សារពិភពលោកបានកើនឡើងពី ៦៣.៧ ដុល្លារអាមេរិកក្នុងមួយប៉ារ៉ែល ដល់ ៧០.៨ ដុល្លារអាមេរិកក្នុងមួយប៉ារ៉ែល។

ការកើនឡើងនៃតម្លៃប្រេងឆៅនៅលើទីផ្សារពិភពលោកនេះហើយក៏បានបង្កឲ្យតម្លៃប្រេងសាំងនៅកម្ពុជាមានការប្រែប្រួលផងដែរ ជាពិសេសនៅចុងត្រីមាសទី២ និងដើមត្រីមាសទី៤ ដោយតម្លៃប្រេងសាំងកើនឡើងដល់កម្រិតខ្ពស់ប្រមាណ ៤៣០០ រៀលក្នុងមួយលីត្រ។ ដោយជារួម ប្រេងសាំងកម្ពុជានៅឆ្នាំ២០១៨ មានតម្លៃជាមធ្យម ៣៩៥០ រៀលក្នុងមួយលីត្រ ដោយមានកំណើន ៦.៨% ធៀបនឹងតម្លៃជាមធ្យម ៣៧០០ រៀលក្នុងមួយលីត្រ នៅឆ្នាំ២០១៧។

ជាសរុប យើងអាចធ្វើការកត់សម្គាល់បានថា ការឡើងចុះនៃតម្លៃប្រេងឆៅពិភពលោក បានបង្កជាមូលហេតុចម្បងមួយដែលនាំឲ្យមានជាសម្ពាធ និងការប្រែប្រួលអត្រាអតិផរណានៅកម្ពុជា ព្រោះថាកម្ពុជាជាប្រទេសនាំចូលប្រេងឥន្ធនៈ ដូចនេះហើយ តម្លៃប្រេងសាំងដែលចរាចរលក់នៅក្នុងប្រទេស គឺតម្លៃត្រូវតែមានការបត់បែនស្របទៅតាមនិន្នាការតម្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ។

**ខ. អតិផរណានៃប្រទេសនាំទំនិញចូលមកកម្ពុជាសំខាន់**

ក្រៅតែពីកត្តាប្រេងនៅពិភពលោក កត្តាចម្បងមួយទៀតគឺបណ្តាលមកពីអតិផរណានៃប្រទេសនាំទំនិញចូលមកកម្ពុជា។ ប្រទេសដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជារួមមាន ចិន (៣៦.៥% នៃការនាំចូលសរុប) ថៃ (១៣.៣%) និងវៀតណាម (១២%)[20]។ ប្រទេសទាំងនោះនាំចូលទំនិញមកកម្ពុជា ដូចជាម្ហូបអាហារ សម្ភារៈ និងគ្រឿងសំណង់ជាដើម ហើយថ្លៃនៃប្រភេទទំនិញទាំងអស់នេះ គឺប្រែប្រួលស្របតាមស្ថានភាពអតិផរណារបស់បណ្តាប្រទេសទាំងអស់នោះ។ គួរបញ្ជាក់ផងដែរថា ប្រសិនបើប្រទេសដែលនាំទំនិញចូលមកកម្ពុជា មានកម្រិតអត្រាអតិផរណាកើនឡើង ទន្ទឹមនឹងតម្លៃនៃរូបិយប័ណ្ណរបស់ពួកគេឡើងថ្លៃធៀបនឹងប្រាក់រៀល នោះវានឹងបង្កជាសម្ពាធដល់អតិផរណានៃប្រទេសកម្ពុជាដែលនាំចូលទំនិញទាំងនោះដូចគ្នា។

ជាក់ស្តែងធ្លាប់មានការព្យាករណ៍ពីស្ថានភាពអតិផរណានៅកម្ពុជាក្នុងឆ្នាំ២០២០ ថាអត្រាអតិផរណានឹងអាចកើនឡើងបន្តិច ដោយសារថ្លៃម្ហូបអាហារនាំចូលអាចនឹងកើនឡើង ដែលបណ្តាលមកពីការរំពឹងទុកថាអតិផរណានៅក្នុងប្រទេសវៀតណាម និងថៃដែលជាប្រទេសចម្បងនាំចូលម្ហូបអាហារមកកម្ពុជាកើនឡើងវិញបន្តិច បូករួមទាំងកំណើនថ្លៃក្រុមទំនិញ[21]។ ជារួម ការកើនឡើងនៃម្ហូបអាហារនៅកម្ពុជា គឺបណ្តាលមកពីការនាំចូលពីប្រទេសជិតខាង មានន័យថា បើសិនជាកម្រិតអត្រាអតិផរណានៅប្រទេសជិតខាងដែលកម្ពុជានាំទំនិញចូលកើនឡើង នោះវានឹងជះឥទ្ធិពលដល់អតិផរណាកម្ពុជាដែរ។

**២.៤.២ កត្តាក្នុងស្រុក (កត្តាតម្រូវការ និងរូបិយវត្ថុ)**

មូលហេតុដែលនាំឲ្យមានបម្រែបម្រួលអត្រាអតិផរណានៅកម្ពុជា មិនត្រឹមតែបណ្តាលមកពីកត្តាខាងក្រៅនោះទេ ដោយក្នុងនោះយើងក៏បានសង្កេតឃើញថាកត្តាតម្រូវការ និងរូបិយវត្ថុ ដែលយកមកចរាចរក្នុងប្រទេសក៏បានរួមចំណែកធ្វើឲ្យអត្រាអតិផរណានៅកម្ពុជាប្រែប្រួលផងដែរ។

ដោយសារតែភាពអំណោយផលពីកំណើនសេដ្ឋកិច្ចពិភពលោកបានរួមចំណែកគាំទ្រដល់ការរីកចម្រើនវិស័យសេដ្ឋកិច្ចចម្បងៗរបស់កម្ពុជា ស្របពេលដែលជំនឿទុកចិត្ត និងទស្សនវិស័យវិនិយោគិនមកលើកម្ពុជាមានភាពរឹងមាំ និងវិជ្ជមាន។ កត្តានេះហើយដែលធ្វើឲ្យកម្ពុជាអាចបន្តភាពរីកចម្រើន និងរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុងប្រទេស ដែលបានចូលរួមក្នុងការបង្កើនទំនុកចិត្តវិស័យឯកជនមកលើប្រព័ន្ធធនាគារ ហើយបានរួមចំណែកក្នុងការធ្វើឲ្យរូបិយវត្ថុក្នុងប្រទេសមានសន្ទុះឡើង។

ជាក់ស្តែងក្នុងឆ្នាំ២០១៧ រូបិយវត្ថុទូទៅ (M2) មានកំណើន ២៣% ឆ្នាំលើឆ្នាំ ខ្ពស់ជាងកំណើនឆ្នាំ ១៨% (២០១៦) និងកំណើនមធ្យមប្រចាំឆ្នាំក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ (២០%)។ ចំពោះការប្រើ

[20] របាយការណ៍ឆមាសទី ១ និងទិសដៅការងារឆមាសទី ២ ឆ្នាំ២០១៥ (ធនាគារជាតិនៃកម្ពុជា)

[21] របាយការណ៍ប្រចាំឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១ (ធនាគារជាតិនៃកម្ពុជា)

ប្រាស់ប្រាក់រៀល រូបិយវត្ថុក្នុងចរាចរណ៍មានកំណើនខ្ពស់ប្រមាណ ២៥% ធៀបនឹង ៩% នៅឆ្នាំមុន រួមចំណែកចម្បងដោយសារកំណើននៃការធ្វើអន្តរាគមន៍ផ្គត់ផ្គង់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការក្នុងទីផ្សារ និងការបង្កើនចំណាយរបស់រាជរដ្ឋាភិបាល ជាពិសេសទៅលើការបង្កើនប្រាក់ខែមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ[22]។

រីឯឆ្នាំ២០១៨ រូបិយវត្ថុទូទៅ (M2) បន្តមានកំណើន ២៤.២% ខ្ពស់ជាងកំណើនឆ្នាំមុនបន្តិច និងកំណើនជាមធ្យមប្រចាំឆ្នាំក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ (២២%)។ កំណើនរូបិយវត្ថុទូទៅនេះ បន្តមានកម្រិតសមស្របនឹងការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ច[23]។ ដោយប្រាក់រៀលដែលចរាចរណ៍ក្នុងឆ្នាំ២០១៨ មានកំណើន ១៤.១% ទាបជាងកំណើននៅឆ្នាំមុន។

ដូចនេះ អត្រាកំណើនរូបិយវត្ថុទូទៅ និងអត្រាកំណើនរូបិយវត្ថុក្នុងចរាចរណ៍ គឺអាចបង្កទៅជាសម្ពាធ និងនាំឲ្យមានបម្រែបម្រួលទៅដល់អត្រាអតិផរណាកម្ពុជាបាន ទោះបីជាពេលខ្លះ អត្រាកំណើនរូបិយវត្ថុទូទៅ និងអត្រាកំណើនរូបិយវត្ថុក្នុងចរាចរណ៍ស្ថិតក្នុងស្ថានភាពគ្រប់គ្រងបានក៏ដោយ ក៏វាអាចនឹងវិវត្តទៅជាហានិភ័យនៅពេលក្រោយក៏ថាបាន។

## ២.៥ ផលប៉ះពាល់នៃអតិផរណា

### ២.៥.១ ប៉ះពាល់ដល់បុគ្គលិកដែលទទួលបានចំណូលទាប

ការកើតមានឡើងនៃអតិផរណា បានជះឥទ្ធិពល និងផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់អ្នកដែលទទួលបានប្រាក់ចំណូលទាប ជាពិសេសអ្នកដែលធ្វើការតាមរោងចក្រ ព្រោះថាប្រាក់ចំណូលដែលពួកគេទទួលបានមិនអាចផ្គត់ផ្គង់គ្រប់គ្រាន់សម្រាប់ការចំណាយលើការប្រើប្រាស់ប្រចាំថ្ងៃរបស់គេបានទេ ដូចជា ការចំណាយលើម្ហូបអាហារ ទឹកភ្លើង ប្រេងឥន្ធនៈសម្រាប់ការធ្វើដំណើរជាដើម។ មិនត្រឹមតែប៉ុណ្ណោះ ប្រសិនបើអតិផរណាបន្តអូសបន្លាយក្នុងរយៈពេលវែង វាអាចនឹងធ្វើឲ្យប៉ះពាល់ដល់ការសន្សំរបស់ពួកគេផងដែរ ព្រោះថាការបន្តបង្កើនការចំណាយក្នុងរយៈពេលយូរទៀតអាចបង្កទៅជាផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ។

### ២.៥.២ ប៉ះពាល់ដល់ប្រជាពលរដ្ឋទូទៅ

ចំពោះប្រជាពលរដ្ឋទូទៅ ដូចជា អាជីវករ កសិករ សិស្ស និស្សិត ក៏ទទួលរងផលប៉ះពាល់យ៉ាងអាក្រក់ពីអតិផរណាដូចគ្នា។ ឧទាហរណ៍ កសិករដែលប្រកបរបរធ្វើស្រែចំការ នៅពេលមានអតិផរណាកើតឡើង នោះការចំណាយរបស់គាត់ក្នុងការទិញវត្ថុធាតុដើមរួមមានដូចជា គ្រាប់ពូជ ជី ថ្នាំសម្រាប់សត្វល្អិត និងវត្ថុធាតុដើមផ្សេងៗទៀតមកធ្វើស្រែចំការមានតម្លៃកើនឡើងខ្ពស់មុន។ នេះជាការប៉ះពាល់យ៉ាងខ្លាំងដល់ប្រជាកសិករគ្រប់រូប

[22] របាយការណ៍ប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ (ធនាគារជាតិនៃកម្ពុជា)

[23] របាយការណ៍ប្រចាំឆ្នាំ២០១៨ និងទិសដៅការងារឆ្នាំ២០១៩ (ធនាគារជាតិនៃកម្ពុជា)

ព្រោះថាពេលខ្លះការចំណាយរបស់ពួកគាត់លើវត្ថុធាតុដើមខ្ពស់ រីឯទិន្នផលដែលទទួលបានពីការប្រមូលផល បែរជាលក់បានក្នុងតម្លៃទាបទៅវិញ។ អាជីវករក៏ដូចគ្នា ធម្មតានៅពេលដែលអតិផរណាកើតមានឡើង ទំនិញ ឬ សេវាកម្មដែលគេធ្លាប់ផ្គត់ផ្គង់នៅលើទីផ្សាក្នុងតម្លៃទាប បែរជាមកលក់ ឬផ្គត់ផ្គង់ក្នុងតម្លៃមួយដែលខ្ពស់វិញ។

### ២.៥.៣ ប៉ះពាល់ដល់មន្ត្រីរាជការដែលចូលនិវត្តន៍

ត្រង់ចំណុចនេះ អតិផរណាបានជិះឥទ្ធិពលយ៉ាងខ្លាំងដល់មន្ត្រីរាជការដែលចូលនិវត្តន៍ ព្រោះថាមន្ត្រីចូលនិវត្តន៍ ជាមនុស្សចាស់ជរាដែលទទួលបានបៀវត្សពីរាជរដ្ឋាភិបាលក្នុងប្រមាណទឹកប្រាក់ណាមួយ ដូចនេះ នៅពេលដែលមានអតិផរណាកើតឡើង នោះនឹងធ្វើឲ្យការចំណាយរបស់ពួកគាត់កើនឡើងបន្ថែម ខណៈប្រាក់បៀវត្សដែលគាត់ទទួលបានពីរដ្ឋាភិបាលស្ថិតក្នុងប្រមាណថេរណាមួយ។ បានជាចំណាយរបស់ពួកគាត់មានការកើនឡើង នោះក៏ដោយសារតែថ្លៃទំនិញ ឬសេវាកម្មប្រើប្រាស់ប្រចាំថ្ងៃមានការកើនឡើងជាងមុន ដែលនេះជាការបង្កផលប៉ះពាល់ដល់ការសន្សំរបស់មន្ត្រីចូលនិវត្តន៍ដែលទទួលបានបៀវត្ស រួមទាំងប៉ះពាល់ដល់ជីវភាពក្រុមគ្រួសាររបស់ពួកគាត់ផងដែរ ដោយកត្តាចម្បងបណ្តាលមកពីការចំណាយប្រចាំថ្ងៃមានការកើនឡើង។

## ២.៦ ដំណោះស្រាយ

### ២.៦.១ ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់

កម្ពុជារក្សាបានស្ថិរភាពថ្លៃ និងតម្លៃប្រាក់រៀលល្អប្រសើរ ដែលបានរួមចំណែករក្សាស្ថិរភាពសេដ្ឋកិច្ច និងគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច។ ស្ថិតនៅក្នុងស្ថានភាពដែលសេដ្ឋកិច្ចរបស់កម្ពុជា មានអត្រាដុល្លារូបនីយកម្មខ្ពស់ រាជរដ្ឋាភិបាលមានគោលនយោបាយរូបិយវត្ថុ ដើម្បីរក្សាស្ថិរភាពថ្លៃដែលត្រូវពឹងជាចម្បងលើការរក្សាឲ្យបាននូវស្ថិរភាពអត្រាប្តូរប្រាក់។ ស្ថិរភាពរបស់អត្រាប្តូរប្រាក់អាចជួយរក្សាអំណាយទិញរបស់ប្រាក់រៀល និងរួមចំណែករក្សាអត្រាអតិផរណាឲ្យស្ថិតក្នុងកម្រិតទាបអាចគ្រប់គ្រងបាន។ ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ដោយធ្វើការផ្គត់ផ្គង់ប្រាក់រៀលស្របតាមស្ថានភាពទីផ្សារ ក្នុងគោលបំណងបញ្ចៀសនូវបម្រែបម្រួលខ្លាំងនៃអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកដែលកើតចេញពីកត្តារដូវកាល ដូចជាតម្រូវការប្រាក់រៀលសម្រាប់បង់ពន្ធ និងការទិញកសិផលជាដើម។ នៅក្នុងឆ្នាំ២០១៧ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបន្តមានស្ថិរភាព ដោយអត្រាបានប្រែប្រួលស្ថិតនៅក្នុងចន្លោះ -0.៨% ទៅ 0.១% ដែលអត្រាប្តូរប្រាក់មានកម្រិតជាមធ្យម ៤០៥០ រៀលក្នុងមួយដុល្លារអាមេរិក បានកើនឡើងថ្លៃ 0.២% ធៀបនឹងឆ្នាំមុន ដែលបណ្តាលមកពីកំណើនតម្រូវការប្រាក់រៀល[24]។ ក្នុងឆ្នាំ២០១៨ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ក៏បន្តមានស្ថិរភាព ដោយក្នុងរង្វង់ប្រមាណ ៤០៥០ រៀលក្នុងមួយដុល្លារអាមេរិក ដោយប្រហាក់ប្រហែលនឹងឆ្នាំ

[24] របាយការណ៍ប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ (ធនាគារជាតិនៃកម្ពុជា)

២០១៧[25]។ ឆ្នាំ២០១៩ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ជាមធ្យមប្រមាណ ៤០៥៥ រៀលក្នុងមួយដុល្លារអាមេរិក បានប្រែប្រួលបន្តិចបន្តួចទៅតាមកត្តារដូវកាល ជាពិសេសកំណើនតម្រូវការប្រាក់រៀលសម្រាប់បង់ពន្ធ (កើន ២៥% ក្នុងរយៈពេល ១០ ខែ ដើមឆ្នាំ២០១៩)[26]។

យើងបន្តសង្កេតឃើញថានៅក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ ប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបន្តមានស្ថិរភាព ទោះបីជាបានថយថ្លៃបន្តិចបន្តួចក្តី ដោយមានកម្រិតជាមធ្យមក្នុងរង្វង់ ៤០៩០ (ឆ្នាំ២០២០) និង ៤០៩៩ (ឆ្នាំ២០២១) រៀលក្នុងមួយដុល្លារអាមេរិក។

បើទោះបីជាប្រាក់រៀល បានប្រែប្រួលថ្លៃថយចុះបន្តិចបន្តួចក្តីក្នុងរយៈពេលពីរឆ្នាំ (២០២០ និង ២០២១) ក៏អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបន្តមានស្ថិរភាព និងស្ថិតក្នុងស្ថានភាពល្អប្រសើរដែរ ដែលនេះដោយសារ តែធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តន៍គោលនយោបាយរូបិយវត្ថុ (ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់)ប្រកបដោយភាពប្រុងប្រយ័ត្ន និងទន់ភ្លន់ ដើម្បីបន្តរក្សាអត្រាអតិផរណាឲ្យស្ថិតក្នុងកម្រិតទាប តាមរយៈការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ និងគ្រប់គ្រង់ការផ្គត់ផ្គង់រូបិយវត្ថុស្របតាមការរីកចម្រើនសកម្មភាពសេដ្ឋកិច្ចជាតិ។

### ២.៦.២ គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ

ការដែលធនាគារជាតិនៃកម្ពុជា អាចរក្សាបាននូវស្ថិរភាពល្អប្រសើររវាងអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ក៏ដោយសារតែរាជរដ្ឋាភិបាលបានអនុវត្តន៍គោលនយោបាយរូបិយវត្ថុយ៉ាងច្បាស់លាស់ ថែមទាំងប្រតិបត្តិពោរពេញដោយការប្រុងប្រយ័ត្ន ជាពិសេសក្នុងការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុលើទីផ្សារ ព្រោះថាបើកាលណារាជរដ្ឋាភិបាលធ្វើការផ្គត់ផ្គង់រូបិយវត្ថុមិនស្របទៅតាមស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេស ឬលើសពីតម្រូវការចាំបាច់ នោះនឹងធ្វើឲ្យតម្លៃលុយធ្លាក់ចុះ ដែលនាំឲ្យអត្រាប្តូរប្រាក់មានការប្រែប្រួលខ្លាំង រហូតដល់អាចបង្កជាសម្ពាធដល់អត្រាអតិផរណាបាន។ នៅក្នុងឆ្នាំ២០២០ ដែលស្ថិតក្នុងការរីករាលដាលនៃជំងឺឆ្លងកូវីដ ១៩ សកម្មភាពសេដ្ឋកិច្ចក្នុងស្រុកមានការថយចុះ និងវិស័យខាងក្រៅរងការធ្លាក់ចុះយ៉ាងខ្លាំង ដែលការធ្លាក់ចុះនៃសកម្មភាពសេដ្ឋកិច្ចក្នុងប្រទេសបានធ្វើឲ្យតម្លៃប្រាក់រៀលធ្លាក់ថ្លៃបន្តិចបន្តួច។

ប៉ុន្តែ ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍ដោយលក់ប្រាក់ដុល្លារអាមេរិក ៨០,២ លានដុល្លារ (៤ លើក) ទៅគ្រឹះស្ថានធនាគារ និងអាជីវករប្តូរប្រាក់ និងបានលក់ប្រាក់រៀល ឆ្លើយតបនឹងតម្រូវការចំនួន ៦៩,៥ ប៊ីលានរៀល (១៧ លានដុល្លារអាមេរិក)[27]។ ធនាគារជាតិនៃកម្ពុជាក៏បានលក់ប្រាក់ដុល្លារអាមេរិកសុទ្ធ ១៤៧,១ លានដុល្លារអាមេរិក (ទិញមាន ៨០,៣ លានដុល្លារអាមេរិក) ទៅស្ថាប័នរដ្ឋ ដោយការធ្វើអន្តរាគមន៍នេះបានកាត់

[25] របាយការណ៍ប្រចាំឆ្នាំ២០១៨ និងទិសដៅការងារឆ្នាំ២០១៩ (ធនាគារជាតិនៃកម្ពុជា)
[26] របាយការណ៍ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០ (ធនាគារជាតិនៃកម្ពុជា)
[27] របាយការណ៍ប្រចាំឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១ (ធនាគារជាតិនៃកម្ពុជា)

បន្ថយនិន្នាការថយថ្លៃប្រាក់រៀល និងបានរក្សាតម្លៃប្រាក់រៀលឲ្យមានស្ថិរភាពល្អវិញ ដែលបានរួមចំណែកក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច[28]។

ការចាត់ចែង និងគ្រប់គ្រងក្នុងការផ្គត់ផ្គង់រូបិយវត្ថុ ស្របទៅតាមស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេស និង ស្របតាមតម្រូវការប្រាក់ដើម្បីចរាចរនៅលើទីផ្សារ បានបង្ហាញឲ្យឃើញថា រាជរដ្ឋាភិបាលមានគោលនយោបាយរូបិយវត្ថុច្បាស់លាស់ក្នុងការដោះស្រាយនៅពេលដែលសេដ្ឋកិច្ចជាតិមានវិវត្តកើតឡើង។

### ២.៦.៣ ការអនុវត្តគោលនយោបាយដំឡើងប្រាក់បៀវត្ស

ជារួម នៅឆ្នាំ ២០១៩ បៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ មានការផ្លាស់ប្តូរដូចខាងក្រោម[29]៖

- **បៀវត្សមន្ត្រីរាជការស៊ីវិល៖** នឹងត្រូវបានដំឡើងពីចំនួន ១ ០១៤ ៤៥០ រៀល នៅឆ្នាំ២០១៨ ដល់ប្រមាណ ១ ០៧០ ១០០ រៀល នៅខែមេសា ឆ្នាំ ២០១៩, ហើយនឹងត្រូវបានដំឡើងដល់ប្រមាណ ១ ១០០ ១០០ រៀល ចាប់ពីខែមេសា ឆ្នាំ ២០១៩។
- **បៀវត្សគ្រូបង្រៀន និងគ្រូពេទ្យ៖** នឹងត្រូវបានដំឡើងពីចំនួន ១ ១១៤ ៤៥០ រៀល នៅឆ្នាំ២០១៨ ដល់ប្រមាណ ១ ១៧០ ១០០ រៀល នៅខែមករា ឆ្នាំ២០១៩ ហើយនឹងត្រូវបានដំឡើងដល់ប្រមាណ ១ ២០០ ១០០ រៀល ចាប់ពីខែមេសា ឆ្នាំ២០១៩។
- **បៀវត្សនគរបាល (ពលបាលត្រី)៖** នឹងត្រូវបានដំឡើងពីចំនួន ១ ០៩៨ ៩២៧ រៀល (គិតបញ្ចូលទាំងរបបអង្ករ) នៅឆ្នាំ២០១៨ ដល់ប្រមាណ ១ ១៥៥ ៥៧៧ រៀល (គិតបញ្ចូលទាំងរបបអង្ករ) នៅខែមករា ឆ្នាំ ២០១៩ ហើយនឹងត្រូវដំឡើងដល់ប្រមាណ ១ ១៨៤ ៥៧៧ រៀល (គិតបញ្ចូលទាំងរបបអង្ករ) ចាប់ពីខែមេសា ឆ្នាំ២០១៩។
- **បៀវត្សយោធិន (ពលទោ)៖** នឹងត្រូវបានដំឡើងពីចំនួន ៩៧៦ ៥៥០ រៀល (មិនគិតបញ្ចូលរបបអង្ករ) នៅឆ្នាំ២០១៨ ដល់ប្រមាណ ១ ០២៥ ៩០០ រៀល (មិនគិតបញ្ចូលរបបអង្ករ) នៅខែមករា ឆ្នាំ២០១៩ ហើយនឹងត្រូវដំឡើងដល់ ១ ០៥៥ ៩០០ រៀល ចាប់ពីខែមេសា ឆ្នាំ២០១៩ បើគិតបញ្ចូលរបបអង្ករ ត្រូវជាប្រមាណ ១ ១១៤ ៣៧៧ រៀល។

[28] របាយការណ៍ប្រចាំឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១ (ធនាគារជាតិនៃកម្ពុជា)

[29] ខ្លឹមសារសង្ខេបប្រតិបត្តិស្តីពីសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០១៩

# ជំពូកទី ៣
# ស្ថានភាពអតិផរណានៃប្រទេសថៃ

# ជំពូកទី ៣

# ស្ថានភាពអតិផរណានៃប្រទេសថៃ

នៅក្នុងជំពូកទី ៣ គឺយើងនឹងធ្វើការសិក្សាស៊ីជម្រៅអំពីស្ថានភាពអតិផរណានៅក្នុងប្រទេសថៃ ដោយចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២១ ដូចទៅនឹងប្រទេសកម្ពុជាដែរ ដោយក្នុងនោះ យើងនឹងធ្វើការបកស្រាយលម្អិតអំពីស្ថានភាពអតិផរណាតាមឆ្នាំនីមួយៗ, មូលហេតុនៃបម្រែបម្រួលអតិផរណានៅក្នុងប្រទេសថៃ, ផលប៉ះពាល់មកលើសេដ្ឋកិច្ច រួមទាំងយុទ្ធសាស្ត្រ និងដំណោះស្រាយដែលរាជរដ្ឋាភិបាលថៃអនុវត្តក្នុងការទប់ស្កាត់ទៅលើបញ្ហាអតិផរណា។

## ៣.១ ស្ថានភាពទូទៅនៃប្រទេសថៃ

ព្រះរាជាណាចក្រថៃ គឺជាប្រទេសមួយដែលមានព្រំប្រទល់ជាប់ព្រះរាជាណាចក្រកម្ពុជា និងជាសមាជិកនៃសមាគមន៍អាស៊ាន (ASEAN) ផងដែរ។ ប្រទេសថៃ គឺជាប្រទេសមួយដែលមានខឿនសេដ្ឋកិច្ចរីកចម្រើនខ្លាំងក្នុងចំណោម សមាជិកសមាគមន៍អាស៊ាន ទោះបីប្រទេសនេះបានជួបប្រទះនឹងវិបត្តិសេដ្ឋកិច្ចពីមុនក្តី។

ក្នុងរយៈពេល ៤ ទស្សវត្សចុងក្រោយនេះ ប្រទេសថៃមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច ដោយផ្លាស់ប្តូរពីប្រទេសដែលមានចំណូលទាបទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងរយៈពេលតិចជាងមួយជំនាន់។ ទោះជាយ៉ាងណាក៏ដោយ ទស្សនវិស័យកំណើនពីការនាំចេញដែលបានអនុវត្តកន្លងទៅនេះ បានធ្វើឲ្យមានកំណើនសេដ្ឋកិច្ចរបស់ប្រទេសថៃ ហាក់ដូចជាមានការថយចុះគួរឱ្យកត់សម្គាល់ ដោយសារការជាប់គាំងនៃផលិតភាព។ ការវិនិយោគឯកជនបានធ្លាក់ចុះពីជាង ៤០% ក្នុងឆ្នាំ ១៩៩៧ មកនៅត្រឹមតែ ១៦.៩% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៩ ខណៈលំហូរនៃការវិនិយោគផ្ទាល់ពីបរទេស និងការចូលរួមនៅក្នុងខ្សែសង្វាក់តម្លៃសកលបានបង្ហាញពីភាពជាប់គាំង។ វិស័យផលិតកម្មបង្ហាញពីការឆ្ពោះទៅមុខបន្តិចបន្តួច ប៉ុន្តែនៅតែពឹងផ្អែកលើការនាំចូលវត្ថុធាតុដើមពីបរទេស ហើយប្រឈមមុខនឹងការប្រកួតប្រជែងកាន់តែខ្លាំងឡើងពីប្រទេសជិតខាងក្នុងតំបន់។ វិស័យទេសចរណ៍ ដែលជាផ្នែកយ៉ាងសំខាន់របស់ប្រទេសក្នុងវិស័យសេវាកម្ម បង្ហាញការអភិវឌ្ឍន៍តិចតួច បើប្រៀបធៀបទៅនឹងសេវាកម្មផ្សេងទៀត។

វឌ្ឍនភាពនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រទេសថៃបានធ្លាក់ចុះចាប់ពីឆ្នាំ២០១៥ តទៅ ដោយឆ្លុះបញ្ចាំងពីការធ្លាក់ចុះនៃសេដ្ឋកិច្ច និងនៅទ្រឹងចំពោះវិស័យកសិដ្ឋាន វិស័យអាជីវកម្ម និងចំណូលប្រាក់ឈ្នួល។ នៅក្នុងឆ្នាំ២០១៥ សេដ្ឋកិច្ចប្រទេសថៃ គឺត្រូវបានធ្លាក់ចុះ ដោយសារការធ្វើរដ្ឋប្រហារនៅឆ្នាំ២០១៤ និង បញ្ហានយោបាយដែលកើតមានបន្តបន្ទាប់។ យើងឃើញថាបន្ទាប់ពីការធ្វើរដ្ឋប្រហារបន្ទាប់ពីវិបត្តិនយោបាយជាច្រើនខែ យោធាថៃបានចូលកាន់កាប់ប្រទេស ហើយព្រឹទ្ធសភា និងរដ្ឋាភិបាលត្រូវបានរំលាយចោល។ ជាលទ្ធផលសេដ្ឋកិច្ចរបស់ប្រទេសថៃបានជួបប្រទះនឹងការធ្លាក់ចុះភ្លាមៗ កំណើនផលិតផលក្នុងស្រុកសរុប និងអតិផរណា

បានធ្លាក់ចុះខណៈដែលភាពអត់មានការងារធ្វើ ដែលជាធម្មតាត្រូវបានពន្យារពេលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ ភាពក្រីក្រត្រូវបានប៉ាន់ប្រមាណថានឹងនៅទ្រឹងនៅឆ្នាំ២០២១ ចំពេលការងើបឡើងវិញនៃទីផ្សារការងារយឺត និងការបញ្ឈប់បន្តិចម្តងៗពីវិធានការណ៍សង្គ្រោះរបស់រដ្ឋាភិបាល។ តាមរបាយការណ៍ស្ទង់មតិធនាគារពិភពលោកដែលបានអនុវត្តពីខែមេសាដល់ខែមិថុនាឆ្នាំ២០២១ បានប៉ាន់ប្រមាណថាជាង ៧០% នៃគ្រួសារបានជួបប្រទះនឹងការធ្លាក់ចុះនៃប្រាក់ចំណូលរបស់ពួកគេចាប់តាំងពីខែមីនា ឆ្នាំ២០២០ ដោយក្រុមស្ថិតនៅក្នុងភាពក្រីក្រត្រូវបានរងផលប៉ះពាល់ខ្លាំងបំផុត។

ជាអកុសល ការរាតត្បាត នៃជម្ងឺកូវីត ១៩ បានធ្វើឱ្យសេដ្ឋកិច្ចថែចុះមក -៦.២% ក្នុងឆ្នាំ២០២០ ដោយសារការធ្លាក់ចុះនៃតម្រូវការខាងក្រៅដែលប៉ះពាល់ដល់វិស័យពាណិជ្ជកម្ម និងវិស័យទេសចរណ៍ ដែលការរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ និងការថយចុះនៃការប្រើប្រាស់ក្នុងស្រុក។ បន្ទាប់ពីទទួលរងការធ្លាក់ចុះដ៏អាក្រក់បំផុតចាប់តាំងពីវិបត្តិហិរញ្ញវត្ថុអាស៊ីក្នុងឆ្នាំ២០២០ សេដ្ឋកិច្ចបានមានការរីកចម្រើនក្នុងអត្រា ១.៦% ក្នុងឆ្នាំ ២០២១។ ទោះបីមានរលកនៃការរាតត្បាតជម្ងឺនេះចំនួនបួនដងក៏ដោយ ហើយមិនត្រូវបានរំពឹងថានឹងងើបឡើងវិញដល់កម្រិតមុន កូវីត ១៩ រហូតដល់ឆ្នាំ២០២៣។ ជំងឺរាតត្បាតកូវីត ១៩ ក៏បានបង្កើតបញ្ហាប្រឈមបន្ថែមមួយចំនួននៅក្នុងទីផ្សារការងារផងដែរ។ ផលប៉ះពាល់ចម្បង គឺការកើនឡើងនៃអត្រាគ្មានការងារធ្វើដោយនៅត្រីមាសទីមួយនៃឆ្នាំ២០២១ មានការថយចុះការងារចំនួន ៧១០,០០០ បើប្រៀបធៀបទៅនឹងឆ្នាំ២០២០។

## ៣.២ អត្រាអតិផរណាប្រចាំឆ្នាំជាភាគរយ

តារាង ៣.១៖ តារាងបម្រែបម្រួលអត្រាអតិផរណាប្រចាំឆ្នាំជាភាគរយឆ្នាំលើឆ្នាំ៖

| **បម្រែបម្រួលអត្រាអតិផរណាឆ្នាំលើឆ្នាំ** | | | | | | | |
|---|---|---|---|---|---|---|---|
| **គិតជាភាគរយ** | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
| មករា | -០.៤ | -០.៥ | ១.៦ | ០.៧ | ០.៣ | ១.១ | -០.៣ |
| កុម្ភៈ | -០.៥ | -០.៥ | ១.៤ | ០.៤ | ០.៧ | ០.៧ | -១.២ |
| មីនា | -០.៦ | -០.៥ | ០.៨ | ០.៨ | ១.២ | -០.៥ | -០.១ |
| មេសា | -១.០ | ០ .១ | ០.៤ | ១.១ | ១.២ | -៣.០ | ៣.៤ |
| ឧសភា | -១.៣ | ០.៥ | -០.០៤ | ១.៥ | ១.២ | -៣.៤ | ២.៤ |
| មិថុនា | -១.១ | ០.៤ | -០.០៥ | ១.៤ | ០.៩ | -១.៦ | ១.២ |
| កក្កដា | -១.១ | ០.១ | ០.១ | ១.៥ | ១.០ | -១.០ | ០.៤ |
| សីហា | -១.២ | ០.៣ | ០.៣ | ១.៦ | ០.៥ | -០.៥ | -០.០២ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| កញ្ញា | -១.១ | ០.៤ | ០.៩ | ១.៣ | ០.៣ | -០.៧ | ១.៧ |
| តុលា | -០.៨ | ០.៣ | ០.៨ | ១.២ | ០.១ | -០.៥ | ២.៤ |
| វិច្ឆិកា | -១.០ | ០.៦ | ១.០ | ០.៩ | ០.២ | -០.៤ | ២.៧ |
| ធ្នូ | -០.៩ | ១.១ | ០.៩ | ០.៤ | ០.៩ | -០.៣ | ២.២ |
| **ជាមធ្យមភាគ** | -០.៩ | ០.១៩ | ០.៦៧ | ១.០៧ | ០.៧១ | -០.៨៥ | ១.២៣ |

ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ (ធនាគារកណ្តាលនៃថៃ) BOT Annual Report, (Bank of Thailand) from 2015-2021




តាមរយៈក្រាហ្វិក ៣.១ ខាងលើ យើងសង្កេតឃើញថា អត្រាអតិផរណាឆ្នាំលើឆ្នាំជាមធ្យមប្រចាំឆ្នាំនីមួយៗ គិតចាប់តាំងពីឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០២១ គឺមានការប្រែប្រួលគួរឲ្យកត់សម្គាល់។ ដោយចាប់ពីឆ្នាំ ២០១៥ ដល់ឆ្នាំ២០១៦ កម្រិតអត្រាអតិផរណាមានការប្រែប្រួលពី -០.៩% ទៅ ០.១៩% ហើយការកើនឡើងក្នុងអត្រាអតិផរណា ក្នុងឆ្នាំ២០១៦ នេះ គឺជាចំណុចចាប់ផ្តើមនៃការរីកចម្រើនផ្នែកសេដ្ឋកិច្ចឡើងវិញ បន្ទាប់ពីការធ្វើរដ្ឋប្រហារនៅឆ្នាំ២០១៤។ អត្រាអតិផរណាក្នុងឆ្នាំបន្ទាប់ៗ គឺមានការកើនឡើងសន្សឹមៗ ដោយនៅក្នុងឆ្នាំ ២០១៧ ក្នុងអត្រា ០.៦៧% ក្នុងឆ្នាំ២០១៨ ក្នុងអត្រា ១.០៧%។ ប៉ុន្តែនៅក្នុងឆ្នាំ២០១៩ យើងសង្កេតឃើញថា អត្រាអតិផរណាត្រូវបានថយចុះមកត្រឹម ០.៧១% ដោយសារតែការធ្លាក់ចុះនៃការនាំចេញ ដែលប៉ះពាល់ដល់ការងារ និងតម្រូវការក្នុងស្រុក។

ប៉ុន្តែជាអកុសល ចាប់តាំងពីមានការរីករាលដាលនៃជំងឺឆ្លងកូវីដ ១៩ នៅទូទាំងសកលលោកមក យើងសង្កេតឃើញថា អត្រាអតិផរណានៅក្នុងប្រទេសកាន់តែធ្លាក់ចុះ រហូតមកត្រឹម -០.៨៥% នៅក្នុងឆ្នាំ២០២០ ប៉ុន្តែនៅឆ្នាំ២០២១ សេដ្ឋកិច្ចប្រទេសថៃ មានការរីកចម្រើនឡើងវិញដោយបានបញ្ចប់នូវការដាក់បម្រាមគោចរដែលធ្វើឲអត្រាអតិផរណាកើនឡើងមក ១.២៣% នៅឆ្នាំនោះ។

## ៣.៣ ស្ថានភាពអតិផរណាប្រចាំឆ្នាំនីមួយៗ

### ៣.៣.១ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៥

ស្ថានភាពអតិផរណាក្នុងឆ្នាំ២០១៥ ការធ្លាក់ចុះជាខ្លាំងបើធៀបនឹងឆ្នាំ២០១៤ ដោយសារការធ្លាក់ចុះនៃថ្លៃប្រេង, និងការធ្វើរដ្ឋប្រហារនៅក្នុងត្រីមាសទី២ ឆ្នាំ២០១៤។ អស្ថិរភាពនយោបាយបានធ្វើឲ្យសេដ្ឋកិច្ចរបស់ប្រទេសថៃបានជួបប្រទះនឹងការធ្លាក់ចុះភ្លាមៗ រហូតដល់អតិផរណារួមគិតជាមធ្យមស្ថិតក្នុងកម្រិតទាបត្រឹម -០.៩% ធៀបនឹងឆ្នាំ២០១៤ (១.៩%) និងទាបជាងរំពឹងទុករបស់រាជរដ្ឋាភិបាល (២.៥%)។

ក្រាហ្វិក ៣.២ : អតិផរណា




ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ ២០១៥ (ធនាគារកណ្តាលនៃថៃ)

បើពិនិត្យមើលការប្រែប្រួលក្នុងឆ្នាំ២០១៥ យើងឃើញថា អត្រាអតិផរណាជាមធ្យម គឺស្ថិតនៅក្រោមបន្ទាត់ ០%។ នៅត្រីមាសទី១ គឺមានអត្រាអតិផរណា -០.៥% នៅត្រីមាសទី២ មានអត្រា -១.១% នៅត្រីមាសទី ៣ មានអត្រា -១.១% និងនៅត្រីមាសទី ៤ មានអត្រា -០.៩%។ សេដ្ឋកិច្ចប្រទេសថៃ ត្រូវបានរារាំងដោយការបន្តធ្លាក់ចុះនៃការនាំចេញ ទាំងតម្លៃ និងបរិមាណ។ តម្លៃនាំចេញបានធ្លាក់ចុះស្របទៅតាមការធ្លាក់ចុះតម្លៃប្រេង ខណៈបរិមាណនាំចេញបានធ្លាក់ចុះដោយសារតែសេដ្ឋកិច្ចរបស់ប្រទេសដៃគូពាណិជ្ជកម្មដ៏សំខាន់របស់ប្រទេសថៃមានការធ្លាក់ចុះ ជាពិសេសគឺ ប្រទេសចិន និងអាស៊ាន។

ជាលទ្ធផល វិស័យផលិតកម្មរបស់ប្រទេសថៃនៅតែស្ថិតក្នុងកម្រិតទាប។ ជារួម អតិផរណាបានបង្ហាញពីតួលេខអវិជ្ជមានដោយសារតែការធ្លាក់ចុះយ៉ាងខ្លាំងនៃតម្លៃប្រេង។ ទោះយ៉ាងណាក៏ដោយ ហានិភ័យនៃបរិត្តផរណានៅតែមានកម្រិតទាបដោយសារអតិផរណាស្នូលនៅតែមានភាពវិជ្ជមាន ហើយការរំពឹងទុកអតិផរណា គឺជិតដល់គោលដៅអតិផរណានៃគោលនយោបាយរូបិយវត្ថុ។

### ៣.៣.២ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៦

ក្នុងឆ្នាំ២០១៦ អត្រាអតិផរណាឆ្នាំលើឆ្នាំបានកើនឡើងវិញ ពីអត្រាអតិផរណាអវិជ្ជមាន មកអត្រាអតិផរណាវិជ្ជមាន ដោយមានកម្រិតជាមធ្យមប្រមាណ 0.១៩% ធៀបនឹងឆ្នាំ២០១៥ (-0.៩%)។

ក្រាហ្វិក ៣.៣ : អតិផរណា




ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ ២០១៦ (ធនាគារកណ្តាលនៃថៃ)

បើយើងមើលទៅលើក្រាហ្វិក យើងឃើញថា នៅត្រីមាសទី១ អត្រាអតិផរណាគឺស្ថិតនៅក្រោមបន្ទាត់ 0 នៅឡើយ គឺនៅត្រឹម -0.៥% ដែលស្មើរទៅនឹងត្រីមាសទី១ នៅឆ្នាំ២០១៥ ផងដែរ។ យ៉ាងណាមិញ នៅត្រីមាសទី២ អត្រាអតិផរណាកើនមកត្រឹម 0.៣% ហើយនៅត្រីមាសទី៣ អត្រាអតិផរណាគឺមានដដែល ដែលមានអត្រាអតិផរណា 0.៣% ដូចគ្នា។ ប៉ុន្តែនៅត្រីមាសទី៤ អត្រាអតិផរណាមានការកើនឡើងបន្តិច គឺកើនមក 0.៧%។

ការងើបឡើងវិញនៃការនាំចេញ កាន់តែបង្ហាញឲ្យឃើញកាន់តែច្បាស់ក្នុងត្រីមាសទីពីរនៅក្នុងឆ្នាំនេះ ដោយសារផលិតករចិនមួយចំនួនបានផ្លាស់ប្តូរមូលដ្ឋានផលិតកម្មរបស់ពួកគេទៅប្រទេសថៃដើម្បីបញ្ចៀសវិធានការប្រឆាំង "ការបោះចោល" ដែលបានដាក់ដោយសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប "ការបោះចោល" នេះសំដៅទៅលើស្ថានភាព ដែលតម្លៃនៃផលិតផលនៅពេលលក់នៅក្នុងប្រទេសនាំចូល គឺទាបជាងតម្លៃផលិតផលនោះនៅក្នុងទីផ្សារនៃប្រទេសនាំចេញ។ ហេតុផលមួយទៀតគឺ ផលិតផលដែលទាក់ទង នឹងប្រេងឥន្ធនៈ ដែលតម្លៃរបស់វាបានត្រលប់មកវិញទាំងតម្លៃ និងលក្ខខណ្ឌបរិមាណ។

ជារួម អតិផរណាបានត្រឡប់មកវិជ្ជមានវិញ ដូចជាតម្លៃថាមពលក្នុងស្រុកដែលកាន់តែមានស្ថេរភាព និងកើនឡើងជាលំដាប់ស្របជាមួយនឹងតម្លៃប្រេងពិភពលោកកាន់តែខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ ក៏កម្រិតអតិផរណាស្នូលនៅតែមានកម្រិតទាបដូចឆ្នាំមុនដោយសារការកើនឡើងនេះ គឺកើនឡើងបន្តិចម្តងៗដែលធ្វើឲ្យមានការងើបឡើងវិញនៃលក្ខខណ្ឌសេដ្ឋកិច្ចផងដែរ ។

### ៣.៣.៣ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៧

អត្រាអតិផរណានៅក្នុងត្រីមាសទី១ ឆ្នាំ២០១៧ បន្តកើនឡើងពីឆ្នាំ២០១៦ ដែលកើនទៅដល់ ១.៣%។ ប៉ុន្តែនៅត្រីមាសទី២ គេសង្កេតឃើញថា អត្រាអតិផរណាមានការធ្លាក់ចុះយ៉ាងកំហុកដោយនៅសល់ត្រឹមតែ 0.១% ប៉ុណ្ណោះ។ ប៉ុន្តែនៅត្រីមាសបន្ទាប់ ដែលជាត្រីមាសទី៣ អត្រាអតិផរណាមានការកើនឡើងវិញបន្តិចដោយកើនមកត្រឹម 0.៤% ហើយបន្តកើននៅត្រីមាសទី៤ ដែលមានអត្រាអតិផរណា 0.៩% ផងដែរ ។

**ក្រាហ្វិក ៣.៤ : អតិផរណា**




ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ ២០១៧ (ធនាគារកណ្តាលនៃថៃ)

យ៉ាងណាមិញ អត្រាអតិផរណាប្រចាំឆ្នាំ២០១៧ ជាមធ្យមស្ថិតក្នុងកម្រិត 0.៦៧% និងអត្រាអតិផរណាស្នូលប្រចាំឆ្នាំ ២០១៧ ជាមធ្យមស្ថិតនៅ 0.៥៦%។អតិផរណាបានកើនឡើងពីកាលពីឆ្នាំមុន ដោយសារតែតម្លៃប្រេងលក់រាយក្នុងស្រុកឡើងថ្លៃ ខណៈតម្លៃអាហារស្រស់បានធ្លាក់ចុះបន្តិចដោយសារទិន្នផលកសិកម្មលើសពីលក្ខខណ្ឌអាកាសធាតុអំណោយផល បើធៀបនឹងឆ្នាំមុន។ អតិផរណាស្នូល នៅតែមានកម្រិតទាប ដោយសារការអភិវឌ្ឍន៍តម្រូវការក្នុងស្រុក មិនមានភាពរឹងមាំគ្រប់គ្រាន់នៅឡើយ។

### ៣.៣.៤ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៨

អត្រាអតិផរណាជាមធ្យម មានអត្រា ១.០៧% ក្នុងឆ្នាំ២០១៨ ដែលជាកម្រិតមួយ ដែលបន្តកើនឡើងពីឆ្នាំ ២០១៧ (០.៦៧%) ប៉ុន្តែអត្រាអតិផរណានៅតែស្ថិតនៅក្នុងកម្រិតទាប មិនទាន់ដល់កម្រិតដែលគេប៉ាន់ស្មាននៅឡើយ។ ទោះបីអត្រាអតិផរណានេះស្ថិតនៅក្នុងកម្រិតទាប ប៉ុន្តែវាបានមានការកើនឡើងដែលបណ្តាលមកពីកំណើនថ្លៃថាមពល ប្រេងឥន្ធនៈ ខណៈដែលអតិផរណាក្រុមទំនិញ អាហារនៅនៅតែធ្លាក់ចុះដោយសារ ការកើនឡើងនូវផលិតផលទំនិញ ទាំងនោះព្រោះតែកត្តាលក្ខខណ្ឌអាកាសធាតុអំណោយផល។ ហើយអតិផរណាស្នូលបានកើនឡើងបន្តិចបណ្តាលមកពីឥទ្ធិពលនៃការដំឡើងពន្ធលើថ្នាំជក់ និងភេសជ្ជៈមានជាតិអាល់កុលដែលត្រូវបានអនុវត្តចាប់តាំងពីចុងឆ្នាំ២០១៧។ តម្លៃនៃទំនិញផ្សេងទៀតមាននិន្នាការស្របតាមការបន្តពង្រីកសេដ្ឋកិច្ច។ យ៉ាងណាក៏ដោយ តម្លៃបានកើនឡើងជាលំដាប់ដោយសារកត្តារចនាសម្ព័ន្ធ ដូចជាមានការប្រកួតប្រជែងនូវអាជីវកម្មខ្ពស់ជាងដែលនាំឱ្យមានការលំបាកក្នុងការឡើងថ្លៃ។

**ក្រាហ្វិក ៣.៥ : អតិផរណា**




ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ ២០១៨ (ធនាគារកណ្តាលនៃថៃ)

### ៣.៣.៥ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០១៩

អតិផរណាមានកម្រិតត្រឹម ០.៧១% ទាបជាងឆ្នាំមុន (១.០៧%)។ ការថយចុះនេះ គឺដោយសារតម្លៃថាមពលមានការធ្លាក់ចុះជាលទ្ធផលនៃការធ្លាក់ចុះតម្លៃប្រេងឆៅពិភពលោក និងប្រាក់បាតថៃឡើងថ្លៃដែលជួយកាត់បន្ថយថ្លៃដើមការនាំចូលថាមពល។ ម្យ៉ាងវិញទៀតតម្លៃអាហារស្រស់មានកំណើននៃថ្លៃ ជាពិសេសពីបន្លែផ្លែឈើនិងតម្លៃស្រូវមួយផ្នែកដោយសារគ្រោះរាំងស្ងួត។ ចំណែកឯអតិផរណាស្នូលមានការថយចុះដោយសារតម្លៃផលិតកម្មទាប និងការកាត់បន្ថយតម្រូវការក្នុងស្រុកដែលបណ្តាលមកពីការលំបាកក្នុងការឡើងថ្លៃទំនិញ និងសេវាកម្មទាំងនោះ។

**ក្រាហ្វិក ៣.៦: អតិផរណា**




ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ ២០១៩ (ធនាគារកណ្ដាលនៃថៃ)

### ៣.៣.៦ ស្ថានភាពអតិផរណាប្រចាំឆ្នាំ២០២០

ស្ថិរភាពសេដ្ឋកិច្ចនៅក្នុងប្រទេសថៃក្នុងឆ្នាំ២០២០ នេះទទួលការរងគ្រោះខ្លាំងមែនទែន ដោយសារការរីករាលដាលនៃជម្ងឺកូវីត ១៩ ។ អត្រាអតិផរណានៅក្នុងឆ្នាំនេះ គឺស្ថិតនៅកម្រិត -0.៨៥% គឺមានការថយចុះយ៉ាងខ្លាំង បើប្រៀបធៀបទៅនឹងឆ្នាំ២០១៩ (0.៧១%)។ អត្រាអតិផរណាធ្លាក់ដល់កម្រិតអវិជ្ជមាននេះ ដោយសារតម្លៃប្រេងលក់រាយក្នុងស្រុកបានធ្លាក់ចុះស្របនឹងតម្លៃប្រេងពិភពលោក។ ការឧបត្ថម្ភធនពីរដ្ឋាភិបាលបានកាត់បន្ថយការចំណាយ លើការរស់នៅ ព្រោះមានការឧបត្ថម្ភធនលើវិក្កយបត្រទឹកនិងអគ្គិសនី។

ជារួម អត្រាអតិផរណានៅឆ្នាំនេះ គឺមានការថយចុះយ៉ាងខ្លាំង និងព្រមទាំងធ្វើឲ្យមានបញ្ហាជាច្រើននៅក្នុងសង្គមដែលបានបង្កជាផលប៉ះពាល់ទៅដល់សេដ្ឋកិច្ចរបស់ប្រទេសថៃ ព្រោះថាវាបានបង្កឲ្យមានហានិភ័យនៃជម្ងឺកូវីត ១៩ នោះ។

**ក្រាហ្វិក ៣.៧ : អតិផរណា**




ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ ២០២០ (ធនាគារកណ្តាលនៃថៃ)

### ៣.៣.៧ ស្ថានភាពអតិផរណាប្រចាំឆ្នាំ ២០២១

អត្រាអតិផរណានៅក្នុងត្រីមាសទី៤ ឆ្នាំ២០២១ មានការកើនឡើង បើធៀបនឹងត្រីមាសមុននៅក្នុងឆ្នាំដដែលដោយសារតម្លៃថាមពល។ អតិផរណាក្នុងរយៈពេលពីរខែដំបូងនៃត្រីមាសទី៤ ឆ្នាំ២០២១ ជាមធ្យម ២.៥៥% កើនឡើងពី ០.៧០% ក្នុងត្រីមាសមុន។ការកើនឡើងភាគច្រើន គឺទាក់ទងទៅនឹង តម្លៃថាមពលដោយសារតែ រដ្ឋាភិបាលមានវិធានការឧបត្ថម្ភ ជួយសម្រួលវិក្កយបត្រអគ្គិសនីដែលបានជួយកាត់បន្ថយការចំណាយលើការរស់នៅត្រូវបានរំសាយបាត់ក៏ដូចជា តម្លៃប្រេងលក់រាយខ្ពស់ជាង មុនស្របគ្នាជាមួយនឹង តម្លៃប្រេងឆៅពិភពលោក។ ទន្ទឹមនឹងនេះ តម្លៃម្ហូបអាហារស្រស់បានបង្ហាញថាមានតម្លៃទាបជាងការធ្លាក់ចុះ ដោយសារទឹកជំនន់បានធ្វើឱ្យតម្លៃបន្លែឡើងថ្លៃ។

អតិផរណាស្នូលក្នុងរយៈពេលពីរខែដំបូងនៃត្រីមាសទី៤ ឆ្នាំ២០២១ ជាមធ្យម ០.២៥% កើនឡើងពី ០.១៤% ក្នុងត្រីមាសមុន។ ការកើនឡើងនេះ ក៏ដោយសារតែតម្លៃផ្ទះ និងគ្រឿងសង្ហារិមមានកំណើនបន្ទាប់ពីការឧបត្ថម្ភធនវិក្កយបត្រទឹករបស់រដ្ឋាភិបាលក្នុងត្រីមាសមុនបានរលាយបាត់ មិនត្រឹមតែប៉ុណ្ណោះ តម្លៃគ្រឿងក្រអូប និងគ្រឿងផ្សំដែលមានតម្លៃខ្ពស់ក៏បានកើនឡើងស្របជាមួយនឹងតម្លៃប្រេងបន្លែ។

**ក្រាហ្វិក ៣.៨ : អតិផរណា**




ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ ២០២១ (ធនាគារកណ្តាលនៃថៃ)

## ៣.៤ មូលហេតុដែលនាំឲ្យមានអតិផរណាកើតមានឡើង

តាមរយៈការសិក្សាទៅលើអតិផរណារបស់ប្រទេសថៃចាប់តាំងពីឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០២១ យើងសង្កេតឃើញថា អត្រាអតិផរណាប្រទេសថៃ គឺមានការប្រែប្រួលជាខ្លាំងចាប់តាំងពីឆ្នាំ២០១៥ មក ដោយអត្រាអតិផរណាប្រចាំឆ្នាំមានការកើនឡើងបន្តបន្ទាប់រហូតដល់ឆ្នាំ២០១៩ ទើបមានការធ្លាក់ចុះ ហើយបានបន្តថយចុះនៅឆ្នាំ២០២០ ផងដែរ។ ក្នុងនោះមានកត្តាជាច្រើនដែលបង្កជាសម្ពាធក្នុងការជម្រុញឲ្យអត្រាអតិផរណានៅក្នុងប្រទេសថៃមាននិន្នាការកើនឡើង និងថយចុះខ្លាំង ដោយស្ថិតនៅចន្លោះឆ្នាំ២០១៥ ដល់ឆ្នាំ២០២១។ តាមរយៈការសិក្សាស្រាវជ្រាវ អត្រាអតិផរណានៅក្នុងប្រទេសថៃចាប់ផ្តើមកើនឡើងចំពេលដែលសេដ្ឋកិច្ចកំពុងតែចាប់ផ្តើមរីកលូតលាស់យ៉ាងខ្លាំង ជាហេតុបង្កឲ្យមានតម្រូវការកើនឡើងច្រើនស្របទៅតាមការរីកលូតលាស់ក្នុងវិស័យផ្សេងៗទៀតផងដែរ។ អត្រាអតិផរណាគិតចាប់តាំងពីឆ្នាំ២០១៥ មកមានការរីកចម្រើនបន្តិចៗ ប៉ុន្តែស្ថិតនៅកម្រិតអត្រាអវិជ្ជមាន នៅឡើយ និងដូចគ្នា នៅក្នុងឆ្នាំ២០២០ ដែលអត្រាអតិផរណាមានការធ្លាក់ចុះយ៉ាងកំហុក។ ការធ្លាក់ចុះកម្រិតអត្រាអតិផរណានេះ បានបង្កទៅជាក្តីព្រួយបារម្ភយ៉ាងខ្លាំងដល់សេដ្ឋកិច្ចប្រទេសថៃ និងតម្រូវឲ្យរាជរដ្ឋាភិបាលថៃគិតគូរស្វែងរកដំណោះស្រាយដើម្បីធ្វើឲ្យសេដ្ឋកិច្ចបានប្រសើរឡើងវិញ។ ដើម្បីឈានទៅដល់ការដោះស្រាយលើបញ្ហាអតិផរណា គឺត្រូវកំណត់ឲ្យច្បាស់លាស់ពីឫសគល់នៃប្រភពបញ្ហារបស់វាសិន។ ដូច្នេះហើយ សូមលើកយកនូវប្រភពបញ្ហាដែលកើតមានឡើងនៅចន្លោះឆ្នាំ២០១៥-២០២១។

### ៣.៤.១ កត្តាតម្លៃថាមពល

កត្តាដែលជួយឲ្យសេដ្ឋកិច្ចនៃប្រទេសថៃមានការរីកចម្រើនយ៉ាងឆាប់រហ័ស មួយផ្នែកត្រូវបានពឹងផ្អែកលើការវិនិយោគក្នុងវិស័យឧស្សាហកម្មជាសំខាន់ ដោយក្នុងនោះ ថៃផលិតប្រេងបាន ៥៣១ ៣២៨.៥៩ បារ៉ែលក្នុងមួយថ្ងៃ (គិតត្រឹមឆ្នាំ២០១៦) ដែលបានជាប់ចំណាត់ថ្នាក់ទី ២៩ នៅលើពិភពលោក ដោយក្នុងនោះ ថៃក៏បាននាំចូលប្រេងឆៅពីបរទេសផងដែរ។ ថ្វីត្បិតតែវាបានរួមចំណែកយ៉ាងសំខាន់ដល់សេដ្ឋកិច្ចរបស់ប្រទេស ប៉ុន្តែកត្តាប្រែប្រួលថ្លៃប្រេងឆៅ និងថ្លៃប្រេងសាំងនៅលើទីផ្សារអន្តរជាតិ បានបង្កជាផលប៉ះពាល់យ៉ាងអាក្រក់ដល់ប្រទេសថៃដូចគ្នា។ ព្រោះថាកម្រិតប្រែប្រួលនៃថ្លៃប្រេងឆៅ និងប្រេងសាំងនៅលើទីផ្សារពិភពលោក បានដាក់សម្ពាធដល់ការចរាចរប្រេងក្នុងប្រទេសថៃ ដែលវាបានដាក់សម្ពាធដល់អតិផរណាក្នុងប្រទេសដូចគ្នា។ នៅពេលដែលមានការឡើងថ្លៃប្រេងនៅលើទីផ្សារអន្តរជាតិ នាំឲ្យអត្រាអតិផរណាប្រទេសថៃមានការកើនឡើងទន្ទឹមនឹងការធ្លាក់ចុះនៃតម្លៃប្រាក់បាត។

ជាក់ស្តែងនៅឆ្នាំ២០១៨ យើងសង្កេតឃើញថា អតិផរណាប្រទេសថៃបានកើនឡើងសមស្របតាមតម្លៃប្រេងឥន្ធនៈក្នុងស្រុកមានការកើនឡើង និងស្ថេរភាពស្របតាមការកើនឡើងនៃតម្លៃប្រេងឆៅពិភពលោក។ នៅក្នុងត្រីមាសទី៣ ឆ្នាំ២០១៨ តម្លៃប្រេងឆៅ Dubai (Dubai crude oil) បានបន្តកើនឡើងជាខ្លាំង បើធៀបទៅនឹងឆ្នាំមុន។ ការកើនឡើងនៃតម្លៃប្រេងឆៅនេះ គឺដោយសារតែកត្តាកំណើនតម្រូវការប្រេងលើពិភពលោក ស្របទៅតាមការរីកចម្រើននៃសេដ្ឋកិច្ច។ រីឯនៅក្នុងត្រីមាសទី៤ យើងសង្កេតឃើញថា ទាំងតម្លៃថាមពល ដូចជាប្រេងឆៅ ប្រេងឥន្ធនៈ និងកម្រិតអត្រាអតិផរណាមានការធ្លាក់ចុះ នៅពេលតម្រូវការប្រេងឆៅត្រូវបានដោះស្រាយ ដោយសហរដ្ឋអាមេរិកបានដោះទណ្ឌកម្មសេដ្ឋកិច្ចពីអ៊ីរ៉ង់ ដែលជាប្រទេសផ្គត់ផ្គង់ប្រេងឆៅដ៏សំខាន់មួយនៅលើទីផ្សារប្រេងលើពិភពលោក ។

### ៣.៤.២ កត្តារូបិយវត្ថុ

នៅចុងឆ្នាំ២០១៨-២០១៩ មានការកើនឡើងនៃតម្លៃប្រាក់បាត ដែលរួមចំណែកធ្វើឲ្យអត្រាអតិផរណានៅក្នុងប្រទេសមានការថយចុះ ព្រោះថាថ្លៃនៃការនាំចូលមានការថយចុះ។ ដោយសារអត្រាអតិផរណាស្ថិតក្នុងកម្រិតទាប ធនាគារកណ្តាលនៃប្រទេសថៃបានបន្តគោលនយោបាយរបស់ខ្លួន (accommodative policy) នៅដដែល ដែលគាំទ្រដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសខ្លួន។ អត្រាគោលនយោបាយរបស់ប្រទេសថៃ ស្ថិតនៅក្រោម ២% ចាប់តាំងពីខែមីនា ឆ្នាំ២០១៥ និងបានកាត់បន្ថយពីរដងក្នុងឆ្នាំ២០១៩ មកត្រឹម ១.២៥%។

យើងបានសង្កេតឃើញថា លុយបាតនៅឆ្នាំ២០១៨ ស្ថិតនៅក្នុងស្ថានភាពរឹងមាំ ដែលស្ថិតក្នុងអត្រា ១ ដុល្លារអាមេរិក ស្មើនឹង ៣២.៥៦ ថៃបាត។ ហើយនៅឆ្នាំ២០១៩ ក្នុង ១ ដុល្លារអាមេរិក ស្មើនឹង ៣១.០៤។ ទោះបីជាលុយថៃបាតមានការធ្លាក់ចុះថ្លៃបន្តិចបន្តួចក្តី ប៉ុន្តែលុយបាតនៅតែជារូបិយវត្ថុមួយ ដែលមានភាពរឹងមាំ

ហើយការបន្តស្ថិតក្នុងស្ថានភាពរឹងមាំនៃលុយបាតនេះ បានរួមជាចំណែកក្នុងការធ្វើឲ្យសេដ្ឋកិច្ចប្រទេសថៃមានភាពស្ថេរភាពល្អប្រសើរឡើងវិញយ៉ាងឆាប់រហ័ស។

## ៣.៥ ផលប៉ះពាល់

នៅពេលដែលអតិផរណាមានការកើនឡើង ឬថយចុះខ្លាំង វាតែងតែមានផលប៉ះពាល់ដល់ប្រជាជនដែលរស់នៅក្នុងប្រទេសនោះ។ ដូចនេះ នៅយើងនឹងលើកយកផលប៉ះពាល់មួយចំនួនមកបកស្រាយ។

ដូចនៅឆ្នាំ២០១៨ វាមានផលប៉ះពាល់ដល់អ្នកប្រកបរបរកសិកម្ម នឹងអ្នកដែលមានចំណូលទាប។ នៅពេលដែលអតិផរណាមានការកើនឡើងវាអាចនឹងជំរុញឲ្យតម្លៃអាហារក្នុងស្រុកក៏មានការកើនឡើង។ សម្រាប់ប្រជាជនដែលមានចំណូលទាប អាហារ គឺជាផ្នែកមួយដែលគេចំណាយច្រើនជាងគេ ប៉ុន្តែនៅពេលដែលតម្លៃអាហារមានការកើនឡើង ពួកគេនឹងជួបវិបត្តិដោយសារពួកគេមិនអាចទិញនូវប្រមាណអាហារក្នុងទំហំទឹកប្រាក់ដដែលបាននោះទេ។ ទាំងនេះហើយ បានធ្វើឲ្យមានផលប៉ះពាល់ដល់ស្ថានភាព និងជីវភាពរស់នៅរបស់គេ។ មិនតែប៉ុណ្ណោះ កសិករក៏ជួបនូវបញ្ហាផងដែរ គឺដោយសារតែមានការឡើងថ្លៃនៃវត្ថុធាតុដើមដែលគេនាំចូល និងការឡើងថ្លៃនៃថ្លៃដើមផលិតកម្ម។

ផលប៉ះពាល់មួយទៀត គឺទៅលើវិស័យឧស្សាហកម្ម។ ដូចនៅឆ្នាំ២០២០ ដែលជាឆ្នាំដែលមានអត្រាអតិផរណា អវិជ្ជមាន គឺមានការប៉ះពាល់ជាខ្លាំងទៅលើវិស័យឧស្សាហកម្ម។ ការនាំចេញជាច្រើនត្រូវបានផ្អែកដោយសារតែរឹងបន្តឹងការធ្វើដំណើរអន្តរជាតិ ព្រោះមានការលេចឡើងនូវជម្ងឺកូវីត ១៩ ។

## ៣.៦ យុទ្ធសាស្ត្រ និងដោះស្រាយរបស់រដ្ឋាភិបាលថៃលើបញ្ហាអតិផរណា

បញ្ហាសេដ្ឋកិច្ចតែងតែកើតមានឡើងនៅក្នុងប្រទេសនីមួយៗ ហើយវាទាមទារឲរដ្ឋាភិបាល ចូលរួមរិះរកដំណោះស្រាយក្នុងការធ្វើឲសេដ្ឋកិច្ចរបស់ខ្លួនមាន បានបន្តដំណើរឆ្ពោះទៅមុខឲមានភាពប្រសើរជាងមុន។ ដូច្នេះ ហើយរដ្ឋាភិបាលថៃបានប្រើប្រាស់នូវគោលនយោបាយចំនួនពីរ នៅពេលដែលប្រទេសរបស់ជួបនូវបញ្ហាអតិផរណា ដូចជាពេលអតិផរណាធ្លាក់ចុះរហូតដល់ចំណុចអវិជ្ជមានជាដើម។

គោលនយោបាយពីរសំខាន់ដែលបានពាក់ព័ន្ធនឹងសេដ្ឋកិច្ច គឺគោលនយោបាយសារពើពន្ធ (Fiscal Policy) និង គោលនយោបាយរូបិយវត្ថុ (Monetary Policy) ។ គោលនយោបាយសារពើពន្ធត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាល ហើយគោលនយោបាយរូបិយវត្ថុត្រូវបានប្រើប្រាស់ដោយធនាគារកណ្តាល។ វិធីសាស្ត្រនីមួយៗត្រូវបានប្រើប្រាស់នឹងមានឥទ្ធិពលខុសៗគ្នាទៅលើសេដ្ឋកិច្ច។

គោលនយោបាយសារពើពន្ធ បានដើរតួយ៉ាងសំខាន់ក្នុងការគាំទ្រលំហូរនៃប្រាក់ចំណូល នៅក្នុងឆ្នាំ២០២០ ដែលមានជម្ងឺកូវីត ១៩ យ៉ាងខ្លាំងនៅក្នុងប្រទេស។ នៅក្នុងកំឡុងពេលជម្ងឺរាតត្បាតនេះ វិធានការជំនួយផ្សេងៗ (incentive measures) ជួយទ្រទ្រង់ការងារ។ រដ្ឋាភិបាលថៃបានដាក់ចេញនូវកញ្ចប់ជំរុញសេដ្ឋកិច្ចជា

បន្តបន្ទាប់ដែលមានតម្លៃប្រមាណជា ២.៦ ពាន់ពាន់លានបាត (2.6 trillion THB) ឬ ១៥% នៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេស។ ដោយកញ្ចប់មួយក្នុងចំណោមកញ្ចប់ទាំងនេះមានប្រាក់ ១ ពាន់ពាន់លានបាត ដែលជាឥណទានក្រិត្យគ្រាអាសន្នសម្រាប់ ផែនការសុខភាពសាធារណៈផែនការជំនួយហិរញ្ញវត្ថុ និងផែនការរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ច ដែលនឹងត្រូវបាន ពន្លឿនតាមការចាំបាច់ក្នុងរយៈពេល ២០២០-២០២១។ ហើយក៏មានវិធានការផ្តល់ជំនួយហិរញ្ញវត្ថុប្រមាណ ៤០០ ពាន់លានបាត តាមរយៈការបន្ធូរបន្ថយពន្ធ និង ជំនួយហិរញ្ញវត្ថុពីមូលនិធិសន្តិសុខសង្គម។

គោលនយោបាយមួយទៀត គឺគោលនយោបាយរូបិយវត្ថុ។ គោលនយោបាយរូបិយវត្ថុបានផ្តល់ការគាំទ្រភ្លាមៗដល់វិស័យឯកជន តាមរយៈការបន្ថយការប្រាក់ឲ្យនៅទាប។ ប្រទេសថៃស្ថិតក្នុងចំណោមប្រទេសដែលមានធនាគារកណ្តាលដំបូងគេ ដើម្បីកាត់បន្ថយអត្រាគោលនយោបាយ ដើម្បីឆ្លើយតបទៅនឹងជំងឺរាតត្បាតកូវីត ១៩។ គោលការណ៍នេះត្រូវបានរចនាឡើងដើម្បីធានានូវទិន្នផលតម្លៃ និងគោលដៅស្ថិរភាពហិរញ្ញវត្ថុ។ ទន្ទឹមនឹងនេះ ដើម្បីធានាបាននូវការចែកចាយសាច់ប្រាក់ (liquidity distribution) ងាយស្រួលគ្រប់គ្រាន់ដល់ក្រុមហ៊ុន និងគ្រួសារដែលត្រូវការជំនួយ ធនាគារកណ្តាលបានសម្របសម្រួលយ៉ាងជិតស្និទ្ធ ជាមួយភ្នាក់ងាររដ្ឋាភិបាល ដើម្បីធានាបាននូវករណីឥណទានរបស់ពួកគេ ដំណើរការបានល្អ។ ហើយក៏មានគោលនយោបាយចម្រុះនៃកម្មវិធីកម្ចីទន់របស់ធនាគារកណ្តាលនៃប្រទេសថៃ ជាមួយនឹងគម្រោងការរបស់រដ្ឋាភិបាលថៃ ដែលបានធានានូវឥណទាន បានជួយធានាថាសាច់ប្រាក់ក្នុងប្រព័ន្ធហិរញ្ញវត្ថុ ត្រូវបានចែកចាយដល់អ្នកដែលត្រូវការយ៉ាងងាយស្រួល និងជាពិសេសដល់សហគ្រាសធុនតូច និងមធ្យមដែលមានទំនោរប្រឈមមុខនឹងហានិភ័យឥណទានខ្ពស់ជាងសាជីវកម្មធំៗ។

# ជំពូកទី ៤
# ការពិភាក្សា វិភាគ ប្រៀបធៀបទៅលើការវិវត្តនៃអត្រាអតិផរណារបស់ប្រទេសកម្ពុជា និងថៃ

# ជំពូកទី ៤

# ការពិភាក្សា វិភាគ ប្រៀបធៀបទៅលើការវិវត្តនៃ អត្រាអតិផរណារបស់ប្រទេសកម្ពុជា និងថៃ

បន្ទាប់ពីយើងធ្វើការសិក្សាយ៉ាងស៊ីជម្រៅអំពីស្ថានភាពអតិផរណារបស់ប្រទេសកម្ពុជា និងថៃ រួចនៅក្នុងជំពូកទី ២ និងទី ៣, នៅក្នុងជំពូកទី ៤ នេះ គឺយើងនឹងធ្វើការពិភាក្សា វិភាគ និងប្រៀបធៀបលើការវិវត្តនៃអត្រាអតិផរណារបស់ប្រទេសទាំងពីរ, ប្រៀបធៀបអំពីមូលហេតុ និងបញ្ហាប្រឈម រួមទាំងយុទ្ធសាស្ត្រក្នុងការដោះស្រាយបញ្ហាអតិផរណាផងដែរ។

## ៤.១ ការប្រៀបធៀបអត្រាអតិផរណារវាងប្រទេសកម្ពុជា និងថៃ

ដោយយោងទៅតាម តារាងអតិផរណាប្រចាំឆ្នាំរបស់ប្រទេសកម្ពុជា និងប្រទេសថៃ (តារាង ២.១ និង តារាង ៣.១) ក្នុងជំពូកទី ២ និងទី៣ យើងអាចបង្ហាញនូវការវិវត្តនៃអត្រាអតិផរណារបស់ប្រទេសទាំងពីរបានដូចក្រាហ្វិកដូចខាងក្រោម៖

ក្រាហ្វិក ៤.១ ការវិវត្តនៃអត្រាអតិផរណាប្រចាំឆ្នាំ




តាមរយៈក្រាហ្វិក ៤.១ នេះ បានបង្ហាញថា អត្រាអតិផរណារបស់ប្រទេសកម្ពុជា មានការប្រែប្រួលជារៀងរាល់ឆ្នាំ ដោយឆ្នាំ២០១៥ ជាឆ្នាំដែលមានកម្រិតអត្រាអតិផរណាទាបបំផុត គឺស្ថិតក្នុងកម្រិតអត្រា ១.២%។ រីឯឆ្នាំដែលមានអត្រាអតិផរណាខ្ពស់ គឺឆ្នាំ២០១៦ មានអត្រាអតិផរណា ៣.០% និងឆ្នាំ ២០១៧, ឆ្នាំ ២០២០, និងឆ្នាំ២០២១ ដែលមានប្រហាក់ប្រហែលគ្នា ២.៩%។ អត្រាអតិផរណានៅប្រទេសកម្ពុជា មានការកើនឡើងដោយសារតែវិស័យទេសចរណ៍ និងការនាំចេញសម្លៀកបំពាក់នៅឆ្នាំ២០១៦ និងមានការធ្លាក់ចុះតែបន្តិចបន្តួចនៅឆ្នាំបន្ទាប់ នៅពេលដែលថ្លៃប្រេងឆៅមានការកើនឡើង ទាំងក្នុងស្រុក និងទូទាំងពិភពលោក ដែលជាហេតុធ្វើឲ្យអតិផរណានៅប្រទេសកម្ពុជា នៅតែស្ថិតនៅចំណុចសឹងតែដដែល និងការឡើងថ្លៃម្ហូបអាហារផងដែរ។ មិនតែ

ប៉ុណ្ណោះ នៅឆ្នាំ២០១៩ យើងសង្កេតឃើញថា កម្រិតអតិផរណាមានការធ្លាក់ចុះយ៉ាងខ្លាំង ដែលស្ថិតក្នុងអត្រា ១.៩% ដោយសារតែនៅមានការបន្តថមថយនៃកំណើនថ្លៃក្រុមម្ហូបអាហារ ការធ្លាក់ថ្លៃនៃក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ។

ចំណែកប្រទេសថៃវិញ តាមក្រាហ្វិក ៤.១ បានបង្ហាញឲ្យឃើញថា អត្រាអតិផរណាប្រទេសថៃ មានការកើនឡើងចាប់តាំងពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ដែលបានកើនឡើងពី -0.៩% នៅឆ្នាំ២០១៥ ដល់ ១.០៧% នៅឆ្នាំ២០១៨។ បន្ទាប់ពីឆ្នាំ២០១៨ យើងបន្តសង្កេតឃើញថា មានការធ្លាក់ចុះបន្តិចវិញ ដោយនៅស្ថិតត្រឹមកម្រិត 0.៧១% និងធ្លាក់ចុះយ៉ាងខ្លាំង នៅឆ្នាំ២០២០ រហូតដល់ចំណុចអវិជ្ជមាន ក្នុងកម្រិតអត្រា -0.៨៥% ហើយក៏មានការកើនឡើងវិញ នៅឆ្នាំ២០២១ ដែលកើនឡើងដល់ ១.២៣%។ អត្រាអតិផរណាក្នុងប្រទេសថៃភាគច្រើនប្រែប្រួលដោយសារតែថ្លៃប្រេងឆៅ ដែលនៅពេលថ្លៃប្រេងឆៅឡើងថ្លៃ ធ្វើឲ្យអត្រាអតិផរណាក្នុងប្រទេសថៃក៏មានកំណើនប្រែប្រួលផងដែរ ។

នៅពេលដែលយើងពិនិត្យទៅលើក្រាហ្វិក ៤.១ នេះ ទាំងប្រទេសកម្ពុជា និងប្រទេសថៃ នៅឆ្នាំ២០១៦ គឺមានអត្រាអតិផរណាកើនឡើងដូចគ្នា ដោយមូលហេតុចម្បងគឺ បណ្តាលមកពីការកើនឡើងនៃថ្លៃប្រេងឆៅនៅលើទីផ្សារពិភពលោក ក្នុងនោះ រួមទាំងកត្តាម្ហូបអាហារផងដែរ។ ហើយនៅឆ្នាំ២០១៩ ប្រទេសទាំងពីរជួបនឹងការថយចុះនៃអត្រាអតិផរណា ដោយសារតែថ្លៃម្ហូបអាហារមានការថយចុះ និងការធ្លាក់ថ្លៃនៃក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈដូចគ្នាដែរ ។

ក្នុងតារាង (៤.១) ខាងក្រោមនេះ ជាការគណនារកអត្រាអតិផរណាមធ្យមរវាងប្រទេសកម្ពុជា និងថៃ៖

| **ឆ្នាំ** | CPI **របស់ប្រទេសកម្ពុជា** | CPI **របស់ប្រទេសថៃ** |
|---|---|---|
| ២០១៥ | ១១៧.៥ | ១១០.៣ |
| ២០១៦ | ១២១ | ១១០.៦ |
| ២០១៧ | ១២៤.៦ | ១១១.៣ |
| ២០១៨ | ១២៧.៦ | ១១២.៥ |
| ២០១៩ | ១៣០.១ | ១១៣.៣ |
| ២០២០ | ១៣៣.៩ | ១១២.៣ |
| ២០២១ | ១៣៧.៩ | ១១៣.៧ |

ប្រភព៖ https://data.worldbank.org/indicator/FP.CPI.TOTL?locations=KH
https://data.worldbank.org/indicator/FP.CPI.TOTL?locations=TH

យើងនឹងធ្វើការគណនារកអត្រាអតិផរណាមធ្យមតាមរូបមន្តដូចខាងក្រោម៖

$$\text{Future Value} = \text{Present Value}\ (1+r)^t$$

យើងតាង Future Value = Ending Value

Present Value = Beginning Value

- ក្នុងករណីអត្រាអតិផរណាមធ្យមនៅកម្ពុជាចន្លោះឆ្នាំ២០១៥ ដល់ឆ្នាំ២០២១

$$\text{Future Value} = \text{Present Value}\ (1+r)^t$$
$$137.9 = 117.5\ (1+r)^6$$
$$\frac{137.9}{117.5} = (1+r)^6$$
$$(\frac{137.9}{117.5})^{\frac{1}{6}} = 1+r$$
$$r = (\frac{137.9}{117.5})^{\frac{1}{6}} - 1$$

នាំឲ្យ $r = 0.0270 = 2.7\%$

ដូចនេះ អត្រាអតិផរណាមធ្យមនៅកម្ពុជាចន្លោះឆ្នាំ២០១៥ ដល់ឆ្នាំ២០២១ ស្មើ ២.៧%

- ក្នុងករណីអត្រាអតិផរណាមធ្យមនៅថៃ

$$\text{Future Value} = \text{Present Value}\ (1+r)^t$$
$$113.7 = 110.3\ (1+r)^6$$
$$\frac{113.7}{110.3} = (1+r)^6$$
$$(\frac{113.7}{110.3})^{\frac{1}{6}} = 1+r$$
$$r = (\frac{113.7}{110.3})^{\frac{1}{6}} - 1$$

នាំឲ្យ $r = 0.0051 = 0.51\%$

ដូចនេះ អត្រាអតិផរណាមធ្យមនៅថៃចន្លោះឆ្នាំ២០១៥ ដល់ឆ្នាំ២០២១ ស្មើ 0.៥១%

ជាសរុបមក យើងសង្កេតឃើញថា អត្រាអតិផរណាជាមធ្យមនៅកម្ពុជា និងថៃ ចន្លោះឆ្នាំ២០១៥ ដល់ឆ្នាំ២០២១ គឺមានភាពខុសគ្នាគួរឲ្យកត់សម្គាល់ ដែលក្នុងនោះយើងឃើញថា អត្រាអតិផរណាមធ្យមនៅកម្ពុជាស្ថិតក្នុងកម្រិត ២.៦៥% និងអត្រាអតិផរណាមធ្យមនៅថៃ ស្ថិតក្នុងកម្រិត 0.៤៩% ដែលកម្ពុជាមានស្ថិតនូវក្នុងអត្រាដែលខ្ពស់ជាងប្រទេសថៃ។ គួរកត់សម្គាល់ផងដែរថា ប្រទេសទាំងពីរមានអត្រាអតិផរណាមធ្យមក្នុងកម្រិតទាបអាចគ្រប់គ្រងបាន។

## ៤.២ ប្រៀបធៀបមូលហេតុដែលនាំឲ្យមានអតិផរណារវាងប្រទេសកម្ពុជា និងប្រទេសថៃ

- **ប្រទេសកម្ពុជា៖** ប្រទេសកម្ពុជា មានការឡើងចុះនៃកម្រិតអត្រាអតិផរណាជារៀងរាល់ឆ្នាំ ដែលក្នុងនោះយើងសង្កេតឃើញថា ក្នុងឆ្នាំ២០១៨ ការកើនឡើងនៃតម្លៃប្រេងឆៅនៅលើទីផ្សារពិភពលោក

បានជះឥទ្ធិពលដល់ទីផ្សារប្រេងនៅកម្ពុជា ដោយសារតែប្រទេសកម្ពុជា ជាប្រទេសនាំចូលប្រេងពីបណ្តាប្រទេសដែលផលិតប្រេង។ មួយវិញទៀត កត្តានាំចូលទំនិញ ឬម្ហូបអាហារជាមូលហេតុដែលធ្វើឲ្យអតិផរណានៅប្រទេសកម្ពុជាមានការប្រែប្រួល ដោយនៅឆ្នាំ២០២០ អត្រាអតិផរណាមានការកើនឡើងបន្តិច ដោយសារថ្លៃម្ហូបអាហារនាំចូលមានកំណើន ដែលបណ្តាលមកពីការរំពឹងទុកថាអតិផរណា នៅក្នុងប្រទេសចម្បងនាំចូលម្ហូបអាហារមកកាន់កម្ពុជាមានការកើនឡើងវិញបន្តិច បូករួមទាំងកំណើនថ្លៃក្រុមទំនិញផងដែរ។ ក្នុងនោះ ប្រទេសចម្បងដែលនាំទំនិញ ឬម្ហូបអាហារចូលមកកាន់ប្រទេសកម្ពុជា រួមមានដូចជា ប្រទេសថៃ និងប្រទេសវៀតណាម។ ដូច្នេះហើយ អតិផរណាក្នុងប្រទេសកម្ពុជា អាស្រ័យទៅលើស្ថានភាពអតិផរណានៃប្រទេសដែលនាំទំនិញចូលមកកាន់ប្រទេសកម្ពុជា។

- **ប្រទេសថៃ៖** ប្រទេសថៃ មានការកើនឡើងនៃអត្រាអតិផរណា នៅពេលដែលមានកំណើនថ្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ ដោយសារតែ ប្រទេសថៃជាប្រទេសពឹងផ្អែកទៅលើវិស័យឧស្សាហកម្មផលិតកម្ម។ ដូចនេះ ការប្រែប្រួលតម្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ បានជះឥទ្ធិពល និងដាក់ជាសម្ពាធដល់អត្រាអតិផរណានៅក្នុងប្រទេសថៃ។

សរុបមក ការកើនឡើងនៃអតិផរណាក្នុងប្រទេសកម្ពុជា និងប្រទេសថៃ គឺបណ្តាលមកពីថ្លៃនៃប្រេងឆៅនៅលើទីផ្សារពិភពលោកមានការកើនឡើង ព្រោះថាប្រទេសទាំងពីរសុទ្ធសឹងតែបានពឹងផ្អែកទៅលើប្រេងឆៅពិភពលោក សម្រាប់យកមកផ្គត់ផ្គង់តម្រូវការប្រើប្រាស់ក្នុងស្រុកទេសន៍ដូចជា ការប្រើប្រាស់ក្នុងវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម វិស័យដឹកជញ្ជូន និងផ្សេងៗទៀត ដើម្បីធ្វើឲ្យមានការអភិវឌ្ឍន៍ក្នុងប្រទេសរៀងៗខ្លួន។ ក្នុងនោះថ្វីត្បិតតែនៅក្នុងប្រទេសកម្ពុជា និងថៃមានការប្រែប្រួលនៃអត្រាអតិផរណាក៏ពិតមែន តែយើងសង្កេតឃើញថាការប្រែប្រួលរបស់វា គឺស្ថិតក្នុងកម្រិតមួយដែលរាជរដ្ឋាភិបាលអាចគ្រប់គ្រងបាន និងពុំទាន់បង្កទៅជាហានិភ័យធ្ងន់ធ្ងរដល់សេដ្ឋកិច្ចឡើយ។ ប៉ុន្តែបើកាលណាកម្រិតនៃអត្រាអតិផរណាប្រែប្រួលចាប់ពី ១០% ឡើងទៅ ពិតណាស់វានឹងបង្កជាហានិភ័យយ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចជាតិ និងមានភាពលំបាកក្នុងការគ្រប់គ្រង ព្រោះថាទំហំនៃការបំផ្លិចបំផ្លាញរបស់វាដល់សេដ្ឋកិច្ច គឺធំធេង និងខ្លាំង ហើយអាចអូសបន្លាយក្នុងរយៈពេលវែង។

## ៤.៣ បញ្ហាប្រឈមនៃការប្រែប្រួលអត្រាអតិផរណានៃប្រទេសកម្ពុជា និងប្រទេសថៃ

បន្ទាប់ពីបានសិក្សាស្រាវជ្រាវពីស្ថានភាពអតិផរណានៃប្រទេសកម្ពុជា និងប្រទេសថៃរួច យើងអាចធ្វើការសង្កេតបានថា កម្ពុជា និងថៃ មានបញ្ហាប្រឈមចម្បងមិនសូវជាខុសគ្នាប៉ុន្មាននោះទេ ដែលបញ្ហាទាំងនោះអាចបង្កជាការប្រែប្រួលអត្រាអតិផរណាក្នុងប្រទេសបាន ហើយបញ្ហាប្រឈមចម្បងទាំងនោះ រួមមាន៖

- **ថ្លៃប្រេងឆៅពិភពលោក៖** យើងសង្កេតឃើញថា ក្នុងឆ្នាំ២០១៨ ការបន្តអនុវត្តកិច្ចព្រមព្រៀងកាត់បន្ថយការផ្គត់ផ្គង់ពីបណ្តាប្រទេសនាំចេញប្រេង (OPEC), និងការដាក់ទណ្ឌកម្មសេដ្ឋកិច្ចពីសហរដ្ឋអាមេរិកមកលើប្រទេសអ៊ីរ៉ង់ ដែលបានបង្កភាពរាំងស្ទះដល់ការនាំចេញប្រេងពីប្រទេសនេះយ៉ាងខ្លាំង។ កត្តាទាំងនេះ បានបង្ហាញយ៉ាងច្បាស់ពីការជះឥទ្ធិពលនៃការប្រែប្រួលតម្លៃប្រេងឆៅនៅលើទីផ្សារពិភពលោកមកកាន់ប្រទេសកម្ពុជា ដែលបង្កជាសម្ពាធដល់អតិផរណារបស់កម្ពុជា។ មិនត្រឹមតែកម្ពុជានោះទេ ដែលទទួលរងឥទ្ធិពលពីការប្រែប្រួលនៃតម្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ ប្រទេសថៃក៏រងឥទ្ធិពលនេះមិនចេញកម្ពុជាប៉ុន្មានដែរ ដោយ ក្នុងឆ្នាំ២០១៨ អតិផរណាប្រទេសថៃបានកើនឡើងសមស្របតាមតម្លៃប្រេងឥន្ធនៈក្នុងស្រុកមានការកើនឡើង និងស្របតាមការកើនឡើងនៃតម្លៃប្រេងឆៅពិភពលោក ដែលនៅក្នុងត្រីមាសទី៣ ឆ្នាំ២០១៨ តម្លៃប្រេងឆៅ Dubai (Dubai crude oil) បានបន្តកើនឡើងជាខ្លាំងដែលបានបង្កជាសម្ពាធដល់កម្រិតអតិផរណាក្នុងប្រទេសថៃ។
- **ថ្លៃម្ហូបអាហារពិភពលោក៖** សម្រាប់ប្រទេសកម្ពុជាជាប្រទេសនាំចូលទំនិញ ម្ហូបអាហារពីក្រៅប្រទេស ពិតណាស់ការកើនឡើងថ្លៃម្ហូបអាហារពិភពលោកនឹងជះឥទ្ធិពលដល់សេដ្ឋកិច្ចប្រទេសទាំងមូល ជាពិសេសនោះ គឺបានដាក់សម្ពាធដល់អត្រាអតិផរណា ជាក់ស្តែងប្រទេសថៃក៏ដូចគ្នាផងដែរ។ ដោយការកើនឡើងនៃថ្លៃម្ហូបអាហារពិភពលោកអាចបណ្តាលមកពីកត្តាបញ្ហាអាកាសធាតុដែលគំរាមកំហែងដល់ការប្រមូលផលទិន្នផលកសិកម្ម កត្តាតម្រូវការកើនឡើងច្រើនជាងមុន កត្តាវត្ថុធាតុដើមក្នុងការផលិតថ្លៃជាងមុនជាដើម។ កត្តាទាំងនេះហើយ ដែលបង្កឲ្យតម្លៃកើនឡើងថ្លៃជាងមុន ជាហេតុបង្កឲ្យមានការប្រែប្រួលអតិផរណា។

## ៤.៤ ដំណោះស្រាយរបស់រាជរដ្ឋាភិបាលនៃប្រទេសទាំងពីរនៅលើអតិផរណា

ប្រទេសនីមួយៗនៅក្នុងពិភពលោកនេះ តែងតែជួបប្រទះនូវបញ្ហាផ្សេងៗគ្នាស្របទៅតាមការអភិវឌ្ឍរបស់ប្រទេស ដូចជា បញ្ហានិកម្មភាព អស្ថេរភាពផ្នែកនយោបាយ ក៏ដូចជាបញ្ហាអតិផរណាផងដែរ។ ហេតុដូច្នេះហើយ ទើបតម្រូវឲ្យរាជរដ្ឋាភិបាលនៃប្រទេសទាំងនោះ មានចំណាត់ការខ្ពស់ ក៏ដូចជាការយកចិត្តទុកដាក់ក្នុងការដោះស្រាយលើវិបត្តិទាំងនោះ ដើម្បីបន្តធានាថាប្រទេសនូវតែមានស្ថិរភាពផ្នែកសេដ្ឋកិច្ច និងអាចបន្តភាពរីកចម្រើន។ យ៉ាងណាមិញ ចំពោះស្ថានភាពអតិផរណានៅប្រទេសកម្ពុជា និងប្រទេសថៃ រាជរដ្ឋាភិបាលនៃប្រទេសទាំងពីរសុទ្ធតែបានយកចិត្តទុកដាក់ខ្ពស់ក្នុងការស្វះស្វែងរកនូវយុទ្ធសាស្ត្រ ឬគោលនយោបាលក្នុងការដោះស្រាយលើបញ្ហាអតិផរណានេះ ដើម្បីធានាថាអត្រារបស់វាឲ្យស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបាន។

- **រាជរដ្ឋាភិបាលកម្ពុជា៖** និយាយពីស្ថានភាពអតិផរណាក្នុងប្រទេសកម្ពុជា ថ្វីត្បិតតែអត្រាអតិផរណាមានការប្រែប្រួលរៀងរាល់ឆ្នាំ ប៉ុន្តែស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបាន នេះក៏ដោយសារតែរាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តន៍គោលនយោបាយរូបិយវត្ថុ ដោយក្នុងនោះរួមមាន៖

- ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់៖ ដើម្បីធានាថាអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក មានស្ថិរភាព ហេតុនេះទើបមិនធ្វើឲ្យអត្រាអតិផរណាប្រែប្រួលខ្លាំង។
- គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ៖ ដើម្បីធានាថាប្រាក់រៀលដែលចរាចរនៅក្នុងទីផ្សារមិនលើសពីតម្រូវរបស់អ្នកប្រើប្រាស់ ហេតុនេះហើយ ទើបមិនធ្វើឲ្យតម្លៃប្រាក់រៀលធ្លាក់ថ្លៃខ្លាំងបើធៀបនឹងរូបិយប័ណ្ណបរទេស។
- ការអនុវត្តគោលនយោបាយដំឡើងប្រាក់បៀវត្ស៖ នៅពេលដែលអតិផរណាកើនឡើង រាល់ថ្លៃទំនិញ សេវាកម្មមានការឡើងថ្លៃជាងមុន ដូចនេះរាជរដ្ឋាភិបាលធ្វើការដំឡើងប្រាក់បៀវត្សដើម្បីធានាថាមន្ត្រីចូលនិវត្តិមិនសូវរងឥទ្ធិពលខ្លាំងពីការកើនឡើងនៃអតិផរណានោះ។

- **រាជរដ្ឋាភិបាលថៃ៖** ថៃបានប្រើប្រាស់គោលនយោបាយពីរនៅពេលដែលប្រទេសខ្លួនធ្លាក់ទាបដល់កម្រិតអវិជ្ជមាននៃអតិផរណា ដោយគោលនយោបាយនោះរួមមាន៖
  - គោលនយោបាយសារពើពន្ធ៖ ជួយជំនួយជាថវិការ ដើម្បីទ្រទ្រង់សេដ្ឋកិច្ចប្រទេសជាតិ ព្រោះវាជាគោលនយោបាយមួយដែលជួយក្នុងលំហូរសាច់ប្រាក់ប្រទេសជាតិ ។
  - គោលនយោបាយរូបិយវត្ថុ៖ បានកាត់បន្ថយអត្រាគោលនយោបាយ ដើម្បីឲ្យងាយស្រួល ក្រុមហ៊ុនមធ្យម និងតូចងាយស្រួលក្នុងការគ្រប់គ្រាន់ក្រុមហ៊ុនរបស់ខមានដំណើរការទៅមុខ និងជួយដល់គ្រួសារដែលត្រូវការជំនួយ ដោយសារមានបំណុល ។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវអំពីប្រធានបទ (ស្ថានភាពនៃអតិផរណានៅប្រទេសកម្ពុជា និងថៃ ពីឆ្នាំ២០១៥ ដល់២០២១) ខាងលើរួចមក យើងអាចធ្វើការសន្និដ្ឋានបានថាស្ថានភាពនៃអតិផរណានៅប្រទេសកម្ពុជា និងថៃ សុទ្ធតែមានការប្រែប្រួលទៅតាមឆ្នាំនីមួយៗដូចគ្នា។ ដោយក្នុងនោះទាំងប្រទេសកម្ពុជា និងប្រទេសថៃ សុទ្ធតែបានជួបប្រទះនូវផលប៉ះពាល់ពីអតិផរណាដូចគ្នា ហើយការប្រែប្រួលនៃអតិផរណានេះសម្រាប់កម្ពុជា និងថៃ ក៏បណ្តាលមកពីមូលហេតុមិនសូវខុសពីគ្នាប៉ុន្មាននោះទេ ដែលសម្រាប់សកម្ពុជាជាប្រទេសនាំចូល ក្នុងនោះរួមមានដូចជា ការនាំចូលប្រេងឥន្ធនៈ ម្ហូបអាហារពីបណ្តាប្រទេសជិតខាងដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗ ហេតុនេះហើយ កត្តាប្រែប្រួលថ្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ និងការប្រែប្រួលថ្លៃម្ហូបអាហារពីបណ្តារប្រទេសដែលនាំចូលមកកាន់កម្ពុជា បានជះឥទ្ធិពល និងដាក់សម្ពាធដល់អតិផរណានៅកម្ពុជាយ៉ាងខ្លាំង។ ចំណែកឯកត្តាតម្រូវការរូបិយវត្ថុនៅក្នុងស្រុក ក៏បានរួមចំណែកដល់ការប្រែប្រួលអតិផរណាកម្ពុជាផងដែរ។ យើងអាចធ្វើការកត់សម្គាល់បានថា មូលហេតុចម្បងដែលនូវតែបន្តធ្វើឲ្យប្រទេសកម្ពុជាជួបប្រទះវិបត្តិអតិផរណា គឺដោយសារតែកម្ពុជានូវជាប្រទេសនាំចូលទំនិញពីបណ្តាប្រទេសដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់ខ្លួន ដូច្នោះហើយរាល់ស្ថានភាពអតិផរណារបស់ប្រទេសជាដៃគូទាំងនោះ សុទ្ធតែបានជះឥទ្ធិពលដល់ស្ថានភាពអតិផរណាកម្ពុជា។ ចំពោះប្រទេសថៃ ក៏មិនសូវខុសពីកម្ពុជានោះដែរ មូលហេតុដែលនាំឲ្យមានការប្រែប្រួលអតិផរណានៅថៃ គឺបណ្តាលមកការប្រែប្រួលថ្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ និងថ្លៃដើមផលិតកម្ម។

មូលហេតុដូចដែលបានរៀបរាប់ខាងលើនេះហើយ ដែលបានបង្កទៅជាផលប៉ះពាល់ដល់សេដ្ឋកិច្ចក្នុងប្រទេស។ ប៉ុន្តែរាល់បញ្ហាទាំងអស់សុទ្ធតែមានដំណោះស្រាយ ក្នុងនោះរាជរដ្ឋាភិបាលនៃប្រទេសទាំងពីរបានចេញគោលនយោបាយក្នុងការទប់ស្កាត់ដើម្បីធានាថា អត្រាអតិផរណាស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន និងបន្តមានស្ថិរភាព។ ចំពោះរាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តន៍គោលនយោបាយរូបិយវត្ថុ ដែលក្នុងនោះរួមមានដូជា ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ដើម្បីធានាថាអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបន្តមានស្ថិរភាព, គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ ដើម្បីធានាថារូបិយវត្ថុដែលចរាចរលើទីផ្សារមិនលើសពីតម្រូវការប្រើប្រាស់ និងការអនុវត្តគោលនយោបាយដំឡើងប្រាក់បៀវត្សជូនដល់មន្ត្រីដែលចូលនិវត្ត ដើម្បីធានាថាការប្រែប្រួលនៃអត្រាអតិផរណាមិនបង្កជាផលប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពរស់ប្រទេសរបស់ពួកគេ។

យើងក្រឡេកមកមើលប្រទេសថៃឯណោះវិញ គឺរាជរដ្ឋាភិបាលនៃប្រទេសនេះ បានអនុវត្តន៍គោលនយោបាយសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុ។ ការស្វះស្វែងរកវិធីសាស្ត្រក្នុងការរក្សាឲ្យអតិផរណាស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងនេះ គឺដើម្បីបន្តធានាបញ្ហាដែលបណ្តាលមកពីការប្រែប្រួលអតិផរណានេះ មិន

សូវបង្កជាផលប៉ះពាល់ធំធេងពេកដល់សេដ្ឋកិច្ចក្នុងប្រទេស និងដើម្បីបន្តធានាថាសេដ្ឋកិច្ចជាតិនូវតែអាចបន្តរីកចម្រើន និងមានការអភិវឌ្ឍទៅមុខបានជានិច្ច។

## ២. ការផ្តល់អនុសាសន៍

ជាចុងក្រោយបន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើរួចមក យើងសង្កេតឃើញថា អតិផរណា នៅតែជាកត្តាចម្បងមួយក្នុងចំណោមកត្តាធំៗជាច្រើនទៀត ដែលបានបង្កជាបញ្ហាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ បញ្ហាអតិផរណានេះក៏ត្រូវបានខាងរាជរដ្ឋាភិបាល ជាពិសេសស្ថានប័នធនាគារជាតិនៃកម្ពុជា ដែលជាអ្នកដើរតួនាទីយ៉ាងសំខាន់ពុំអាចខ្វះបានក្នុងការរៀបចំគោលនយោបាយរូបិយវត្ថុ និងតែងតែយកចិត្តទុកដាក់ក្នុងការរិះរកវិធីសាស្ត្រ ក៏ដូចជាយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហា ឬធ្វើយ៉ាងណាឲ្យការប្រែប្រួលនៃអត្រាអតិផរណាក្នុងប្រទេសស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន និងមិនសូវបង្កជាការដាក់សម្ពាធខ្លាំងពេកដល់សេដ្ឋកិច្ចជាតិ។ ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលទាំងប៉ុន្មាននេះ ពិតណាស់បានជួយបន្ធូរបន្ថយសម្ពាធនៃកំណើនអតិផរណាមកដល់សេដ្ឋកិច្ចជាតិយ៉ាងច្រើន ថែមទាំងបានរួមចំណែកធ្វើឲ្យអត្រាអតិផរណានៅតែបន្តស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន។

ប៉ុន្តែទោះបីជាយ៉ាងណាក្តី ក៏យើងសង្កេតឃើញថាអតិផរណាកម្ពុជា នៅតែមានបញ្ហាប្រឈមដ៏រាបណា កម្ពុជានៅតែបន្តពឹងផ្អែកខ្លាំងលើការនាំចូលទំនិញពីប្រទេសដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់ខ្លួន ព្រោះថាប្រសិនបើប្រទេសទាំងនោះមានការប្រែប្រួលអតិផរណា ហើយក្នុងករណីដែលប្រទេសយើងមានការរឹតត្បិតលើទំនិញនាំចូល នោះវានឹងបង្កជាសម្ពាធដល់អតិផរណាកម្ពុជាដូចគ្នា។

ហេតុដូចនេះហើយ យើងខ្ញុំនឹងផ្តល់ជាអនុសាសន៍មួយចំនួនដូចខាងក្រោមនេះ៖

- បន្តធ្វើការសិក្សា តាមដាន និងយកចិត្តទុកដាក់វិភាគជាប្រចាំនូវរាល់បម្រែបម្រួលនៃអត្រាអតិផរណាក្នុងប្រទេស រួមទាំងប្រទេសជាដៃគូពាណិជ្ជកម្មដែលនាំចូលទំនិញមកកាន់កម្ពុជា
- ជំរុញ និងលើកទឹកចិត្តបន្ថែមក្នុងការវិនិយោគលើវិស័យផលិតកម្ម ព្រោះថាប្រសិនបើប្រទេសយើងមានលទ្ធភាពផលិតនូវផលិតផលបានខ្លួនឯង ហើយអាចកាត់បន្ថយការនាំចូលបានខ្លះ នោះយើងនឹងអាចជៀសវាងពីការទទួលរងឥទ្ធិពលនៃអតិផរណាពីបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មរបស់យើង ហើយលើសពីនេះទៅទៀត យើងក៏អាចរួមចំណែកក្នុងការពង្រីកទីផ្សារការងារក្នុងស្រុកឲ្យរីកចម្រើនដូចគ្នា ដែលបានផ្តល់ឱកាសការងារដល់ប្រជាពលរដ្ឋក្នុងស្រុកថែមទៀតផង
- លើកទឹកចិត្តដល់សិស្សានុសិស្ស និស្សិត បន្ត និងបង្កើនការការយកចិត្តទុកដាក់ស្រាវជ្រាវបន្ថែមលើប្រធានបទ អតិផរណានេះ ព្រោះថាវាជាកត្តាចម្បងមួយដែលអាចបង្កជាផលប៉ះពាល់ដល់សេដ្ឋកិច្ចជាតិទាំងមូលបាន ហេតុដូចនេះហើយ ការប្រែប្រួលនៃអតិផរណានូវតែអាចបន្តកើតមានឡើងជាដរាប

ទៅថ្ងៃមុន។ ដូច្នេះហើយ សិស្ស និស្សិតគួរតែខិតខំ យកចិត្តបន្តសិក្សាស្រាវជ្រាវឲ្យបានស៊ីជម្រៅទាក់ទងនឹងសេដ្ឋកិច្ចជាតិរបស់ខ្លួន ព្រោះថានៅពេលសិស្សនិស្សិតបានធ្វើការសិក្សាស្រាវជ្រាវកាន់តែច្រើនពីប្រទេសជាតិរបស់ខ្លួន នោះពួកគេនឹងបានរួមចំណែកក្នុងការស្វែងរកចំណុចខ្វះខាត និងចំណុចខ្លាំងរបស់ប្រទេសជាតិខ្លួន។

- លើកទឹកចិត្តដល់ប្រជាពលរដ្ឋគ្រប់រូប ងាកមកយកចិត្តទុកដាក់លើបញ្ហាសេដ្ឋកិច្ចជាតិ ព្រោះថាបញ្ហាដែលកើតមានឡើងនៅក្នុងប្រទេស បង្កជាផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋផ្ទាល់។ ហេតុដូចនេះ ប្រជាពលរដ្ឋគ្រប់រូបគួរតែត្រៀមលក្ខណៈឲ្យបានគ្រប់គ្រាន់ និងត្រូវរៀនសិក្សាស្វែងយល់បន្ថែមអំពីស្ថានភាព និងសុខភាពសេដ្ឋកិច្ចរបស់ប្រទេសខ្លួនឲ្យបានល្អប្រសើរ ព្រោះថាបើកាលណាប្រជាពលរដ្ឋនៃប្រទេសមួយស្គាល់ពីប្រទេសជាតិខ្លួនឯងច្បាស់ ប្រជាពលរដ្ឋនោះនឹងរស់នៅក្នុងស្ថានភាពប្រាកដប្រជា និងភាពច្បាស់លាស់។

# ឯកសារយោង

# ឯកសារយោង

## ឯកសារយោងជាភាសារខ្មែរ


- សៀវភៅម៉ាក្រូសេដ្ឋកិច្ចរបស់បណ្ឌិត ហង់ ជួន ណារ៉ុង ឆ្នាំ ២០០៩, ទំព័រ ៣៦
- តារាងតម្លៃ និងសេវាប្រចាំខែសម្រាប់ខែឧសភា ក្នុងឆ្នាំ២០២០, ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយដ្ឋានគោលនយោបាយ
- របាយការណ៍ប្រចាំ និងទិសដៅការងាររបស់ធនាគារជាតិនៃកម្ពុជា ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២១
- របាយការណ៍ស្តីពីអតិផរណាប្រចាំខែរបស់ធនាគារជាតិនៃកម្ពុជាពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២១
- របាយការណ៍ឆមាសទី ១ និងទិសដៅការងារឆមាសទី ២ ឆ្នាំ២០១៥ របស់ធនាគារជាតិនៃកម្ពុជា
- ខ្លឹមសារសង្ខេបប្រតិបត្តិស្តីពីសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ ២០១៩
- របាយការណ៍ពី World Bank Group ស្តីពីសេដ្ឋកិច្ចកម្ពុជា ត្រឹមឆ្នាំ២០២១


## ឯកសារយោងជាភាសារអង់គ្លេស


- BOT Annual Report, (Bank of Thailand) from 2015-2021
- Monetary Report of Thailand (2015-2021)
- Principles of Economics, Eighth Edition N. GREGORY MANKIW, Print year: 2016


## ឯកសារយោងពីគេហទំព័រ


1. ស្វែងយល់ពី អតិផរណា / Inflation ( និយមន័យ, ប្រភេទ, និងផលប៉ះពាល់) (psndaily.wixsite.com) (ចូលមើលថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២)
2. https://www.worldbank.org/en/country/cambodia/overview#:~:text=The%20World%20Bank's%20engagement%20in,basic%20infrastructure%2C%20and%20empowering%20communities (ចូលមើលថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២២)
3. https://www.facebook.com/CambonomicTimes/posts/414904180170401/ (ចូលមើលថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២២)
4. https://www.thebalance.com/types-of-inflation-4-different-types-plus-more-3306109 (ចូលមើលថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២២)
5. https://moneyclubber.com/blog/inflation/ (ចូលមើលថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២)
6. https://data.worldbank.org/indicator/FP.CPI.TOTL.ZG?locations=KH (ចូលមើលថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២)

7. https://www.phnompenhpost.com/business/regular-petrol-diesel-rates-set-5150-and-5500-riel (ចូលមើលថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២)
8. https://www.moneyhelper.org.uk/en/savings/how-to-save/inflation-what-the-saver-needs-to-know (ចូលមើលថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២)
9. https://www.bis.org/publ/bppdf/bispap122_w.pdf (ចូលមើលថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២)
10. https://www.bot.or.th/English/MonetaryPolicy/MonetPolicyComittee/MPR/BOX_MRP/BOX1_AssessingRiskDeflationThailand.pdf (ចូលមើលថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២)
11. https://www.worldbank.org/en/country/thailand/overview#1 (ចូលមើលថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២)
12. https://www.nationthailand.com/business/30238673 (ចូលមើលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២)
13. https://data.worldbank.org/indicator/FP.CPI.TOTL?locations=KH (ចូលមើលថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២)
14. https://data.worldbank.org/indicator/FP.CPI.TOTL?locations=TH (ចូលមើលថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២)
15. https://www.nbc.org.kh/about_the_bank/banking_terms.php (ចូលមើលថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០២២)
16. http://nis.gov.kh/index.php/km/20-cpi/31-cpi-tables (ចូលមើលថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២)

# បញ្ជីឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី ២
# ប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗ

| រូបិយប័ណ្ណ | ២០១៤ | ២០១៥ | | | | | | | | | | | | បម្រែបម្រួល% |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ធ្នូ-១៥ /ធ្នូ-១៤ |
| អេសដេអែរ | ៥.៩០២ | ៥.៧២០ | ៥.៦៩៥ | ៥.៥៤៨ | ៥.៦៥៨ | ៥.៦៥៣ | ៥.៧៥០ | ៥.៧៣៥ | ៥.៧៤៦ | ៥.៧១៥ | ៥.៦៥៨ | ៥.៥៥៥ | ៥.៦១៧ | -៤,៨៣ |
| **អាស៊ី** | | | | | | | | | | | | | | |
| ដុល្លារ-អូស្ត្រាលី | ៣.៣១០ | ៣.១៥៩ | ៣.១៤៥ | ៣.០៧១ | ៣.២៣៩ | ៣.១១៤ | ៣.១៤៦ | ៣.០០០ | ២.៩១៥ | ២.៨៥៦ | ២.៨៨៣ | ២.៩០៥ | ២.៩៥០ | -១០,៨៨ |
| ដុល្លារ-ហុងកុង | ៥២៥ | ៥២៤ | ៥១៩ | ៥១៧ | ៥២៣ | ៥២៥ | ៥២៩ | ៥៣១ | ៥២៧ | ៥២៦ | ៥២៤ | ៥២២ | ៥២៣ | -០,៣៨ |
| យ៉េន-ជប៉ុន | ៣៤,១១ | ៣៤,៣៤ | ៣៣,៧៧ | ៣៣,៤០ | ៣៤,០៥ | ៣២,៨៦ | ៣៣,៤៣ | ៣៣,១៨ | ៣៣,៦៤ | ៣៣,៩៩ | ៣៣,៥៦ | ៣២,៩២ | ៣៣,៦២ | -១,៤៤ |
| វ៉ុន-កូរ៉េ | ៣,៧២ | ៣,៦៩ | ៣,៦៦ | ៣,៦២ | ៣,៧៩ | ៣,៦៧ | ៣,៦៦ | ៣,៥២ | ៣,៤៥ | ៣,៤១ | ៣,៥៧ | ៣,៥០ | ៣,៥ | -៧,៥៣ |
| ដុល្លារ-ញ៉ូស៊ីឡែន | ៣.១៩១ | ២.៩៥៤ | ៣.០៣៨ | ៣.០១០ | ៣.០៨០ | ២.៩២០ | ២.៨០៤ | ២.៧១៧ | ២.៦៣៨ | ២.៥៩២ | ២.៧៣៥ | ២.៦៣៩ | ២.៧៧១ | -១៣,១៦ |
| យ័ន់ចិន | ៦៥៧ | ៦៥០ | ៦៤៣ | ៦៤៦ | ៦៥៣ | ៦៥៦ | ៦៦០ | ៦៦២ | ៦៣៩ | ៦៤១ | ៦៣៩ | ៦៣២ | ៦២៤ | -៥,០២ |
| ដុល្លារ-តៃវ៉ាន់ | ១២៨ | ១២៩ | ១២៨ | ១២៨ | ១៣៣ | ១៣៣ | ១៣២ | ១៣០ | ១២៧ | ១២៣ | ១២៥ | ១២៤ | ១២៣ | -៣,៩១ |
| **អាស៊ាន** | | | | | | | | | | | | | | |
| រ៉ូពី-ឥណ្ឌូណេស៊ី | ០,៣២៨ | ០,៣២៣ | ០,៣១៤ | ០,៣០៧ | ០,៣១៣ | ០,៣០៨ | ០,៣០៧ | ០,៣០៦ | ០,២៩២ | ០,២៧៨ | ០,២៩៨ | ០.២៩៣ | ០.២៩៤ | -១០,៣៧ |
| រីងហ្គីត-ម៉ាឡេស៊ី | ១.១៦៦ | ១.១១៨ | ១.១២០ | ១.០៨០ | ១.១៤១ | ១.១១៦ | ១.០៨៧ | ១.០៧៨ | ៩៧៤ | ៩១៦ | ៩៤២ | ៩៥១ | ៩៤៤ | -១៩,០៤ |
| ប៉េសូ-ហ្វីលីពីន | ៩១,១៧ | ៩២,៣០ | ៩១,៤៧ | ៨៩,៥៧ | ៩១,៤០ | ៩១,២៤ | ៩០,៩៣ | ៩០,១៤ | ៨៧,៤២ | ៨៦,៩៤ | ៨៦,៥៤ | ៨៥,៩ | ៨៦,៣ | -៥,៣៤ |
| ដុល្លារ-សាំងហ្គាពួរ | ៣.០៨៣ | ៣.០០២ | ២.៩៦៩ | ២.៩១៤ | ៣.០៦៦ | ៣.០១៧ | ៣.០៤៤ | ២.៩៩៥ | ២.៨៩៦ | ២.៨៥៥ | ២.៨៩៩ | ២.៨៦២ | ២.៨៦៣ | -៧,១៤ |
| បាត-ថៃ | ១២៤ | ១២៤ | ១២៤ | ១២៣ | ១២៣ | ១២០ | ១២១ | ១១៧ | ១១៤ | ១១២ | ១១៤ | ១១៣ | ១១២ | -៩,៦៨ |
| ដុង-វៀតណាម | ០,១៩១ | ០,១៩០ | ០,១៨៩ | ០,១៨៦ | ០,១៨៨ | ០,១៨៧ | ០,១៨៨ | ០,១៨៩ | ០,១៨២ | ០,១៨១ | ០,១៨២ | ០,១៨០ | ០,១៨១ | -៥,២៤ |
| **អឺរ៉ុប** | | | | | | | | | | | | | | |
| អឺរ៉ូ | ៤.៩៥៥ | ៤.៥៩៨ | ៤.៥១៤ | ៤.៣៤៦ | ៤.៥០១ | ៤.៤៥៧ | ៤.៥៩៥ | ៤.៥០០ | ៤.៥៧៦ | ៤.៥៨៦ | ៤.៤៦១ | ៤.២៨១ | ៤.៤២៩ | -១០,៦២ |
| **ផ្សេង** | | | | | | | | | | | | | | |
| ផោន-អង់គ្លេស | ៦.៣៤២ | ៦.១២១ | ៦.២១១ | ៥.៩៣៩ | ៦.២៤៨ | ៦.២៣២ | ៦.៤៤៧ | ៦.៤២០ | ៦.២៩០ | ៦.១៧៦ | ៦.២២៤ | ៦.០៨១ | ៦.០០០ | -៥,៣៩ |

| រូបិយប័ណ្ណ | ២០១៥ | ២០១៦ | | | | | | | | | | | | បម្រែបម្រួល% |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ធ្នូ-១៦ /ធ្នូ-១៥ |
| អេសដេអែរ | ៥.៦១៧ | ៥.៥៨១ | ៥.៥៦៥ | ៥.៦៣៥ | ៥.៧៣៩ | ៥.៧៤៣ | ៥.៧០១ | ៥.៦៩៦ | ៥.៧១៧ | ៥.៧០៨ | ៥.៥៥៥ | ៥.៤៤៩ | ៥.៤១០ | -៣,៧ |
| **អាស៊ី** | | | | | | | | | | | | | | |
| ដុល្លារ-អូស្ត្រាលី | ២.៩៥០ | ២.៨៥៧ | ២.៨៥០ | ៣.០៧០ | ៣.០៩៩ | ២.៩៤០ | ៣.០៤៨ | ៣.០៧៧ | ៣.០៨១ | ៣.១៣៨ | ៣.០៧៣ | ៣.០១៨ | ២.៩២១ | -១,០ |
| ដុល្លារ-ហុងកុង | ៥២៣ | ៥១៨ | ៥១៦ | ៥១៧ | ៥២៣ | ៥២៦ | ៥២៦ | ៥២៨ | ៥២៨ | ៦១០ | ៥២២ | ៥៨៣ | ៥២១ | -០,៤ |
| យ៉េន-ជប៉ុន | ៣៣,៦២ | ៣៣,៩៦ | ៣៥,២៥ | ៣៥,៦៥ | ៣៧,៥៦ | ៣៦,៨៥ | ៣៩,៧៥ | ៣៩,១០ | ៣៩,៨០ | ៤០,៤០ | ៣៨,៦៤ | ៣៥,៨៧ | ៣៤,៦៧ | ៣,១ |
| វ៉ុន-កូរ៉េ | ៣,៤៤ | ៣,៣៥ | ៣,២២ | ៣,៥ | ៣,៥៧ | ៣,៤៤ | ៣,៥៤ | ៣,៦៥ | ៣,៦៦ | ៣,៧៤ | ៣,៥៣ | ៣,៤៦ | ៣,៣៤ | -២,៩ |
| ដុល្លារ-ញ៉ូស៊ីឡែន | ២.៧៧១ | ២.៦១៣ | ២.៦៣៤ | ២.៧៦៦ | ២.៨២៧ | ២.៧៤១ | ២.៩០៥ | ២.៩០៤ | ២.៩៦៦ | ២.៩៧១ | ២.៨៩៣ | ២.៨៧៧ | ២.៨១៣ | ១,៥ |
| យ័ន់ចិន | ៦២៤ | ៦១៤ | ៦១៣ | ៦២០ | ៦២៧ | ៦២១ | ៦១៦ | ៦១៦ | ៦១៣ | ៦១១ | ៥៩៨ | ៥៨៤ | ៥៨០ | -៧,១ |
| ដុល្លារ-តៃវ៉ាន់ | ១២៣ | ១២០ | ១២១ | ១២៤ | ១២៦ | ១២៥ | ១២៦ | ១២៨ | ១២៩ | ១៣០ | ១២៨ | ១២៧ | ១២៥ | ១,៦ |
| **អាស៊ាន** | | | | | | | | | | | | | | |
| រ៉ូពី-ឥណ្ឌូណេស៊ី | ០,២៩៤ | ០,២៩១ | ០,៣ | ០,៣០២ | ០,៣០៨ | ០,៣ | ០,៣១១ | ០,៣១៣ | ០,៣០៩ | ០,៣១៥ | ០,៣១០ | ០,២៩៧ | ០,៣០០ | ២,០ |
| រីងហ្គីត-ម៉ាឡេស៊ី | ៩៤៤ | ៩៦៨ | ៩៤៩ | ១.០២១ | ១.០៤៦ | ៩៩៥ | ១.០១៨ | ១.០១២ | ១.០១០ | ៩៩៣ | ៩៦៤ | ៩០៤ | ៩០១ | -៤,៦ |
| ប៉េសូ-ហ្វីលីពីន | ៨៦,៣០ | ៨៤,៦២ | ៨៤,៥៦ | ៨៧,០៨ | ៨៦,៧៧ | ៨៧,៤៩ | ៨៧,០៨ | ៨៧,០៦ | ៨៨,២២ | ៨៤,៧១ | ៨៣,៦៦ | ៨១.០០ | ៨១,១៩ | ៥,៩ |
| ដុល្លារ-សាំងហ្គាពួរ | ២.៨៦៣ | ២.៨២៧ | ២.៨៤០ | ២.៩៦៦ | ៣.០២១ | ២.៩៦២ | ៣.០៣៣ | ៣.០៣០ | ៣.០០៤ | ៣.០០២ | ២.៩០៨ | ២.៨៣០ | ២.៧៩២ | -២,៥ |
| បាត-ថៃ | ១១២ | ១១៣ | ១១២ | ១១៤ | ១១៦ | ១១៤ | ១១៦ | ១១៨ | ១១៨ | ១១៨ | ១១៦ | ១១៣ | ១១២ | ០,០ |
| ដុង-វៀតណាម | ០,១៨១ | ០,១៨២ | ០,១៨០ | ០,១៨០ | ០,១៨២ | ០,១៨២ | ០,១៨៣ | ០,១៨៤ | ០,១៨៤ | ០,១៨៣ | ០,១៨២ | ០,១៧៨ | ០,១៧៨ | -១,៧ |
| **អឺរ៉ុប** | | | | | | | | | | | | | | |
| អឺរ៉ូ | ៤.៤២៩ | ៤.៤១៣ | ៤.៣៨១ | ៤.៥៤០ | ៤.៦១១ | ៤.៥៥៤ | ៤.៥៣៩ | ៤.៥៤១ | ៤.៥៦៥ | ៤.៥៧៨ | ៤.៤៤៤ | ៤.២៩២ | ៤.២៦៥ | -៣,៧ |
| **ផ្សេង** | | | | | | | | | | | | | | |
| ផោន-អង់គ្លេស | ៦.០០០ | ៥.៧៩៤ | ៥.៥៥៥ | ៥.៧៥៧ | ៥.៩៣៣ | ៥.៩៨១ | ៥.៤៨៩ | ៥.៣៩៣ | ៥.៣៦០ | ៥.៣២១ | ៤.៩៣៧ | ៥.០៣៤ | ៤.៩៦០ | -១៧,៣ |

| រូបិយប័ណ្ណ | ២០១៥ | ២០១៦ | ២០១៧ | | | | | | | | | | | បម្រែបម្រួល% វិច្ឆិកា-១៧ /ធ្នូ-១៦ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | |
| អេសដេអែរ | ៥.៦១៧ | ៥.៤១០ | ៥.៤៦៥ | ៥.៤១៦ | ៥.៤៤៦ | ៥.៥២៣ | ៥.៦១៨ | ៥.៦៨២ | ៥.៧៦០ | ៥.៧៤៤ | ៥.៧២២ | ៥.៦៦៦ | ៥.៧១៥ | ៥,៦ |
| **អាស៊ី** | | | | | | | | | | | | | | |
| ដុល្លារ-អូស្ត្រាលី | ២.៩៥០ | ២.៩២១ | ៣.០៥១ | ៣.០៧៣ | ៣.០៦១ | ៣.០១២ | ៣.០៣៨ | ៣.១៤៣ | ៣.២៦៧ | ៣.០២១ | ៣.១៨០ | ៣.១០៥ | ៣.០៥៣ | ៤,៥ |
| ដុល្លារ-ហុងកុង | ៥២៣ | ៥២១ | ៥២០ | ៥១៦ | ៥១៥ | ៥១៨ | ៥២២ | ៥២៤ | ៥២៥ | ៥១៨ | ៥១៩ | ៥១៨ | ៥១៧ | -០,៨ |
| យ៉េន-ជប៉ុន | ៣៣,៦២ | ៣៤,៦៧ | ៣៥,៥១ | ៣៥,៥០ | ៣៥,៨២ | ៣៦,២៣ | ៣៦,៧១ | ៣៦,៤៥ | ៣៧,០៨ | ៣៦,៦៤ | ៣៦,០៤ | ៣៥,៧២ | ៣៦.០៣ | ៣,៩ |
| វ៉ុន-កូរ៉េ | ៣,៤៤ | ៣,៣៤ | ៣,៤៥ | ៣,៥៣ | ៣,៥៨ | ៣,៥៧ | ៣,៦២ | ៣,៥៧ | ៣,៦៥ | ៣,៦០ | ៣,៥៣ | ៣,៦០ | ៣.៧៣ | ១១,៧ |
| ដុល្លារ-ញ៉ូស៊ីឡែន | ២.៧៧១ | ២.៨១៣ | ២.៩៤២ | ២.៨៧៥ | ២.៨០១ | ២.៧៧៥ | ២.៨៨៣ | ២.៩៩០ | ៣.០៧៩ | ២.៩១៦ | ២.៩២៧ | ២.៧៧២ | ២.៧៦៥ | -១,៧ |
| យ៉ន់ចិន | ៦២៤ | ៥៨០ | ៥៨៧ | ៥៨៣ | ៥៨២ | ៥៨៥ | ៥៩៤ | ៦០២ | ៦០៨ | ៦១៤ | ៦០៩ | ៦០៨ | ៦១០ | ៥,២ |
| ដុល្លារ-តៃវ៉ាន់ | ១២៣ | ១២៥ | ១២៨ | ១៣១ | ១៣២ | ១៣៤ | ១៣៥ | ១៣៤ | ១៣៦ | ១៣៤ | ១៣៣ | ១៣៤ | ១៣៥ | ៨,០ |
| **អាស៊ាន** | | | | | | | | | | | | | | |
| រ៉ូពី-ឥណ្ឌូណេស៊ី | ០,២៩៤ | ០,៣០០ | ០,៣០២ | ០,៣០០ | ០,៣០១ | ០,៣០៣ | ០,៣០៥ | ០,៣០៧ | ០,៣០៨ | ០,៣០៤ | ០,៣០០ | ០,២៩៧ | ០,២៩៩ | -០,៣ |
| រីងហ្គីត-ម៉ាឡេស៊ី | ៩៤៤ | ៩០១ | ៩១២ | ៩០២ | ៩០៦ | ៩២៩ | ៩៥១ | ៩៥២ | ៩៥៨ | ៩៤៨ | ៩៥៨ | ៩៥៤ | ៩៨៨ | ៩,៧ |
| ប៉េសូ-ហ្វីលីពីន | ៨៦,៣០ | ៨១,១៩ | ៨១,១២ | ៧៩,៦៥ | ៧៩,៨៥ | ៨០,៥០ | ៨១,៧៦ | ៨០,៨៦ | ៨១,១០ | ៧៩,២០ | ៧៩,៥៨ | ៧៨,២០ | ៨០,៣៥ | -១,០ |
| ដុល្លារ-សាំងហ្គាពួរ | ២.៨៦៣ | ២.៧៩២ | ២.៨៤២ | ២.៨៤៩ | ២.៨៦៥ | ២.៨៨៧ | ២.៩៣៦ | ២.៩៦៤ | ៣.០១៩ | ២.៩៨២ | ២.៩៨៤ | ២.៩៦៧ | ២.៩៩៥ | ៧,៣ |
| បាត-ថៃ | ១១២ | ១១២ | ១១៥ | ១១៥ | ១១៦ | ១១៧ | ១១៩ | ១២០ | ១២៣ | ១២២ | ១២១ | ១២២ | ១២៤ | ១០,៧ |
| ដុង-វៀតណាម | ០,១៨១ | ០,១៧៨ | ០,១៧៩ | ០,១៧៦ | ០,១៧៦ | ០,១៧៧ | ០,១៧៩ | ០,១៨០ | ០,១៨០ | ០,១៧៨ | ០,១៧៩ | ០,១៧៨ | ០,១៧៨ | ០,០ |
| **អឺរ៉ុប** | | | | | | | | | | | | | | |
| អឺរ៉ូ | ៤.៤២៩ | ៤.២៦៥ | ៤.៣១៩ | ៤.២៣៧ | ៤.២៧៨ | ៤.៣៨៤ | ៤.៥៤៦ | ៤.៦៧២ | ៤.៨១២ | ៤.៨១៤ | ៤.៧៧៥ | ៤.៧០២ | ៤.៧៨៣ | ១២,១ |
| **ផ្សេង** | | | | | | | | | | | | | | |
| ផោន-អង់គ្លេស | ៦.០០០ | ៤.៩៦០ | ៥.០៤៣ | ៤.៩៨១ | ៤.៩៩៧ | ៥.២០២ | ៥.២១៣ | ៥.៣១៥ | ៥.៣៨៥ | ៥.២៣១ | ៥.៤៤៣ | ៥.៣៣២ | ៥.៤១១ | ៩,១ |

***ទិន្នន័យព្យាករណ៍**

| រូបិយប័ណ្ណ | ២០១៦ | ២០១៧ | ២០១៨ | | | | | | | | | | | | បម្រែបម្រួល% |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ធ្នូ-១៨/ធ្នូ-១៧ |
| អេសដេអែរ | ៥.៤១ | ៥.៧៣៥ | ៥.៨៣៣ | ៥.៨២ | ៥.៨១៥ | ៥.៧៩៧ | ៥.៧៦៣ | ៥.៧០៨ | ៥.៦៩៦ | ៥.៧២៧ | ៥.៧២៣ | ៥.៦១២ | ៥.៥៧៦ | ៥.៥៨៨ | -២,៦ |
| **អាស៊ី** | | | | | | | | | | | | | | | |
| ដុល្លារ-អូស្ត្រាលី | ២.៩២១ | ៣.១៤៧ | ៣.២៥២ | ៣.១២៥ | ៣.០៧៤ | ៣.០៤៥ | ៣.០៨៥ | ២.៩៨៥ | ៣.០០៨ | ២.៩៦៤ | ២.៩៤១ | ២.៨៨៤ | ២.៩៥១ | ២.៨៣២ | -១០,០ |
| ដុល្លារ-ហុងកុង | ៥២១ | ៥១៦ | ៥១៤ | ៥១២ | ៥១០ | ៥១៤ | ៥១៩ | ៥១៨ | ៥១៧ | ៥២០ | ៥២២ | ៥១៨ | ៥១៥ | ៥១៣ | -០,៦ |
| យ៉េន-ជប៉ុន | ៣៤,៦៧ | ៣៥,៧៤ | ៣៦,៨៦ | ៣៧,៣០ | ៣៧,៥៧ | ៣៦,៩៤ | ៣៧,៥៣ | ៣៦,៧៩ | ៣៦,៦០ | ៣៦,៨១ | ៣៦,០០ | ៣៥,៨៩ | ៣៥,៥៥ | ៣៦,៤១ | ១,៩ |
| វ៉ុន-កូរ៉េ | ៣,៣៤ | ៣,៧៨ | ៣,៧៥ | ៣,៧១ | ៣,៧៦ | ៣,៧៥ | ៣.៧៨ | ៣,៦៣ | ៣,៦៣ | ៣,៦៦ | ៣,៦៦ | ៣,៥៦ | ៣,៦០ | ៣,៦២ | -៤,២ |
| ដុល្លារ-ញ៉ូស៊ីឡែន | ២.៨១៣ | ២.៨៦៣ | ២.៩៤៣ | ២.៨៩៦ | ២.៨៩១ | ២.៨៥៣ | ២.៨៤៦ | ២.៧៤៦ | ២.៧៧១ | ២.៧២១ | ២.៦៩៩ | ២.៦៦៥ | ២.៧៦៧ | ២.៦៩៦ | -៥,៨ |
| យ៉ន់ចិន | ៥៨០ | ៦១៨ | ៦៣៤ | ៦៣៥ | ៦៣៦ | ៦៣៧ | ៦៣៥ | ៦១៣ | ៥៩៦ | ៥៩៧ | ៥៩៣ | ៥៨៣ | ៥៨១ | ៥៨៤ | -៥,៥ |
| ដុល្លារ-តៃវ៉ាន់ | ១២៥ | ១៣៦ | ១៣៨ | ១៣៧ | ១៣៧ | ១៣៦ | ១៣៦ | ១៣៣ | ១៣៣ | ១៣៣ | ១៣៤ | ១៣១ | ១៣១ | ១៣២ | -២,៩ |
| **អាស៊ាន** | | | | | | | | | | | | | | | |
| រ៉ូពី-ឥណ្ឌូណេស៊ី | ០,៣០០ | ០,២៩៨ | ០,៣០០ | ០,២៩៣ | ០,២៩១ | ០,២៩០ | ០,២៩១ | ០,២៨២ | ០,២៨២ | ០,២៧៨ | ០,២៧៤ | ០,២៦៧ | ០,២៨ | ០,២៨ | -៧,០ |
| រីងហ្គីត-ម៉ាឡេស៊ី | ៩០១ | ៩៩៤ | ១.០៣៣ | ១.០២២ | ១.០៣៥ | ១.០២៩ | ១.០២២ | ១.០០៥ | ១.០០០ | ៩៩៤ | ៩៨៥ | ៩៧១ | ៩៦៣ | ៩៦៩ | -២,៥ |
| ប៉េសូ-ហ្វីលីពីន | ៨១,១៩ | ៨០,៩៤ | ៧៨,៤១ | ៧៧,១២ | ៧៦,៥៤ | ៧៧,៧១ | ៧៧,៤៤ | ៧៥,៩៣ | ៧៦,៣២ | ៧៦,៣៤ | ៧៥,៤២ | ៧៥,៨៣ | ៧៦,៩៣ | ៧៦,៥៣ | -៥,៤ |
| ដុល្លារ-សាំងហ្គាពួរ | ២.៧៩២ | ៣.០១៧ | ៣.០៦៤ | ៣.០២៧ | ៣.០៥ | ៣.០៤៥ | ៣.០៤៣ | ២.៩៧២ | ២.៩៨៤ | ២.៩៨៥ | ២.៩៨៤ | ២.៩៣១ | ២.៩៤៣ | ២.៩៤២ | -២,៥ |
| បាត-ថៃ | ១១២ | ១២៤ | ១២៨ | ១២៨ | ១២៨ | ១២៨ | ១២៧ | ១២៣ | ១២២ | ១២៥ | ១២៦ | ១២២ | ១២២ | ១២៤ | ០,០ |
| ដុង-វៀតណាម | ០,១៧៨ | ០,១៧៨ | ០,១៧៧ | ០,១៧៦ | ០,១៧៥ | ០,១៧៧ | ០,១៧៩ | ០,១៧៧ | ០,១៧៥ | ០,១៧៥ | ០,១៧៥ | ០,១៧៤ | ០,១៧ | ០,១៧ | -២,២ |
| **អឺរ៉ុប** | | | | | | | | | | | | | | | |
| អឺរ៉ូ | ៤.២៦៥ | ៤.៨២១ | ៤.៩៧១ | ៤.៩០៣ | ៤.៩១៩ | ៤.៨៨៧ | ៤.៧៥១ | ៤.៧០១ | ៤.៧៥៣ | ៤.៧៦៣ | ៤.៧៥១ | ៤.៦០៦ | ៤.៥៩២ | ៤.៥៩៧ | -៤,៦ |
| **ផ្សេង** | | | | | | | | | | | | | | | |
| ផោន-អង់គ្លេស | ៤.៩៦ | ៥.៤២៦ | ៥.៦៥១ | ៥.៥៧៤ | ៥.៦០៩ | ៥.៥៥២ | ៥.៣១២ | ៥.៣១៤ | ៥.៣៣២ | ៥.៣១២ | ៥.៣៣៨ | ៥.១៦ | ៥.១៥៣ | ៥.០៩៨ | -៦,០ |

**ទិន្នន័យព្យាករណ៍*

| រូបិយប័ណ្ណ | ២០១៧ | ២០១៨ | ២០១៩ | | | | | | | | | | | បម្រែបម្រួល% |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | វិច្ឆិកា-១៩/ធ្នូ-១៨ |
| អេសដេអែរ | ៥.៧៣៥ | ៥.៥៨៨ | ៥.៦០៤ | ៥.៥៩៥ | ៥.៥៧៣ | ៥.៥៩៥ | ៥.៥៩៥ | ៥.៦៥២ | ៥.៦២០ | ៥.៦០០ | ៥.៥៨៧ | ៥.៥៧៣ | ៥.៥៨១ | -០,១ |
| **អាស៊ី** | | | | | | | | | | | | | | |
| ដុល្លារ-អូស្ត្រាលី | ៣.១៤៧ | ២.៨៣២ | ២.៩១៣ | ២.៨៦៥ | ២.៨៤៥ | ២.៨៥៤ | ២.៨០៥ | ២.៨៣៨ | ២.៨០៨ | ២.៧៥៣ | ២.៧៦៩ | ២.៧៥៤ | ២.៧៥២ | -២,៨ |
| ដុល្លារ-ហុងកុង | ៥១៦ | ៥១៣ | ៥១២ | ៥១០ | ៥១១ | ៥១៦ | ៥១៨ | ៥២០ | ៥២២ | ៥២១ | ៥២២ | ៥១៦ | ៥១៩ | ១,២ |
| យ៉េន-ជប៉ុន | ៣៥,៧៤ | ៣៦,៤១ | ៣៦,៨៣ | ៣៦,១០ | ៣៦,៣១ | ៣៦,២៩ | ៣៧,១៧ | ៣៧,៧៦ | ៣៧,៦៤ | ៣៨,៤០ | ៣៧,៩៣ | ៣៧,២០ | ៣៧,១០ | ១,៩ |
| វ៉ុន-កូរ៉េ | ៣,៧៨ | ៣,៦២ | ៣,៦១ | ៣,៥៨ | ៣,៥៣ | ៣,៥០ | ៣,៤១ | ៣,៥២ | ៣,៤៦ | ៣,៣៨ | ៣,៤១ | ៣,៤៨ | ៣,៤៥ | -៤,៧ |
| ដុល្លារ-ញូវស៊ីឡែន | ២.៨៦៣ | ២.៦៩៦ | ២.៧៧៣ | ២.៧៤១ | ២.៧២៣ | ២.៧០២ | ២.៦៤២ | ២.៧២៧ | ២.៧០៣ | ២.៥៨១ | ២.៥៧១ | ២.៥៥៥ | ២.៦០៩ | -៣,២ |
| យ៉ន់ចិន | ៦១៨ | ៥៨៤ | ៥៩៧ | ៥៩៩ | ៥៩៦ | ៦០២ | ៥៨៩ | ៥៩១ | ៥៩៤ | ៥៧២ | ៥៧៥ | ៥៧៤ | ៥៧៨ | -១,០ |
| ដុល្លារ-តៃវ៉ាន់ | ១៣៦ | ១៣២ | ១៣០ | ១៣០ | ១៣០ | ១៣១ | ១២៩ | ១៣១ | ១៣២ | ១៣០ | ១៣២ | ១៣៣ | ១៣៣ | ០,៨ |
| **អាស៊ាន** | | | | | | | | | | | | | | |
| រ៉ូពី-ឥណ្ឌូណេស៊ី | ០,២៩៨ | ០,២៧៧ | ០,២៨៤ | ០,២៨៥ | ០,២៨២ | ០,២៨៥ | ០,២៨២ | ០,២៨៨ | ០,២៩១ | ០,២៨៧ | ០,២៨៩ | ០,២៨៩ | ០,២៨៩ | ៤,៣ |
| រីងហ្គីត-ម៉ាឡេស៊ី | ៩៩៤ | ៩៦៩ | ៩៨១ | ៩៨៤ | ៩៨៥ | ៩៨១ | ៩៦៩ | ៩៨២ | ៩៩១ | ៩៦៩ | ៩៧៨ | ៩៦៩ | ៩៧៥ | ០,៦ |
| ប៉េសូ-ហ្វីលីពីន | ៨០,៩៤ | ៧៦,៥៣ | ៧៦,៦៨ | ៧៧,១៤ | ៧៦,១១ | ៧៧,៧៣ | ៧៧,៨៦ | ៧៩,៣១ | ៨០,៤០ | ៧៨,៤២ | ៧៨,៩៦ | ៧៩,៥០ | ៨០,០៨ | ៤,៦ |
| ដុល្លារ-សាំងហ្គាពួរ | ៣.០១៧ | ២.៩៤២ | ២.៩៧៩ | ២.៩៧ | ២.៩៦១ | ២.៩៧៥ | ២.៩៤៣ | ៣.០០៦ | ២.៩៨១ | ២.៩៤៦ | ២.៩៦៤ | ២.៩៧៣ | ២.៩៧៦ | ១,២ |
| បាត-ថៃ | ១២៤ | ១២៤ | ១២៨ | ១២៧ | ១២៦ | ១២៧ | ១២៨ | ១៣២ | ១៣៣ | ១៣៤ | ១៣៤ | ១៣៤ | ១៣៤ | ៨,១ |
| ដុង-វៀតណាម | ០,១៧៨ | ០,១៧៤ | ០,១៧៣ | ០,១៧៣ | ០,១៧៣ | ០,១៧៤ | ០,១៧៣ | ០,១៧៤ | ០,១៧៦ | ០,១៧៦ | ០,១៧៧ | ០,១៧៤ | ០,១៧៥ | ០,៦ |
| **អឺរ៉ុប** | | | | | | | | | | | | | | |
| អឺរ៉ូ | ៤.៨២១ | ៤.៥៩៧ | ៤.៦១០ | ៤.៥៥៥ | ៤.៥១០ | ៤.៥១៥ | ៤.៥២៣ | ៤.៦២៤ | ៤.៥៥៨ | ៤.៥២០ | ៤.៤៨០ | ៤.៥១៦ | ៤.៤៧៦ | -២,៦ |
| **ផ្សេងៗ** | | | | | | | | | | | | | | |
| ផោន-អង់គ្លេស | ៥.៤២៦ | ៥.០៩៨ | ៥.២៦៤ | ៥.៣៣១ | ៥.២៤៤ | ៥.២៣៣ | ៥.១២៣ | ៥.១៥៤ | ៤.៩៦៧ | ៤.៩៨១ | ៥.០៣៤ | ៥.២២៤ | ៥.២៤៨ | ២,៩ |

**ទិន្នន័យព្យាករណ៍*

| រូបិយប័ណ្ណ | ២០១៨ | ២០១៩ | ២០២០ | | | | | | | | | | | បម្រែបម្រួល% |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | វិច្ឆិកា-២០/ធ្នូ-១៩ |
| អេសដេអែរ | ៥.៥៨៨ | ៥.៦៣៥ | ៥.៥៧២ | ៥.៥៧៥ | ៥.៥៧៨ | ៥.៥៩១ | ៥.៦២១ | ៥.៦៣១ | ៥.៧៦៨ | ៥.៨២២ | ៥.៧៧០ | ៥.៧៥៦ | ៥.៧៦៩ | ២,៤ |
| **អាស៊ី** | | | | | | | | | | | | | | |
| ដុល្លារ-អូស្ត្រាលី | ២.៨៣២ | ២.៨៥៣ | ២.៧១៨ | ២.៦៧៨ | ២.៥១៣ | ២.៦៨៤ | ២.៧២៨ | ២.៨១៣ | ២.៩៥៣ | ៣.០២០ | ២.៩៣០ | ២.៨៩១ | ២.៩៩៦ | ៥,០ |
| ដុល្លារ-ហុងកុង | ៥១៣ | ៥២៣ | ៥២១ | ៥២២ | ៥២៥ | ៥២៩ | ៥៣១ | ៥២៨ | ៥២៩ | ៥៣០ | ៥២៩ | ៥២៤ | ៥២២ | -០,២ |
| យ៉េន-ជប៉ុន | ៣៦,៤១ | ៣៧,៤៣ | ៣៧,១៨ | ៣៧,១១ | ៣៧,៦៨ | ៣៨,៤៣ | ៣៨,២៤ | ៣៨,០២ | ៣៩,១៩ | ៣៨,៩៦ | ៣៨,៧៨ | ៣៨,៨៤ | ៣៨,៩៦ | ៤,១ |
| វ៉ុន-កូរ៉េ | ៣,៦២ | ៣,៥២ | ៣,៤១ | ៣,៣៤ | ៣,៣៣ | ៣,៣៩ | ៣,៣២ | ៣,៤២ | ៣,៤៥ | ៣,៤៧ | ៣,៥១ | ៣,៥៩ | ៣,៦៧ | ៤,៣ |
| ដុល្លារ-ញូវស៊ីឡែន | ២.៦៩៦ | ២.៧៤៥ | ២.៦៦៦ | ២.៥៦៨ | ២.៤៤៩ | ២.៥១៤ | ២.៥៤៩ | ២.៦២៩ | ២.៧៤៦ | ២.៧៦៦ | ២.៧០៨ | ២.៧១៨ | ២.៨៤៩ | ៣,៨ |
| យ៉ន់ចិន | ៥៨៤ | ៥៨៣ | ៥៨៦ | ៥៨១ | ៥៧៣ | ៥៧៩ | ៥៧៦ | ៥៧៨ | ៥៨៥ | ៥៩៨ | ៦០២ | ៦០៦ | ៦១៦ | ៥,៧ |
| ដុល្លារ-តៃវ៉ាន់ | ១៣២ | ១៣៦ | ១៣៤ | ១៣៥ | ១៣៥ | ១៣៧ | ១៣៧ | ១៣៩ | ១៤០ | ១៣៩ | ១៤១ | ១៤២ | ១៤២ | ៤,៤ |
| **អាស៊ាន** | | | | | | | | | | | | | | |
| រ៉ូពី-ឥណ្ឌូនេស៊ី | ០,២៧៧ | ០,២៩៣ | ០,២៩៧ | ០,២៩០ | ០,២៤៩ | ០,២៦៩ | ០,២៨០ | ០,២៨៩ | ០,២៨២ | ០,២៨១ | ០,២៧៦ | ០,២៧៨ | ០,២៨៨ | -១,៧ |
| រីងហ្គីត-ម៉ាឡេស៊ី | ៩៦៩ | ៩៩៤ | ៩៩១ | ៩៦៧ | ៩៤២ | ៩៤៦ | ៩៤៧ | ៩៥៦ | ៩៦៧ | ៩៨៦ | ៩៨៨ | ៩៧៥ | ៩៩៥ | ០,១ |
| ប៉េសូ-ហ្វីលីពីន | ៧៩,៥៣ | ៨០,៥០ | ៧៩,៤៥ | ៨០,១០ | ៧៩,៩៦ | ៨១,២០ | ៨១,២០ | ៨១,១០ | ៨៣,៤១ | ៨៤,៦៣ | ៨៤,៥៥ | ៨៣,៩៤ | ៨៤,២១ | ៤,៦ |
| ដុល្លារ-សាំងហ្គាពួរ | ២.៩៤២ | ៣.០២៣ | ២.៩៧៣ | ២.៩១៨ | ២.៨៥៩ | ២.៩០៤ | ២.៩០៣ | ២.៩៣៨ | ២.៩៩០ | ៣.០២២ | ២.៩៩៧ | ២.៩៨១ | ៣.០២៧ | ០,១ |
| បាត-ថៃ | ១២៤ | ១៣៦ | ១៣០ | ១២៩ | ១២៥ | ១២៦ | ១២៩ | ១៣៣ | ១៣១ | ១៣២ | ១៣០ | ១៣០ | ១៣៤ | -១,៥ |
| ដុង-វៀតណាម | ០,១៧៤ | ០,១៧៦ | ០,១៧៥ | ០,១៧៥ | ០,១៧២ | ០,១៧៦ | ០,១៧៧ | ០,១៧៧ | ០,១៧៧ | ០,១៧៧ | ០,១៧៧ | ០,១៧៥ | ០,១៧៥ | -០,៦ |
| **អឺរ៉ុប** | | | | | | | | | | | | | | |
| អឺរ៉ូ | ៤.៥៩៧ | ៤.៥៦៥ | ៤.៤៦៦ | ៤.៤៧៦ | ៤.៤៩០ | ៤.៤៥៤ | ៤.៥៥៨ | ៤.៦០២ | ៤.៨៦៧ | ៤.៨៨៩ | ៤.៨១៥ | ៤.៧៨០ | ៤.៨៤៤ | ៦,១ |
| **ផ្សេងៗ** | | | | | | | | | | | | | | |
| ផោន-អង់គ្លេស | ៥.០៩៨ | ៥.៣៤៤ | ៥.៣០១ | ៥.២៤៥ | ៥.០៣៧ | ៥.១៦០ | ៥.០៦៨ | ៥.០៣៨ | ៥.៣៧៧ | ៥.៤៨០ | ៥.២៧៤ | ៥.២៨៩ | ៥.៣៩៥ | ១,០ |

**ទិន្នន័យព្យាករណ៍*

| រូបិយប័ណ្ណ | ២០១៩ | ២០២០ | ២០២១ | | | | | | | | | | បម្រែបម្រួល% |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | តុលា-២១/ធ្នូ-២០ |
| អេសដេអែរ | ៥.៦៣៥ | ៥.៨២៦ | ៥.៨៤៨ | ៥.៨៨៧ | ៥.៧៣១ | ៥.៨០៧ | ៥.៨៧៨ | ៥.៨១៤ | ៥.៨១៣ | ៥.៨០៤ | ៥.៧៦៦ | ៥.៧៤៣ | -១,៤ |
| **អាស៊ី** | | | | | | | | | | | | | |
| ដុល្លារ-អូស្ត្រាលី | ២.៨៥៣ | ៣.០៨១ | ៣.១១៩ | ៣.១៩១ | ៣.០៧៧ | ៣.១៥៨ | ៣.១៣៦ | ៣.០៦៤ | ៣.០១២ | ២.៩៧៥ | ២.៩៣២ | ៣.០៥២ | -០,៩ |
| ដុល្លារ-ហុងកុង | ៥២៣ | ៥២២ | ៥២៤ | ៥២៥ | ៥២០ | ៥២១ | ៥២៥ | ៥២៥ | ៥២៥ | ៥២៤ | ៥២៤ | ៥២៣ | ០,២ |
| យ៉េន-ជប៉ុន | ៣៧,៤៣ | ៣៩,០៨ | ៣៨,៩៦ | ៣៨,៣១ | ៣៦,៦៤ | ៣៧,៣១ | ៣៧,០៥ | ៣៦,៨៦ | ៣៧,២២ | ៣៧,១១ | ៣៦,៤៦ | ៣៥,៧៣ | -៨,៦ |
| វ៉ុន-កូរ៉េ | ៣,៥២ | ៣,៧១ | ៣,៦៥ | ៣,៦៣ | ៣,៥៧ | ៣,៦៤ | ៣,៦៥ | ៣,៦០ | ៣,៥៥ | ៣,៥០ | ៣,៤៤ | ៣,៤៧ | -៦,៥ |
| ដុល្លារ-ញ៉ូស៊ីឡែន | ២.៧៤៥ | ២.៨៩៦ | ២.៩១៥ | ២.៩៨៧ | ២.៨២៧ | ២.៩៤៣ | ២.៩៤៥ | ២.៨៥១ | ២.៨៥៥ | ២.៨៥៥ | ២.៨០៥ | ២.៩១៣ | ០,៦ |
| យ៉ន់ចិន | ៥៨៣ | ៦១៩ | ៦៣០ | ៦៣០ | ៦១៦ | ៦២៥ | ៦៤០ | ៦៣០ | ៦៣១ | ៦៣១ | ៦៣០ | ៦៣៦ | ២,៧ |
| ដុល្លារ-តៃវ៉ាន់ | ១៣៦ | ១៤៤ | ១៤៥ | ១៤៧ | ១៤២ | ១៤៥ | ១៤៧ | ១៤៦ | ១៤៦ | ១៤៧ | ១៤៧ | ១៤៦ | ១,៤ |
| **អាស៊ាន** | | | | | | | | | | | | | |
| រូពី-ឥណ្ឌូនេស៊ី | ០,២៩៣ | ០,២៨៧ | ០,២៨៩ | ០,២៨៩ | ០,២៨០ | ០,២៧៩ | ០,២៨៥ | ០,២៨១ | ០,២៨១ | ០,២៨៤ | ០,២៨៥ | ០,២៨៧ | ០,០ |
| រីងហ្គីត-ម៉ាឡេស៊ី | ៩៩៤ | ១.០០០ | ១.០០៥ | ១.០០៣ | ៩៧៥ | ៩៨៧ | ៩៨៣ | ៩៨១ | ៩៦១ | ៩៨២ | ៩៧៤ | ៩៨០ | -២,០ |
| ប៉េសូ-ហ្វីលីពីន | ៨០,៥០ | ៨៤,២៣ | ៨៤,៥០ | ៨៣,៧២ | ៨៣,៣៣ | ៨៣,៥២ | ៨៥,២០ | ៨៤,០២ | ៨០,៩៥ | ៨១,៨៩ | ៨០,២២ | ៨០,១៧ | -៤,៨ |
| ដុល្លារ-សាំងហ្គាពួរ | ៣.០២៣ | ៣.០៤៩ | ៣.០៥៩ | ៣.០៦៣ | ៣.០០៣ | ៣.០៥៦ | ៣.០៧៥ | ៣.០៣០ | ៣.០១០ | ៣.០៣៣ | ២.៩៩៧ | ៣.០១៤ | -១,១ |
| បាត-ថៃ | ១៣៦ | ១៣៥ | ១៣៦ | ១៣៥ | ១២៩ | ១២៩ | ១៣០ | ១២៧ | ១២៤ | ១២៦ | ១២០ | ១២២ | -៩,៦ |
| ដុង-វៀតណាម | ០,១៧៦ | ០,១៧៥ | ០,១៧៦ | ០,១៧៧ | ០,១៧៥ | ០,១៧៦ | ០,១៧៧ | ០,១៧៧ | ០,១៧៧ | ០,១៧៩ | ០,១៧៩ | ០,១៧៩ | ២,៣ |
| **អឺរ៉ុប** | | | | | | | | | | | | | |
| អឺរ៉ូ | ៤.៥៦៥ | ៤.៩៦២ | ៤.៩២៦ | ៤.៩៤៤ | ៤.៧៤២ | ៤.៩១២ | ៤.៩៦២ | ៤.៨៥០ | ៤.៨៤២ | ៤.៨១៣ | ៤.៧៣២ | ៤.៧១៦ | -៥,០ |
| **ផ្សេង** | | | | | | | | | | | | | |
| ផោន-អង់គ្លេស | ៥.៣៤៤ | ៥.៤៦៥ | ៥.៥៧៨ | ៥.៦៨៦ | ៥.៥៥៨ | ៥.៦៤៩ | ៥.៧៧២ | ៥.៦៤៥ | ៥.៦៨៧ | ៥.៦១៣ | ៥.៤៨០ | ៥.៥៨៤ | ២,២ |

**ទិន្នន័យព្យាករណ៍*